ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម
# ឆ្នាំ ២០២៤-២០៣៥

គាំពារសង្គមកម្ពុជា

SOCIAL PROTECTION IN CAMBODIA

រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម

ខែតុលា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម
# ឆ្នាំ ២០២៤-២០៣៥

គាំពារ
សង្គម
កម្ពុជា

SOCIAL PROTECTION IN CAMBODIA

រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម

ខែតុលា ឆ្នាំ២០២៤

# មាតិកា


បញ្ជីអក្សរកាត់ ..... I
បញ្ជីរូបភាព ..... II
បុព្វកថា ..... IV
ខ្លឹមសារសង្ខេប ..... VII
១. ស្ថានភាពទូទៅ ..... ១
១.១. សេចក្តីផ្តើម ..... ១
១.២. ការវិវឌ្ឍនៃម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ..... ២
១.៣. ការវិវឌ្ឍនៃស្ថានភាពសង្គម ..... ៣
១.៣.១. សន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស (Human Development Index) ..... ៣
១.៣.២. ស្ថានភាពប្រជាសាស្ត្រ ..... ៤
២. អភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ..... ៦
២.១. ចក្ខុវិស័យ ..... ៦
២.២. គោលបំណង ..... ៦
២.៣. គោលដៅ ..... ៦
២.៤. និយមន័យប្រព័ន្ធគាំពារសង្គម ..... ៧
២.៥. គោលការណ៍ហិរញ្ញប្បទាន ..... ៨
២.៦. អភិក្រមហានិភ័យនៃវដ្តជីវិត ..... ៨
២.៧. កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ..... ៩
២.៨. ការឆ្លើយតបនឹងគ្រោះអាសន្ន ..... ១០
២.៩. ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ..... ១១
២.១០. យន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម ..... ១១
៣. ធាតុផ្សំនៃប្រព័ន្ធគាំពារសង្គមកម្ពុជា ..... ១៣
៣.១. មាតុភាព និងហានិភ័យកុមារភាព ..... ១៤
៣.១.១. ស្ថានភាពទូទៅ ..... ១៤
៣.១.២. វិធានការគោលនយោបាយ ..... ១៥
៣.២. ហានិភ័យសុខភាព ..... ១៧
៣.២.១. ស្ថានភាពទូទៅ ..... ១៧
៣.២.២. វិធានការគោលនយោបាយ ..... ១៨

៣.៣. ហានិភ័យការងារ............................................................................១៩
៣.៣.១. ស្ថានភាពទូទៅ ....................................................................................១៩
៣.៣.២. វិធានការគោលនយោបាយ ......................................................................១៩
៣.៤. ពិការភាព .............................................................................................២០
៣.៤.១. ស្ថានភាពទូទៅ.....................................................................................២០
៣.៤.២. វិធានការគោលនយោបាយ ......................................................................២១
៣.៥. និកម្មភាព .............................................................................................២២
៣.៥.១. ស្ថានភាពទូទៅ.....................................................................................២២
៣.៥.២. វិធានការគោលនយោបាយ ......................................................................២២
៣.៦. ភាពគ្មានជម្រក.........................................................................................២៤
៣.៦.១. ស្ថានភាពទូទៅ.....................................................................................២៤
៣.៦.២. វិធានការគោលនយោបាយ ......................................................................២៤
៣.៧. ជរាភាព និងឧត្តរជីវី ...................................................................................២៥
៣.៧.១. ស្ថានភាពទូទៅ ....................................................................................២៥
៣.៧.២. វិធានការគោលនយោបាយ.......................................................................២៥
**៤. កិច្ចការឆ្លងវិស័យ ......................................................................................២៧**
៤.១. ការដោះស្រាយវិវាទ និងការទទួលមតិត្រឡប់ .....................................២៨
៤.១.១. ស្ថានភាពទូទៅ ....................................................................................២៨
៤.១.២. វិធានការគោលនយោបាយ......................................................................២៨
៤.២. ការកំណត់អត្តសញ្ញាណអត្តគាហក...........................................................២៩
៤.២.១. ស្ថានភាពទូទៅ.....................................................................................២៩
៤.២.២. វិធានការគោលនយោបាយ ......................................................................២៩
៤.៣. ប្រព័ន្ធគាំពារសង្គមឌីជីថល .........................................................................៣០
៤.៣.១. ស្ថានភាពទូទៅ ....................................................................................៣០
៤.៣.២. វិធានការគោលនយោបាយ ......................................................................៣០
៤.៤. ការបញ្ជ្រាបការយល់ដឹង ទំនាក់ទំនង និងការផ្សព្វផ្សាយ .........................៣២
៤.៤.១. ស្ថានភាពទូទៅ ....................................................................................៣២
៤.៤.២. វិធានការគោលនយោបាយ.......................................................................៣៣

៤.៥. គោលនយោបាយគាំទ្រប្រព័ន្ធគាំពារសង្គម ........................................ ៣៤
៤.៥.១. ស្ថានភាពទូទៅ ........................................ ៣៤
៤.៥.២. វិធានការគោលនយោបាយ ........................................ ៣៤
៤.៦. យន្តការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធគាំពារសង្គម ........ ៣៥
៤.៦.១. ស្ថានភាពទូទៅ ........................................ ៣៥
៤.៦.២. វិធានការគោលនយោបាយ ........................................ ៣៥
**៥. អភិបាលកិច្ចប្រព័ន្ធគាំពារសង្គមកម្ពុជា ........................................ ៣៦**
៥.១. កម្រិតគោលនយោបាយ ........................................ ៣៧
៥.១.១. ស្ថានភាពទូទៅ ........................................ ៣៧
៥.១.២. វិធានការគោលនយោបាយ ........................................ ៣៧
៥.២. កម្រិតនិយ័តករ ........................................ ៣៨
៥.២.១. ស្ថានភាពទូទៅ ........................................ ៣៨
៥.២.២. វិធានការគោលនយោបាយ ........................................ ៣៨
៥.៣. ប្រតិបត្តិករសន្តិសុខសង្គម៖ បេឡាជាតិសន្តិសុខសង្គម ........................ ៣៩
៥.៣.១. ស្ថានភាពទូទៅ ........................................ ៣៩
៥.៣.២. វិធានការគោលនយោបាយ ........................................ ៣៩
៥.៤. ប្រតិបត្តិករជំនួយសង្គម៖ មូលនិធិជាតិជំនួយសង្គម ........................ ៤០
៥.៤.១. ស្ថានភាពទូទៅ ........................................ ៤០
៥.៤.២. វិធានការគោលនយោបាយ ........................................ ៤០
៥.៥. ប្រតិបត្តិករមូលនិធិសមធម៌សុខាភិបាល ........................................ ៤១
៥.៥.១. ស្ថានភាពទូទៅ ........................................ ៤១
៥.៥.២. វិធានការគោលនយោបាយ ........................................ ៤១
៥.៦. ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ ........................................ ៤២
៥.៦.១. ស្ថានភាពទូទៅ ........................................ ៤២
៥.៦.២. វិធានការគោលនយោបាយ ........................................ ៤២
៥.៧. ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ........................................ ៤៣
៥.៧.១. ស្ថានភាពទូទៅ ........................................ ៤៣
៥.៧.២. វិធានការគោលនយោបាយ ........................................ ៤៣

**៦. យន្តការអនុវត្ត និងយន្តការតាមដាន និងវាយតម្លៃ** ...................... **៤៥**
៦.១. យន្តការអនុវត្ត ........................................................................ ៤៥
៦.២. យន្តការតាមដាន និងវាយតម្លៃ ...................................................... ៤៦
៦.២.១. យន្តការតាមដាន និងវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងផែនការសកម្មភាព ............................................ ៤៦
៦.២.២. យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ........................ ៤៦
**៧. សេចក្តីសន្និដ្ឋាន** ........................................................................ **៤៨**
**ឧបសម្ព័ន្ធ ១ ៖** សទ្ទានុក្រម ........................................................................ ៤៩
**ឧបសម្ព័ន្ធ ២ ៖** សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារបច្ចេកទេសរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០៣០............................... ៥៣
**ឧបសម្ព័ន្ធ ៣ ៖** ក្រុមការងារវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ ................................................................ ៥៦
**ឧបសម្ព័ន្ធ ៤ ៖** ក្រុមការងារគាំទ្រប្រចាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមសម្រាប់ការរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០២៤-២០៣៥ ................................................................ ៥៩

# បញ្ជីអក្សរកាត់

| | |
|---|---|
| ក.ជ.គ.ស. | ក្រុមប្រឹក្សាជាតិគាំពារសង្គម |
| គ.អ.ច.ក. | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា |
| ទ.ជ.ប. | ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ |
| ន.ស.ស. | និយ័តករសន្តិសុខសង្គម |
| ប.ជ.ស. | បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| ប.ស.ស. | បេឡាជាតិសន្តិសុខសង្គម |
| ប.ជ.អ. | បេឡាជាតិអតីតយុទ្ធជន |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| ម.ជ.ជ. | មូលនិធិជាតិជំនួយសង្គម |
| ម.ជ.ព. | មូលនិធិជនពិការ |

# បញ្ជីរូបភាព


រូបភាពទី១ ៖ ផលិតផលក្នុងស្រុកសរុបគិតជាមធ្យមសម្រាប់មនុស្សម្នាក់.....................................៣

រូបភាពទី២ ៖ អាយុសង្ឃឹមរស់របស់ពលរដ្ឋកម្ពុជា...................................................................៥

រូបភាពទី៣ ៖ ពីរ៉ាមីតប្រជាជនកម្ពុជាឆ្នាំ២០១៩-២០៣០ និង ឆ្នាំ២០១៩-២០៥០..........................៥

រូបភាពទី៤ ៖ អភិក្រមហានិភ័យនៃវដ្តជីវិត...........................................................................៩



“រាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស និងសុខុមាលភាពរបស់ពលរដ្ឋ តាមរយៈការបន្តជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ និងមានភាពធន់ដែលជាអាទិភាពមួយកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺការផ្តោតលើការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមតាមអភិក្រមហានិភ័យនៃវដ្តជីវិត ដោយឈរលើស្មារតី “**មិនបោះបង់ពលរដ្ឋណាម្នាក់**” ជាមួយនឹងទស្សនវិស័យ និងគោលដៅដ៏ច្បាស់លាស់គឺ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងបរិយាបន្ន។”

# បុព្វកថា

អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាគ្រប់នីតិកាលគឺការរក្សាឱ្យបាននូវសុខសន្តិភាព និងស្ថិរភាពនយោបាយពេញលេញ ដែលជាកត្តាសត្យានុម័តសម្រាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសជាតិ។ ជាក់ស្តែង, ព្រះរាជាណាចក្រកម្ពុជាបាន និងកំពុងទទួលផ្លែផ្កាពីសុខសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលធ្វើឱ្យកម្ពុជារក្សាបាននូវកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងរង្វង់ ៦,១% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១០ ដល់ ឆ្នាំ២០២៣ ទោះបីជាកម្ពុជាបានរងកម្មវិបាកអវិជ្ជមានពីវិបត្តិនៃជំងឺកូវីដ-១៩ នាពេលកន្លងមកក៏ដោយ ដែលការរក្សាបាននូវកំណើនក្នុងកម្រិតនេះ បានប្រែក្លាយកម្ពុជា ជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប តាំងពីឆ្នាំ២០១៥ មក។ ផ្លែផ្កានៃកំណើនសេដ្ឋកិច្ចនេះត្រូវបានបែងចែកប្រកបដោយសមធម៌ តាមរយៈការវិនិយោគលើវិស័យសុខាភិបាល វិស័យអប់រំ និងជាពិសេសលើប្រព័ន្ធគាំពារសង្គម ដោយរាជរដ្ឋាភិបាលទទួលស្គាល់ថា ការវិនិយោគនេះរួមចំណែកយ៉ាងសំខាន់ ក្នុងការកសាងសង្គមមួយប្រកបដោយសមធម៌ ភាពសុខដុម និងជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេស។ ជាលទ្ធផល, ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់បានកើនឡើងជាង ៨ ដង ពីទំហំប្រមាណ ៣១២ ដុល្លារអាមេរិក ក្នុងឆ្នាំ២០០០ ទៅប្រមាណ ២ ៥២០ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣ ដោយទន្ទឹមពេលជាមួយគ្នានេះដែរ អត្រានៃភាពក្រីក្របានធ្លាក់ចុះយ៉ាងខ្លាំង និងជាបន្តបន្ទាប់។

ផ្លែផ្កានៃកំណើនសេដ្ឋកិច្ច សុខសន្តិភាពពេញបរិបូរណ៍ និងស្ថិរភាពនយោបាយជាបុរេលក្ខខណ្ឌមិនអាចខ្វះបាន ដែលអនុញ្ញាឱ្យរាជរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រ ក៏ដូចជាអនុវត្តការងារកែទម្រង់សំខាន់ៗ ដើម្បីស្តារ និងអភិវឌ្ឍប្រទេស ដោយសម្រេចបាននូវលទ្ធផលគួរជាទីមោទកៈ។ កន្លងមក, រាជរដ្ឋាភិបាលបានផ្តោតលើការកសាងប្រព័ន្ធគាំពារសង្គម តាមរយៈការដាក់ឱ្យអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដែលក្របខណ្ឌគោលនយោបាយ នេះបាន និងកំពុងដើរតួយ៉ាងសំខាន់ ក្នុងការកសាង និងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឱ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន។ តាមរយៈការអនុវត្តក្របខណ្ឌគោលនយោបាយនេះ, ក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានដឹកនាំការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដោយសម្រេចបាននូវសមិទ្ធផលជាច្រើន ជាពិសេសការជួយទប់ស្កាត់ពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ពីការធ្លាក់ចូលក្នុងភាពក្រីក្រកាន់តែខ្លាំងក្នុងអំឡុងវិបត្តិធំៗនាពេលកន្លងមក រួមមានវិបត្តិដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩, សម្ពាធអតិផរណា, និងគ្រោះទឹកជំនន់ធ្ងន់ធ្ងរជាដើម។ ការណ៍នេះ បានឆ្លុះបញ្ចាំងថា ប្រព័ន្ធគាំពារសង្គមកម្ពុជាកាន់តែមានភាពធន់, ភាពរឹងមាំ, វិសាលភាពធំជាងមុន, សមាហរណ៍ និងកាន់តែមានប្រសិទ្ធភាព។

ជាការសម្លឹងទៅមុខ និងដើម្បីសម្រេចបានចក្ខុវិស័យរយៈពេលវែងក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០, រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញ

យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព ដោយកំណត់យកអាទិភាពគន្លឹះចំនួន៥ រួមមានមនុស្ស ផ្លូវ ទឹក ភ្លើង និង បច្ចេកវិទ្យា ដែលមានន័យថា "មនុស្ស" នៅតែជាអាទិភាពទី១ សម្រាប់រួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស និងសុខុមាលភាពរបស់ពលរដ្ឋ តាមរយៈការបន្តជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំនិងមានភាពធន់ ដែលជាអាទិភាពមួយកំណត់ក្នុង យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺការផ្តោតលើការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមតាមអភិក្រមហានិភ័យនៃវដ្តជីវិត ដោយឈរលើស្មារតី "មិនបោះបង់ពលរដ្ឋណាម្នាក់" ជាមួយនឹងទស្សនវិស័យ និងគោលដៅដ៏ច្បាស់លាស់គឺ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយសមធម៌ និងបរិយាបន្ន។

ឆ្លើយតបនឹងទិសដៅយុទ្ធសាស្ត្រនេះ និងផ្អែកលើមូលដ្ឋាននៃស្ថិរភាពនយោបាយ កំណើនសេដ្ឋកិច្ច ការវិវឌ្ឍសង្គម-សេដ្ឋកិច្ច និងវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកន្លងមក, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវ "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥" ដែលជាការធ្វើបច្ចុប្បន្នកម្ម "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥" ក្នុងគោលបំណងបន្តជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមបន្ថែមទៀត ដោយផ្តោតលើការកសាងភាពធន់ និងរក្សាភាពទន់ភ្លន់ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គ្រោះអាសន្ន និងវិបត្តិនានា ក៏ដូចជាការវិវឌ្ឍនៃកត្តាសេដ្ឋកិច្ច កត្តាសង្គម និងកត្តាប្រជាសាស្ត្រ ជាទូទៅផងដែរ។

"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥" នឹងដើរតួជាមគ្គុទ្ទេសក៍ រយៈពេលវែង ជំនួស "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥" ដើម្បីធានានិរន្តរភាព នៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ដោយបន្តតម្រង់ទិសសម្រាប់រយៈពេល ១១ឆ្នាំ ទៅមុខ សំដៅរួមចំណែកលើកកម្ពស់សុខុមាលភាពសង្គម និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមថ្មីនេះ ផ្លាស់ប្តូរពីអភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមតាមបែបសសរស្តម្ភ ទៅជាការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងការផ្តល់កិច្ចគាំពារតាមហានិភ័យនៃវដ្តជីវិត ដោយបន្តផ្តោតការយកចិត្តទុកដាក់លើការធានានូវសន្តិសុខប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចរបស់ពលរដ្ឋ សំដៅលើកកម្ពស់សុខុមាលភាព ការឆ្លើយតបនឹងយេនឌ័រ សមភាពសង្គម ព្រមទាំងកាត់បន្ថយភាពក្រីក្រ។

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ កំណត់នូវវិធានការគោលនយោបាយគាំពារសង្គម ដែលឆ្លើយតបនឹងហានិភ័យនៃវដ្តជីវិតទាំង ៧ ដំណាក់កាលរបស់មនុស្សដែលរួមមាន មាតុភាព និងកុមារភាព, ហានិភ័យការងារ, និកម្មភាព, ហានិភ័យសុខភាព, ពិការភាព, ភាពគ្មានជម្រក និងជរាភាពនិងឧត្តរជីវី។ ក្របខណ្ឌគោលនយោបាយនេះ ក៏កំណត់ផងដែរនូវវិធានការគោលនយោបាយសម្រាប់កិច្ចការឆ្លងវិស័យពាក់ព័ន្ធ ដើម្បីជួយជំរុញដំណើរការអភិវឌ្ឍន៍ និងមិនបង្កភាពរាំងស្ទះដល់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏កំណត់វិធានការគោលនយោបាយ សម្រាប់បន្តពង្រឹងអភិបាលកិច្ចប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ តាមមុខងារទាំង ៣ កម្រិត រួមមានកម្រិតគោលនយោបាយ កម្រិតនិយ័តករ និងកម្រិតប្រតិបត្តិករ ដើម្បីធានាបាននូវប្រតិតុល្យការរវាងការបំពេញមុខងារនីមួយៗ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥" នឹងជំរុញកម្រិតជីវភាព និងគុណភាពជីវិតរបស់ពលរដ្ឋគ្រប់រូប ឱ្យមានភាពប្រសើរឡើងថែមទៀត ព្រមទាំងជួយពង្រឹងសាមគ្គីភាព និងស្ថិរភាពសង្គម យ៉ាងពិតប្រាកដ។ ក្នុងន័យនេះ, ក្រសួង-ស្ថាប័ន ពាក់ព័ន្ធត្រូវសហការគ្នាជាធ្លុងមួយ ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ ក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីជំរុញការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០២៤-២០៣៥ នេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងដែលបានកំណត់។

ជាមួយគ្នានេះ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំរបស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលបានដឹកនាំដោយផ្ទាល់ និងផ្តល់ការណែនាំជាប្រចាំដល់ក្រុមការងារដែលសម្របសម្រួលដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងការរៀបចំសេចក្តីព្រាង ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ នេះ តាំងពីដើមទី រហូតសម្រេចបានដោគជ័យដោយរៀបចំបាននូវឯកសារជាប្រវត្តិសាស្ត្រដ៏សំខាន់ សម្រាប់ប្រព័ន្ធគាំពារសង្គមកម្ពុជានេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម, ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម, ក្រុមការងារបច្ចេកទេសរៀបចំក្របខណ្ឌគោលនយោបាយនេះ រួមទាំងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ដែលបានផ្តល់កិច្ចសហការគាំទ្រ និងចូលរួមយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងដំណើរការនៃការរៀបចំឯកសារដ៏មានតម្លៃនេះ។

ថ្ងៃ ចន្ទ ១១រោច ខែ អស្សុជ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា គ.ស.២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# ខ្លឹមសារសង្ខេប

"**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥**" ត្រូវបានរៀបចំឡើងតាមរយៈការធ្វើបច្ចុប្បន្នកម្ម និងជំនួស "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥" ដើម្បីធានានិរន្តរភាពនៃការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព ដែលអាចគ្របដណ្តប់ហានិភ័យនៃវដ្តជីវិត និងឆ្លើយតបនឹងគ្រោះអាសន្ន ឬវិបត្តិនានាជាយថាហេតុ។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ ធ្វើការផ្លាស់ប្តូរអភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមតាមបែបសសរសស្តម្ភ មកជាការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងការផ្តល់កិច្ចគាំពារតាមហានិភ័យនៃវដ្តជីវិត ឱ្យស្របតាមការវិវឌ្ឍជាក់ស្តែងនៃសង្គម-សេដ្ឋកិច្ចកម្ពុជា និងនិន្នាការតំបន់ និងសកល។ ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍សំខាន់ៗ ចំនួន ៧ គឺ៖ (១) សមធម៌ និងបរិយាបន្ន, (២) ភាពគ្រប់គ្រាន់, (៣) ស័ក្តិសិទ្ធិភាព, (៤) ភាពបត់បែន, (៥) ចីរភាព, (៦)អភិបាលកិច្ចល្អ, និង (៧) ការឆ្លើយតបនឹងយេនឌ័រ (Gender Responsiveness) រួមទាំងការគិតគូរលើគោលការណ៍ហិរញ្ញប្បទានប្រកបដោយភាពប្រាកដប្រជា។

ដោយផ្អែកលើការវិភាគស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា ក៏ដូចជានិន្នាការតំបន់ និងសកល, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមនេះ កំណត់នូវអន្តរាគមន៍គាំពារសង្គមច្បាស់លាស់ទៅតាមហានិភ័យនៃវដ្តជីវិតទាំង៧ ដែលរួមមាន៖



១. **មាតុភាព និងហានិភ័យកុមារភាព៖** ពង្រឹងយន្តការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ សម្រាប់គ្រប់ក្រុមគោលដៅ ដោយនឹងបន្តគិតគូរគ្របដណ្តប់បន្ថែមលើកុមារដល់អាយុ ៥ឆ្នាំ និងក្រុមគោលដៅផ្សេងទៀត; ពង្រឹងសមត្ថភាពស្ថាប័ន និងយន្តការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ដោយគិតគូរពង្រីកវិសាលភាពជាជំហានៗ; ពិនិត្យលទ្ធភាពដំឡើងកម្រិតប្រាក់ឧបត្ថម្ភនៃកម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ និងពង្រីកការគ្របដណ្តប់ជាជំហានៗប្រកបដោយចីរភាព។



២. **ហានិភ័យសុខភាព៖** ផ្តោតលើការអនុវត្តទិសដៅគោលនយោបាយដែលបានកំណត់ក្នុង "ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ២០២៤-២០៣៥" ដើម្បីជំរុញឱ្យការគ្របដណ្តប់សុខភាពជាសកល ក្លាយជាការពិតសម្រាប់កម្ពុជា។



៣. **ហានិភ័យការងារ៖** ជំរុញការពង្រឹងគុណភាពសេវាព្យាបាល និងការស្តារនីតិសម្បទា នៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ដោយពិនិត្យលទ្ធភាពប្រើប្រាស់សេវារបស់មជ្ឈមណ្ឌលរដ្ឋ ឱ្យបានជាអតិបរមា ក៏ដូចជាពិនិត្យឡើងវិញនូវកញ្ចប់អត្ថប្រយោជន៍ឱ្យស្របនឹងកម្រិតភាគទានដែលបង់ ព្រមទាំងសិក្សាលទ្ធភាពពង្រីកវិសាលភាពនៃរបបនេះទៅបុគ្គលស្វ័យនិយោជន៍ ដូចបណ្តាប្រទេសមួយចំនួនក្នុងតំបន់។



៤. **ពិការភាព៖** ពង្រឹងយន្តការកំណត់អត្តសញ្ញាណពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន; ពង្រឹងយន្តការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាពក្រីក្រ ក្នុងកញ្ចប់គ្រួសារ; ពង្រឹងយន្តការគាំពារផ្នែកពិការភាព ដោយផ្តោតសំខាន់លើការស្តារនីតិសម្បទា ក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកប្រាក់សោធន ក៏ដូចជាពិនិត្យលទ្ធភាពផ្តល់ការគាំពារបន្ថែមដល់ជនមានពិការភាព ដែលជាសមាជិកនៃគ្រួសារងាយរងហានិភ័យ។



៥. **និកម្មភាព៖** បន្តកសាងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន ដើម្បីត្រៀមខ្លួនសម្រាប់ការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ; ពង្រឹងយន្តការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ; ធ្វើស្ថាប័នូបនីយកម្ម "កម្មវិធីគាំពារសង្គមដើម្បីចាកចេញពីភាពក្រីក្រ" និង "កម្មវិធីសាច់ប្រាក់ពលកម្ម"ដែលអាចនឹងដាក់ឱ្យដំណើរការក៏ដូចជាសិក្សាលទ្ធភាពក្នុងការដាក់ឱ្យដំណើរការកម្មវិធីផ្តល់ឥណទានសម្រាប់ការសិក្សាថ្នាក់ឧត្តមសិក្សា ដល់និស្សិតខ្វះលទ្ធភាពបង់ថ្លៃសិក្សាតែមានបំណងចូលរៀនថ្នាក់ឧត្តមសិក្សា។



៦. **ភាពគ្មានជម្រក៖** សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ទ្រទ្រង់ចំណាយជួលផ្ទះឬបន្ទប់ស្នាក់នៅដល់សិស្ស និងនិស្សិតដែលមកពីគ្រួសារក្រីក្រ និងងាយរងគ្រោះ និងគ្រួសារងាយរងហានិភ័យដែលចាប់ផ្តើមពីការអនុវត្តសាកល្បង ក៏ដូចជា សិក្សាសមិទ្ធិលទ្ធភាពក្នុងការដាក់ឱ្យដំណើរការកម្មវិធី "លំនៅឋានតម្លៃសមរម្យ" សម្រាប់ប្រជាជនមានចំណូលទាប និងជនងាយរងគ្រោះក៏ដូចជាសិក្សាសមិទ្ធិលទ្ធភាពក្នុងការផ្តល់ការគាំទ្រសម្រាប់ជួយសម្រួលដល់ក្រុមជនងាយរងគ្រោះដែលកំពុងស្នាក់នៅតាមទីវត្តអារាម និងទីកន្លែងសាសនាដទៃទៀត ផងដែរ។



៧. **ជរាភាព និងឧត្តរជីវី៖** កែទម្រង់របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ដើម្បីជានាទីរភាពនៃប្រព័ន្ធសោធនជារួម; សិក្សាសមិទ្ធិលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលស្វ័យនិយោជន៍ទៅតាមបរិបទជាក់ស្តែង ក៏ដូចជាពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យដំណើរការប្រព័ន្ធសោធនពហុកម្រិត (Multi-tiers Pension System) ដើម្បីពង្រីកការគ្របដណ្តប់ដល់ពលរដ្ឋផ្សេងទៀតដែលមិនទាន់ទទួលបានការគ្របដណ្តប់។

បន្ថែមលើនេះ និងដើម្បីជួយជំរុញដំណើរការអភិវឌ្ឍ និងមិនបង្កភាពរាំងស្ទះដល់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ទាំងដោយផ្ទាល់ ឬដោយប្រយោល, ក្របខណ្ឌគោលនយោបាយនេះក៏កំណត់នូវវិធានការគោលនយោបាយសម្រាប់កិច្ចការឆ្លងវិស័យ ដូចជា៖ ១) ការដោះស្រាយវិវាទ និងការទទួលមតិត្រឡប់, ២) ការកំណត់អត្តសញ្ញាណអត្ថគាហក, ៣) ប្រព័ន្ធគាំពារសង្គមឌីជីថល, ៤) ការបញ្ជ្រាបការយល់ដឹង ទំនាក់ទំនង និងការផ្សព្វផ្សាយ, ៥) គោលនយោបាយគាំទ្រប្រព័ន្ធគាំពារសង្គម, និង ៦) យន្តការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធគាំពារសង្គម។

លើសពីនេះ និងដើម្បីធានាបាននូវប្រតិតុល្យការរវាងការបំពេញមុខងារក្នុងប្រព័ន្ធគាំពារសង្គម, អភិបាលកិច្ចនៃប្រព័ន្ធគាំពារសង្គមនឹងត្រូវបានពង្រឹងឱ្យកាន់តែរឹងមាំតាមមុខងារទាំង ៣ កម្រិត រួមមាន៖

១. **កម្រិតគោលនយោបាយ** មានក្រុមប្រឹក្សាជាតិគាំពារសង្គមបំពេញមុខងារក្នុងការតម្រង់ទិសគោលនយោបាយ

២. **កម្រិតនិយ័តករ** មាននិយ័តករសន្តិសុខសង្គមបំពេញតួនាទីតាមដាន និងត្រួតពិនិត្យរាល់ប្រតិបត្តិការនៃគ្រប់របបសន្តិសុខសង្គម និងសិក្សាអំពីលទ្ធភាពក្នុងការបង្កើតមុខងារនិយ័តកម្មសម្រាប់កម្មវិធីជាតិជំនួយសង្គម, និង

៣. **កម្រិតប្រតិបត្តិករ** មានបេឡាជាតិសន្តិសុខសង្គម, មូលនិធិជាតិជំនួយសង្គម, ប្រតិបត្តិករមូលនិធិសមធម៌សុខាភិបាល, ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ, និងការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាស្ថាប័នអនុវត្តផ្ទាល់។




**“ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០២៤-២០៣៥”** នេះ ដើរតួនាទីជាមគ្គុទ្ទេសក៍រយៈពេលវែង ជំនួស “ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥” ក្នុងការបន្តតម្រង់ទិសការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ឱ្យកាន់តែរឹងមាំ និងកាន់តែប្រសើរ ប្រកបដោយនិរន្តរភាព សម្រាប់រយៈពេល១១ឆ្នាំបន្តទៀត។

# ១

# ទិដ្ឋភាពទូទៅ

## ១.១. សេចក្តីផ្តើម

ក្នុងរយៈពេលប្រមាណ ១០ ឆ្នាំចុងក្រោយនេះ, ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជាបានបោះជំហាន គួរជាទីមោទកៈ ជាពិសេសក្រោយពេលរាជរដ្ឋាភិបាលបានដាក់ចេញនូវ "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥" ដែលជាផែនទីបង្ហាញផ្លូវសម្រាប់រយៈពេលវែង សម្រាប់ការដាក់ចេញឱ្យអនុវត្តរបបសន្តិសុខសង្គម និងកម្មវិធីជាតិជំនួយសង្គមនានានៅកម្ពុជា។ អនុលោមតាមការចង្អុលបង្ហាញរបស់ក្របខណ្ឌគោលនយោបាយនេះ, ក្រុមប្រឹក្សាជាតិគាំពារសង្គមដែលត្រូវបានបង្កើតឡើង បាន និងកំពុងបំពេញតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាលសម្រាប់សម្របសម្រួលក្នុងការដាក់ចេញគោលនយោបាយគាំពារសង្គម ដែលមានលក្ខណៈប្រមូលផ្តុំ និងសង្គតិភាព។ វត្តមាន និងប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម បានបង្ហាញឱ្យឃើញពីសារៈសំខាន់នៃយន្តការកណ្តាលមួយសម្រាប់កិច្ចពិភាក្សា និងផ្លាស់ប្តូរយោបល់លើគោលនយោបាយ និងយន្តការដែលមានលក្ខណៈប្រទាក់ក្រឡា និងមានភាពជាប់ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័នច្រើន។

ក្នុងនាមជាស្ថាប័នដឹកនាំសម្របសម្រួល និងជំរុញការអភិវឌ្ឍរបបសន្តិសុខសង្គម និងកម្មវិធីជាតិជំនួយសង្គមនានា ដែលបានកំណត់ក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥, ក្រុមប្រឹក្សាជាតិគាំពារសង្គមបានដឹកនាំការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ឱ្យឈានដល់ដំណាក់កាលថ្មីមួយ ដែលមានលក្ខណៈកាន់តែរឹងមាំ សមាហរណ៍ និងមានប្រសិទ្ធភាព។ ទោះយ៉ាងណា,ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជានៅតែបន្តមានសក្តានុពល ក្នុងការបោះជំហានទៅមុខបន្ថែមទៀតស្របពេលដែលរាជរដ្ឋាភិបាលបានដាក់ចេញនូវចក្ខុវិស័យប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ការណ៍នេះ បង្ហាញកាន់តែច្បាស់ថា កម្ពុជាត្រូវការជាចាំបាច់នូវប្រព័ន្ធគាំពារសង្គមមួយដែលកាន់តែរឹងមាំថែមមួយកម្រិតទៀត ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈម ទាំងក្នុងកម្រិតជាតិ និងកម្រិតសកលតាមរយៈការបែងចែកធនធានឡើងវិញឱ្យកាន់តែប្រសើរ សំដៅចូលរួមធានាបាននូវសមធម៌ បរិយាបន្ន សាមគ្គីភាព និងស្ថិរភាពក្នុងសង្គម។

កន្លងមក, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការតម្រង់ទិសការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជាយ៉ាងគាប់ប្រសើរ ប៉ុន្តែដោយមានការវិវឌ្ឍយ៉ាងឆាប់រហ័សនៃព្រឹត្តិការណ៍សកលនានា ដូចជាវិបត្តិជំងឺកូវីដ-១៩ និងជាមួយនឹងលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្ត, រាជរដ្ឋាភិបាលបានមើលឃើញពីភាពចាំបាច់ក្នុងការធ្វើបច្ចុប្បន្នកម្មក្របខណ្ឌគោលនយោបាយនេះ ទៅជា "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម

ឆ្នាំ២០២៤-២០៣៥" ក្នុងគោលបំណងបន្តពង្រឹងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមបន្ថែមទៀត ដោយផ្តោតលើការកសាងភាពធន់ និងការរក្សាភាពទន់ភ្លន់ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គ្រោះអាសន្ន និងវិបត្តិនានា ក៏ដូចជាការវិវឌ្ឍនៃកត្តាសេដ្ឋកិច្ច និងកត្តាសង្គមជាទូទៅ។

"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥" នេះ ដើរតួនាទីជាមគ្គុទ្ទេសក៍រយៈពេលវែង ជំនួសក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥ ដើម្បីបន្តនិរន្តរភាពនៃការតម្រង់ទិសការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជាឱ្យកាន់តែរឹងមាំ និងកាន់តែប្រសើរ សម្រាប់រយៈពេល ១១ឆ្នាំ បន្តទៀត។ ក្របខណ្ឌគោលនយោបាយនេះ ធ្វើការផ្លាស់ប្តូរពីអភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមដែលផ្តោតលើសសរស្តម្ភ ទៅជាការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងការផ្តល់កិច្ចគាំពារតាមហានិភ័យនៃវដ្តជីវិតវិញដោយបន្តផ្តោតការយកចិត្តទុកដាក់លើការធានានូវសន្តិសុខប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចរបស់ពលរដ្ឋសំដៅលើកកម្ពស់សុខុមាលភាព ការឆ្លើយតបនឹងយេនឌ័រ ព្រមទាំងកាត់បន្ថយភាពក្រីក្រ ទន្ទឹមនឹងការត្រៀមខ្លួនដោះស្រាយបញ្ហាដែលបង្កឡើងដោយគ្រោះអាសន្ន និងវិបត្តិនានា ជាយថាហេតុ។

## ១.២. ការវិវឌ្ឍនៃម៉ាក្រូសេដ្ឋកិច្ចកម្ពុជា

សេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ បន្ទាប់ពីកម្ពុជាបានប្រកាន់យករបបសេដ្ឋកិច្ចទីផ្សារសេរី ដែលជាមូលដ្ឋានគ្រឹះក្នុងការដាក់ចេញនូវផែនការកែទម្រង់រចនាសម្ព័ន្ធស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ។ ការធ្វើសេរីភាវូបនីយកម្មផ្នែកវិនិយោគ និងពាណិជ្ជកម្ម បានទាក់ទាញលំហូរវិនិយោគបរទេសមកកម្ពុជាជាបន្តបន្ទាប់ និងបានជំរុញឱ្យមានកំណើនការផលិត និងការនាំចេញទៅទីផ្សារបរទេសដែលបានបង្កើតការងារក្នុងស្រុក រួមចំណែកលើកកម្ពស់ជីវភាព ក៏ដូចជាកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋជាជំហានៗ។ ភាពជោគជ័យទាំងនេះ មិនមែនកើតឡើងដោយចៃដន្យទេ ប៉ុន្តែកើតចេញពីផ្លែផ្កានៃសុខសន្តិភាព ដែលបាននាំមកជូនជាតិមាតុភូមិ តាមរយៈការអនុវត្ត "**នយោបាយឈ្នះ-ឈ្នះ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អគ្គមគ្គុទ្ទេសក៍ឯកដ៏ឆ្នើមរបស់កម្ពុជា។

យោងតាមទិន្នន័យគណនេយ្យជាតិឆ្នាំគោលថ្មី ឆ្នាំ២០១៤ របស់វិទ្យាស្ថានជាតិស្ថិតិ, សេដ្ឋកិច្ចកម្ពុជាមានកំណើនជាមធ្យម ៩,៤% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៨ មុននឹងថមថយបន្តិចមកត្រឹម អត្រាប្រមាណ ៤,១% ក្នុងឆ្នាំ២០០៩ ដោយសារវិបត្តិសេដ្ឋកិច្ចសកល ប៉ុន្តែបានបន្តងើបឡើងវិញក្នុងកំណើនជាមធ្យម ៧,៦% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៩។ យ៉ាងណាមិញ, ការរីករាតត្បាតនៃជំងឺកូវីដ-១៩ បានផ្តល់កម្មវិបាកអវិជ្ជមាន ជាពិសេសលើវិស័យទេសចរណ៍, វិស័យសំណង់ និងវិស័យបម្រើឱ្យការនាំចេញ ដូចជាវិស័យកាត់ដេរជាដើម ដែលការណ៍នេះបានបណ្តាលឱ្យសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះជាលើកដំបូងក្នុងរយៈពេល ៣០ឆ្នាំចុងក្រោយ ក្នុងអត្រា ៣,៦% នៅឆ្នាំ២០២០។ ក្នុងឆ្នាំ២០២១, ឆ្នាំ២០២២ និងឆ្នាំ២០២៣ កំណើនសេដ្ឋកិច្ចបានបន្តងើបឡើងវិញក្នុងអត្រាកំណើន ៣,១%, ៥,១% និង ៥,០% រៀងគ្នា និងត្រូវបានព្យាករថាបន្តងើបឡើងក្នុងអត្រាកំណើន ៦,០% ក្នុងឆ្នាំ២០២៤។ ការរីកចម្រើន នៃកំណើនសេដ្ឋកិច្ចនេះ បានជំរុញជីវភាពរស់នៅរបស់ពលរដ្ឋកម្ពុជាមានការកើនឡើងជាបន្តបន្ទាប់។ ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) សម្រាប់មនុស្សម្នាក់បានកើនឡើងជាង ៨ដង ពីទំហំប្រមាណ ៣១២ ដុល្លារអាមេរិក ក្នុងឆ្នាំ២០០០ ដល់ប្រមាណ ២ ៥២០ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣។ គួរកត់សម្គាល់ថា យោងតាមការវាយតម្លៃរបស់ធនាគារពិភពលោក, ប្រទេសកម្ពុជាឱ្យបានប្រែក្លាយខ្លួនពីប្រទេសមានចំណូលទាប មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ ហើយស្ថាប័នអន្តរជាតិនានាជាច្រើន បានវាយតម្លៃថា កម្ពុជាជាប្រទេសមួយដែលមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចលឿនជាងគេ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍នានា ផងដែរ។

រូបភាពទី១៖ ផលិតផលក្នុងស្រុកសរុបគិតជាមធ្យមសម្រាប់មនុស្សម្នាក់




*ប្រភព៖ ទិន្នន័យគណនេយ្យជាតិឆ្នាំគោលថ្មី ឆ្នាំ ២០១៤*

ទន្ទឹមនឹងការសម្រេចបានកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ និងការកើនឡើងជាលំដាប់នៃប្រាក់ចំណូលរបស់ពលរដ្ឋ, រាជរដ្ឋាភិបាលរក្សាបានយ៉ាងល្អប្រសើរផងដែរនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជារួម។ ជាក់ស្តែង ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ, អត្រាអតិផរណាត្រូវបានរក្សាក្នុងកម្រិតអាចគ្រប់គ្រងបាន ពោលគឺក្នុងអត្រាមធ្យមប្រមាណ ៣% ខណៈដែលអត្រាប្តូរប្រាក់រក្សាបានក្នុងរង្វង់ ៤ ០៦០ រៀល ក្នុង ១ដុល្លារអាមេរិក។ ទុនបម្រុងអន្តរជាតិស្ថិតក្នុងរង្វង់ ១៩ ៩៩៨ លានដុល្លារអាមេរិក គិតត្រឹមឆ្នាំ២០២៣ ដែលអាចធានាការនាំចូលបានប្រមាណ ៨,២ខែ។ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២៣, ការនាំចូលបានកើនឡើងជាមធ្យមចំនួន ១២,២% ខណៈដែលការនាំចេញមានកំណើនជាមធ្យមចំនួន ១៣,៣%។

## ១.៣. ការវិវឌ្ឍនៃស្ថានភាពសង្គម

### ១.៣.១. សន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស (Human Development Index)

កម្ពុជាប្តេជ្ញាជានិច្ចក្នុងការចូលរួមសម្រេចបានឱ្យបាននូវរបៀបវារៈឆ្នាំ២០៣០ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា - Cambodia Sustainable Development Goals (គ.អ.ច.ក) ជាពិសេសលើគោលដៅពាក់ព័ន្ធនឹងការអភិវឌ្ឍមនុស្ស។ វឌ្ឍនភាពនៃការសម្រេច គ.អ.ច.ក ពាក់ព័ន្ធនឹងការអភិវឌ្ឍមនុស្ស មានជាអាទិ៍៖

- **គោលដៅទី១៖** បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទិសទី មានវឌ្ឍនភាពកម្រិតគួរឱ្យកត់សម្គាល់ ដោយសម្រេចបានសូចនាករតាមចំណុចដៅកំណត់ទាំងអស់ ដែលបង្ហាញតាមរយៈការកាត់បន្ថយអត្រាភាពក្រីក្រពី ២៦,៣% ក្នុងឆ្នាំ២០១៤ មកត្រឹម ១៧,៨% ក្នុងឆ្នាំ២០១៩។

- **គោលដៅទី២៖** បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យស្ថានភាពអាហារូបត្ថម្ភមានភាពប្រសើរឡើង និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព មានវឌ្ឍនភាពជារួមកម្រិតមធ្យម ដោយសារផលវិបាកអវិជ្ជមានពីការរីករាលដាលនៃជំងឺកូវីដ-១៩ ប៉ុន្តែមានវឌ្ឍនភាពល្អក្នុងការកាត់បន្ថយភាពក្រិសក្រិនរបស់កុមារ ដែលបានធ្លាក់ចុះពី ៣២% ក្នុងឆ្នាំ២០១៤ មកត្រឹម ២២% ក្នុងឆ្នាំ២០២១-២០២២។

- **គោលដៅទី៣៖** ធានាជីវភាពរស់នៅរបស់ពលរដ្ឋប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាព របស់មនុស្សគ្រប់រូបនិងគ្រប់វិស័យ មានវឌ្ឍនភាពកម្រិតគួរឱ្យកត់សម្គាល់ ដែលបង្ហាញតាមរយៈការកើនឡើងនៃអាយុសង្ឃឹមរស់ (Life expectancy) របស់ពលរដ្ឋកម្ពុជា ៦២ឆ្នាំ ក្នុងឆ្នាំ២០០៨ ទៅ ៧៦ឆ្នាំ ក្នុងឆ្នាំ២០២១-២០២២, ការធ្លាក់ចុះនៃអត្រាមរណភាពកុមារអាយុក្រោម ៥ឆ្នាំ ពី ៣៥នាក់ មកត្រឹម ១៦នាក់ ក្នុងចំណោម ១ ០០០ កំណើតរស់ នៅចន្លោះឆ្នាំ២០១៤ ដល់ឆ្នាំ២០២២ និងការធ្លាក់ចុះនៃអត្រាមរណៈមាតា ពី ១៧០នាក់ មកត្រឹម ១៥៤នាក់ ក្នុងចំណោម ១០០ ០០០ កំណើតរស់ នៅចន្លោះឆ្នាំដូចគ្នា។ វឌ្ឍនភាពផ្សេងទៀតមានដូចជា ការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍មានលទ្ធផលជាវិជ្ជមាន ដែល ៩៩% នៃអ្នកដឹងខ្លួនផ្ទុកមេរោគអេដស៍ បានទទួលការព្យាបាលដោយថ្នាំប្រឆាំងមេរោគអេដស៍ ក្នុងឆ្នាំ២០២២, ការដោះស្រាយបញ្ហាជំងឺរបេងបានល្អប្រសើរ ដែលកម្ពុជាត្រូវបានដកចេញពីបញ្ជីប្រទេសដែលមានបន្ទុកដោះស្រាយជំងឺរបេងធ្ងន់ធ្ងរ, ការធ្លាក់ចុះនៃករណីជំងឺគ្រុនចាញ់ពី ១,៩៥នាក់ មក ០,២៤នាក់ ក្នុងប្រជាជន ១ ០០០ នាក់ ក្នុងអំឡុងឆ្នាំ២០១៩-២០២២ និងមិនមានអ្នកស្លាប់ដោយជំងឺនេះចាប់ពីឆ្នាំ២០១៨ មក។
- **គោលដៅទី៤៖** ធានាការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាមួយជីវិតសម្រាប់ពលរដ្ឋគ្រប់រូប មានវឌ្ឍនភាពកម្រិតគួរឱ្យកត់សម្គាល់ ដោយអត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមភូមិបានកើនឡើងពី ៨២,៧% ក្នុងឆ្នាំ២០១៨ ដល់ ៩១,៧២% ក្នុងឆ្នាំ២០២២, សន្ទស្សន៍យុគភាពយេនឌ័រក្នុងវិស័យអប់រំ បានកើនឡើងពី ១,០៩% ក្នុងឆ្នាំ២០១៨ ដល់ ១,១៧% ក្នុងឆ្នាំ២០២២, អត្រាអក្ខរកម្មមនុស្សពេញវ័យបានកើនឡើងពី ៨៣,៥% ក្នុងឆ្នាំ២០១៨ ដល់ ៨៧,៨% ក្នុងឆ្នាំ២០២២, និងការបន្តផ្តោតការយកចិត្តទុកដាក់លើការធ្វើទំនើបកម្មវិស័យអប់រំ និងបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ។
- **គោលដៅទី៥៖** សម្រេចឱ្យបានការឆ្លើយតបនឹងយេនឌ័រ និងពង្រឹងភាពអង់អាចរបស់ស្ត្រី និងកុមារីគ្រប់រូប មានវឌ្ឍភាពច្រើនគួរឱ្យកត់សម្គាល់ តាមរយៈការរៀបចំបទដ្ឋានគតិយុត្ត សម្រាប់ជំរុញការអនុវត្ត និងការតាមដានពីការឆ្លើយតបនឹងយេនឌ័រ និងមិនរើសអើងភេទ ច្រើនលើសការកំណត់របស់គោលដៅ, ការរៀបចំបង្កើតយន្តការឆ្លើយតបពហុវិស័យលើហិង្សាលើយេនឌ័រ, និងការកើនឡើងនៃការបញ្ជ្រាបយេនឌ័រតាមវិស័យ។

### ១.៣.២. ស្ថានភាពប្រជាសាស្ត្រ

យោងតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, ចំនួនពលរដ្ឋបានកើនឡើងពី ១៣,៤ លាននាក់ ក្នុងឆ្នាំ២០០៨ ទៅ ១៥,៦ លាននាក់ ក្នុងឆ្នាំ២០១៩ ហើយត្រូវបានរំពឹងថានឹងកើនឡើងដល់ប្រមាណ ១៨,៧ លាននាក់ ក្នុងឆ្នាំ២០៣០, ប្រមាណ ២០,៦ លាននាក់ ក្នុងឆ្នាំ២០៤០ និង ប្រមាណ ២១,៧ លាននាក់ ក្នុងឆ្នាំ២០៥០។ រចនាសម្ព័ន្ធអាយុរបស់ពលរដ្ឋកម្ពុជាកំពុងឈានចូលដល់វ័យចំណាស់ ដែលពលរដ្ឋអាយុក្រោម ១៥ឆ្នាំ មាន ២៩,៤% ហើយមេដ្យានអាយុបានកើតឡើងពី ២២ឆ្នាំ ក្នុងឆ្នាំ២០០៨ ដល់ ២៧ឆ្នាំ ក្នុងឆ្នាំ២០១៩។ ជាមួយគ្នានេះ, ចំនួនពលរដ្ឋអាយុ៦០ឆ្នាំឡើង មានប្រមាណ ៨,៩% ក្នុងឆ្នាំ២០១៩ ហើយត្រូវបានរំពឹងថានឹងកើនដល់ ១២,៧% ក្នុងឆ្នាំ២០៣០, ១៦,១% ក្នុងឆ្នាំ២០៤០ និង ២៣,២% ក្នុងឆ្នាំ២០៥០។

រូបភាពទី២៖ អាយុសង្ឃឹមរស់របស់ពលរដ្ឋកម្ពុជា




*ប្រភព៖ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩*

រូបភាពទី៣៖ ពីរ៉ាមីតប្រជាជនកម្ពុជា ឆ្នាំ២០១៩-២០៣០ និង ឆ្នាំ២០១៩-២០៥០




*ប្រភព៖ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩*

# ២

# អភិក្រមនៃការអភិវឌ្ឍ ប្រព័ន្ធគាំពារសង្គមកម្ពុជា

## ២.១. ចក្ខុវិស័យ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា គឺផ្តល់ការគាំពារដល់ពលរដ្ឋគ្រប់រូបទល់នឹងអសន្តិសុខប្រាក់ចំណូលក្នុងពេលប្រឈមនឹងហានិភ័យនានា ក្នុងដំណាក់កាលនីមួយៗនៃវដ្តជីវិត សំដៅលើកកម្ពស់សុខភាព និងសុខុមាលភាព, កាត់បន្ថយភាពក្រីក្រ, កាត់បន្ថយវិសមភាពយេនឌ័រ និងវិសមភាពសង្គម ព្រមទាំងពង្រឹងសាមគ្គីភាព និងស្ថិរភាពសង្គម តាមរយៈការបន្តជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ, មានប្រសិទ្ធភាព និងប្រកបដោយចីរភាព។

## ២.២. គោលបំណង

"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥" មានគោលបំណងពង្រឹងការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់ និងដាក់ចេញនូវកម្មវិធីជាតិជំនួយសង្គម ឬរបបសន្តិសុខសង្គមថ្មីៗ តាមស្ថានភាពជាក់ស្តែងនៃការវិវឌ្ឍសង្គម-សេដ្ឋកិច្ច ដើម្បីផ្តល់ការគាំពារផ្នែកសន្តិសុខប្រាក់ចំណូលជូនពលរដ្ឋពេញមួយវដ្តជីវិត ដោយឈរលើគោលការណ៍ "**មិនបោះបង់ពលរដ្ឋណាម្នាក់**" តាមរយៈការពង្រឹងយន្តការចុះបញ្ជីក្នុងប្រព័ន្ធ និងយន្តការកំណត់អត្តសញ្ញាណពលរដ្ឋគោលដៅ។

## ២.៣. គោលដៅ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងខាងលើ, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ កំណត់គោលដៅចម្បងៗ ដូចខាងក្រោម៖

- ពង្រឹងអភិបាលកិច្ចប្រព័ន្ធគាំពារសង្គម ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងរបបសន្តិសុខសង្គម និងកម្មវិធីជាតិជំនួយសង្គមនីមួយៗ
- ពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់អត្ថប្រយោជន៍គាំពារសង្គមជូនដល់ពលរដ្ឋ
- ពង្រីកការគ្របដណ្តប់លើហានិភ័យនៃវដ្តជីវិត និងការឆ្លើយតបនឹងគ្រោះអាសន្ន ឬវិបត្តិនានា រួមទាំងការប្រែប្រួលអាកាសធាតុ
- ពង្រឹងការកំណត់អត្តសញ្ញាណអត្ថគាហក និងចុះបញ្ជីគាំពារសង្គមប្រកបដោយប្រសិទ្ធភាព បរិយាបន្ន និងអាចឆ្លើយតបនឹងតម្រូវការ
- កសាងភាពធន់នៃប្រព័ន្ធគាំពារសង្គមកម្ពុជាទាំងមូល។

## ២.៤. និយមន័យប្រព័ន្ធគាំពារសង្គម

ប្រព័ន្ធគាំពារសង្គមសំដៅលើគោលនយោបាយ, កម្មវិធីជាតិជំនួយសង្គម, របបសន្តិសុខសង្គម, សកម្មភាព, ក្របខណ្ឌច្បាប់ និងស្ថាប័ន ដែលត្រូវបានបង្កើតឡើង ដើម្បីពង្រឹងសន្តិសុខប្រាក់ចំណូល និងផ្ដល់ការគាំពារទល់នឹងហានិភ័យ និងភាពងាយរងគ្រោះនានាដែលពលរដ្ឋអាចនឹងជួបប្រទះ។

ប្រព័ន្ធគាំពារសង្គមកម្ពុជាចូលរួមកសាងសាមគ្គីភាពសង្គម តាមរយៈការលើកកម្ពស់សិទ្ធិ ក្នុងការទទួលបានការគាំពារប្រកបដោយសមធម៌ ការឆ្លើយតបនឹងយេនឌ័រ និងបរិយាបន្ន។ អន្តរាគមន៍គាំពារសង្គម រួមចំណែកដល់ការបែងចែកធនធានឡើងវិញ សំដៅគាំទ្រដល់សិទ្ធិក្នុងការរស់នៅថ្លៃថ្នូររបស់ពលរដ្ឋគ្រប់រូប។

ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជាត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍សំខាន់ៗ ដូចខាងក្រោម៖



១. **សមធម៌ និងបរិយាបន្ន៖** ការកំណត់គោលនយោបាយត្រូវគិតគូរឱ្យបានទូលំទូលាយ និងគ្រប់ជ្រុងជ្រោយសម្រាប់ពលរដ្ឋគ្រប់ក្រុមគោលដៅ ដោយផ្ដោតការយកចិត្តទុកដាក់លើភាពងាយរងគ្រោះ ជាចម្បង។



២. **ភាពគ្រប់គ្រាន់៖** ការកំណត់កញ្ចប់អត្ថប្រយោជន៍ត្រូវគិតគូរពីកម្រិតនៃភាពសមរម្យ និងអាចទទួលយកបាន ដើម្បីធានានូវសន្តិសុខប្រាក់ចំណូលអប្បបរមាក្នុងរយៈពេលវែង ដោយរក្សាឱ្យបាននូវតុល្យភាពរវាងការឧបត្ថម្ភរបស់រដ្ឋ និងការប្រឹងប្រែងដោយខ្លួនឯង។ ឈរលើគោលការណ៍នេះ, កញ្ចប់អត្ថប្រយោជន៍នៃកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមគួរត្រូវបានគិតគូរឱ្យមានការកែសម្រួលស្របតាមការវិវឌ្ឍនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការ និងស្ថានភាពសង្គម-សេដ្ឋកិច្ច។



៣. **ស័ក្តិសិទ្ធិភាព៖** ការគ្រប់គ្រង និងចាត់ចែង កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ត្រូវអនុវត្តដោយហ្មត់ចត់ និងរឹតត្បិត ចៀសវាងការខ្ជះខ្ជាយ ជាពិសេសលើចំណាយរដ្ឋបាល។



៤. **ភាពបត់បែន៖** ការគិតគូរអំពីជម្រើសគោលនយោបាយនានា ត្រូវផ្សារភ្ជាប់ទៅនឹងការវិវឌ្ឍនៃទិដ្ឋភាពនានា ដូចជាកត្តាប្រជាសាស្ត្រ, បច្ចេកវិទ្យា, សង្គម, និងបរិស្ថាន ជាដើម ដើម្បីធានាថាជម្រើសគោលនយោបាយនីមួយៗ អាចបត់បែនទៅតាមសភាពការណ៍នៃការប្រែប្រួលទាំងនោះ។



៥. **ចីរភាព៖** ការកំណត់យកគោលនយោបាយត្រូវគិតគូរឱ្យបានច្បាស់លាស់ពីបន្ទុកហិរញ្ញវត្ថុ ដើម្បីធានាថាការអនុវត្តប្រកបដោយនិរន្តរភាព និងមិនប៉ះពាល់ដល់ភាពទ្រទ្រង់បាននៃថវិកា ទាំងថវិការដ្ឋ និងថវិកាភាគទាន។



៦. **អភិបាលកិច្ចល្អ៖** ដំណើរការរៀបចំស្ថាប័ន ត្រូវប្រកាន់ខ្ជាប់នូវតម្លាភាព គណនេយ្យភាព និងប្រតិគុល្យការរវាងអ្នកអនុម័តគោលនយោបាយ អ្នកត្រួតពិនិត្យ និងអ្នកអនុវត្ត។



៧. **ការឆ្លើយតបនឹងយេនឌ័រ** (Gender Responsiveness)៖ ការរៀបចំគោលនយោបាយ របបសន្តិសុខសង្គម ឬកម្មវិធីជាតិជំនួយសង្គម ត្រូវយកចិត្តទុកដាក់ និងគិតគូរពីទិដ្ឋភាពយេនឌ័រ នៅគ្រប់ដំណាក់កាលគ្រប់ផ្នែកនៃដំណើការ និងកិច្ចការក្នុងការចូលរួមចំណែកឈានទៅសម្រេចបានគោលដៅសមភាពយេនឌ័រ។

## ២.៥. គោលការណ៍ហិរញ្ញប្បទាន

ការកសាងប្រព័ន្ធគាំពារសង្គមរឹងមាំមួយ ត្រូវការជាចាំបាច់នូវធនធានហិរញ្ញវត្ថុសមស្រប។ ក្នុងន័យនេះ ដោយឈរលើឧត្តមានុវត្តន៍អន្តរជាតិ, រាជរដ្ឋាភិបាលកំណត់យកជាគោលការណ៍រួមនៃការរៀបចំប្រព័ន្ធគាំពារសង្គមរបស់ជាតិ ដែលពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ភាគទាន ដើម្បីទទួលបានការគាំពារ តាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ទោះយ៉ាងណា, រាជរដ្ឋាភិបាលនឹងរ៉ាប់រងលើការផ្ដល់ការគាំទ្រសម្រាប់ក្រុមពលរដ្ឋក្រីក្រ ងាយរងគ្រោះ និងងាយរងហានិភ័យ ដែលមិនមានឬមានលទ្ធភាពតិចតួចបំផុតក្នុងការបង់ភាគទាន ដែលការគាំទ្រនេះចាំបាច់ត្រូវមានការគិតគូរឱ្យបានហ្មត់ចត់លើភាពអាចទ្រទ្រង់បាននៃថវិកាជាតិ និង "យុទ្ធសាស្ត្រចាកចេញ" ដោយគិតគូរផ្ដល់នូវការអប់រំ និងការបណ្ដុះបណ្ដាលពង្រឹងសមត្ថភាព និងឱកាសការងារសមរម្យ ក្នុងការបង្កើនប្រាក់ចំណូល និងលើកកម្ពស់ជីវភាពរស់នៅ ឈានទៅចូលរួមបង់ភាគទាន។

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ គិតគូរគ្រប់ជ្រុងជ្រោយអំពីការផ្ដល់ការគាំពារដល់ពលរដ្ឋគ្រប់រូប។ ទោះជាយ៉ាងណា, ការពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គមត្រូវធ្វើឡើងជាជំហានៗ ស្របតាមការវិវឌ្ឍនៃសង្គម-សេដ្ឋកិច្ច ជាពិសេសភាពទ្រទ្រង់បាននៃថវិកាជាតិ និងលទ្ធភាពនៃការបង់ភាគទានរបស់និយោជក និងពលរដ្ឋ។ មហិច្ឆតាខ្ពស់ក្នុងការជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនឹងនាំឱ្យមានអស្ថេរភាពហិរញ្ញវត្ថុ ដែលមិនអំណោយផលដល់លទ្ធភាពថវិកា និងចុងក្រោយផ្ដល់កម្មវិបាកអវិជ្ជមានដល់ការអភិវឌ្ឍប្រទេសទាំងមូល។ ដូច្នេះ ការកំណត់គោលនយោបាយគាំពារសង្គម ចាំបាច់ត្រូវផ្អែកលើសនិទានភាពនៃលំហសារពើពន្ធជាក់ស្ដែង, ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច, និងនយោបាយជារួម។

## ២.៦. អភិក្រមហានិភ័យនៃវដ្ដជីវិត

បញ្ហាប្រឈមចម្បងមួយសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា គឺភាពនៅមានកម្រិតនៃវិសាលភាពគ្របដណ្ដប់ ដែលមិនទាន់ធានាបាននូវសន្តិសុខប្រាក់ចំណូលសម្រាប់ពលរដ្ឋគ្រប់ក្រុមគោលដៅ នៅពេលដែលមានហានិភ័យកើតឡើងក្នុងដំណាក់កាលនីមួយៗនៃការរស់នៅប្រចាំថ្ងៃ។ ដូច្នេះ និម្មាបនកម្មនៃ "ផ្ទះគាំពារសង្គមកម្ពុជា" ត្រូវកសាងឡើងដោយបណ្ដុំនៃផ្នែកចំនួន ៧ ដែលផ្នែកនីមួយៗតំណាងឱ្យហានិភ័យក្នុងដំណាក់កាលជាក់លាក់នៃវដ្ដជីវិត ក្នុងនោះរួមមាន មាតុភាព និងហានិភ័យកុមារភាព, ហានិភ័យសុខភាព, ហានិភ័យការងារ, ពិការភាព, និកម្មភាព, ភាពគ្មានជម្រក, និងជរាភាពនិងឧត្តរជីវី។

រូបភាពទី៤៖ អភិក្រមហានិភ័យនៃវដ្តជីវិត




*ប្រភព៖ ក្រុមប្រឹក្សាជាតិគាំពារសង្គម*

## ២.៧. កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម

ភាពខុសគ្នារវាងកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ត្រូវបានកំណត់ដោយយន្តការហិរញ្ញប្បទាន និងក្រុមពលរដ្ឋគោលដៅដែលគ្របដណ្តប់។ កម្មវិធីជាតិជំនួយសង្គមប្រើប្រាស់ថវិការដ្ឋជាហិរញ្ញប្បទានតាមតម្រូវការជាក់ស្តែង ខណៈដែលរបបសន្តិសុខសង្គម ត្រូវបានទ្រទ្រង់ដោយថវិកាភាគទានដែលបង់ជាមុនរួមគ្នាចូលទៅក្នុងមូលនិធិសន្តិសុខសង្គម។

កម្មវិធីជាតិជំនួយសង្គម ផ្តោតលើការផ្តល់ការគាំទ្រដល់ពលរដ្ឋក្រីក្រដែលមានបណ្ណសមធម៌ និងពលរដ្ឋងាយរងគ្រោះផ្សេងទៀត ដែលត្រូវបានកំណត់អត្តសញ្ញាណដោយយន្តការអត្តសញ្ញាណកម្មអត្តគាហកជាក់លាក់របស់រាជរដ្ឋាភិបាល។ ដោយឡែក របបសន្តិសុខសង្គម ជាយន្តការធានារ៉ាប់រងសង្គម ដែលផ្តោតលើពលរដ្ឋផ្សេងទៀត ទាំងនៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

## ២.៨. ការឆ្លើយតបនឹងគ្រោះអាសន្ន

ប្រទេសកម្ពុជាប្រឈមមុខខ្ពស់ទៅនឹងវិបត្តិ និងគ្រោះអាសន្ននានា ហើយអាចក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ។ ស្ថានភាពនៃគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានបង្ហាញឱ្យឃើញ និងជាការក្រើនរម្លឹក អំពីភាព-ងាយរងគ្រោះដោយគ្រោះធម្មជាតិ ដែលតែងផ្តល់កម្មវិបាកអវិជ្ជមានដល់ជីវភាពរបស់ពលរដ្ឋ ជាពិសេសពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។ ថ្វីត្បិតកម្ពុជាទទួលបានជោគជ័យក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយ, ក៏ជំងឺរាតត្បាតនេះបានផ្តល់នូវកម្មវិបាកអវិជ្ជមាន និងបន្សល់នៅស្នាមរបួសលើសេដ្ឋកិច្ចជាតិ និងប្រព័ន្ធសុខាភិបាលទាំងមូលផងដែរ។ ម្យ៉ាងវិញទៀត កម្ពុជាជាប្រទេសដែលមានសេដ្ឋកិច្ចបើកចំហដែលពឹងផ្អែកជាចម្បងលើកត្តាខាងក្រៅ ដូចជាការវិនិយោគបរទេស, ទេសចរណ៍, ពាណិជ្ជកម្ម, និងខ្សែច្រវាក់ផ្គត់ផ្គង់ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដែលនាំឱ្យកម្ពុជាទទួលរងនូវកម្មវិបាកបន្ថែមពីវិបត្តិផ្សេងៗ ក្នុងបរិការណ៍ដែលពិភពលោកស្ថិតក្នុងជម្លោះភូមិសាស្ត្រនយោបាយ, សង្គ្រាមពាណិជ្ជកម្ម និងការកើនឡើងនៃគោលនយោបាយគាំពារនិយម (Protectionism policy) ជាដើម។

ក្នុងអំឡុងវិបត្តិនៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានដាក់ចេញអន្តរាគមន៍គាំពារសង្គមមួយចំនួនដើម្បីជួយដោះស្រាយបញ្ហាជីវភាពរបស់ពលរដ្ឋ ជាពិសេសពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។ ជាក់ស្តែង, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្រោយពេលបិទខ្ទប់ទ្រង់ទ្រាយធំ ជាកម្មវិធីជំនួយសង្គមក្នុងមួយគ្រានៃវិបត្តិដ៏មានប្រសិទ្ធភាព។ ជាមួយគ្នានេះ, ការអនុគ្រោះលើការបង់ភាគទានដល់បេឡាជាតិសន្តិសុខសង្គមក្នុងអំឡុងមានវិបត្តិ ក៏បានជួយសម្រួលដល់ក្រុមហ៊ុន-សហគ្រាសនានា ក្នុងគ្រាដ៏លំបាកនោះ ផងដែរ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏បានដាក់ចេញកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងមានសម្ពាធអតិផរណា និងកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ កាលពីចុងឆ្នាំ២០២២ និងដើមឆ្នាំ២០២៣ ដើម្បីជួយសម្រាលបន្ទុកជីវភាពរបស់ពួកគាត់។

ដើម្បីត្រៀមខ្លួនដោះស្រាយបញ្ហា នៅពេលមានវិបត្តិ ឬគ្រោះអាសន្ន រួមទាំងការប្រែប្រួលអាកាសធាតុ ដែលអាចកើតមានជាយថាហេតុនៅអនាគត, រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលការណ៍ណែនាំស្តីពី "ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន" ក្នុងគោលបំណងផ្តល់ការគាំពារដែលមានលក្ខណៈជាប្រព័ន្ធ, ទស្សន៍លទ្ធភាព, ភាពទាន់ពេល, និងប្រសិទ្ធភាពខ្ពស់ ដល់ពលរដ្ឋក្រីក្រ ងាយរងគ្រោះ និងងាយរងហានិភ័យ ទាំងក្នុងអំឡុង និងក្រោយពេលជួបគ្រោះអាសន្ននានា ដូចជាគ្រោះមហន្តរាយធម្មជាតិ វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិបត្តិសុខភាពសាធារណៈ។ គោលការណ៍ណែនាំនេះ កំណត់នូវជម្រើសឧបករណ៍គោលនយោបាយគាំពារសង្គម ដូចជាការកែសម្រួលយន្តការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់, ការពង្រីកការគ្របដណ្តប់តាមខ្សែបញ្ឈរ, ការពង្រីកការគ្របដណ្តប់តាមខ្សែផ្តេក, ការផ្សារភ្ជាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ពិសេសបន្ទាន់ក្នុងគ្រាអាសន្នរបស់ស្ថាប័នមនុស្សធម៌នឹងប្រព័ន្ធគាំពារសង្គម និងជម្រើសផ្សេងៗទៀត ដើម្បីឆ្លើយតបនឹងគ្រោះអាសន្ននានា។

## ២.៩. ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ

ការកសាងប្រព័ន្ធគាំពារសង្គម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ, សមាហរណ៍ និងស្វ័យប្រវត្តិ មានសារៈសំខាន់ក្នុងការទ្រទ្រង់សុខុមាលភាពពលរដ្ឋ។ ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលជាការប្រមូលផ្តុំកម្មវិធីជំនួយសង្គមមានលក្ខណៈជាការឧបត្ថម្ភសាច់ប្រាក់ ត្រូវបានរៀបចំឡើងដោយដាក់ឱ្យអនុវត្តក្នុងទម្រង់រួមមួយក្រោមមូលនិធិជាតិជំនួយសង្គម ដែលជាប្រតិបត្តិករទោល ក្នុងគោលដៅពង្រឹងអភិបាលកិច្ច និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី ក៏ដូចជាបង្កើនសង្គតិភាព និងពង្រីកការគ្របដណ្តប់កាន់តែទូលំទូលាយលើគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះក្នុងគ្រួសារនោះ។ ជាចំណុចចាប់ផ្តើម, កម្មវិធីជាតិជំនួយសង្គមចំនួន៤ ត្រូវបានកែសម្រួល ឬបង្កើតថ្មី និងធ្វើសមាហរណ៍មុខងារមកក្រោមកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលកម្មវិធីទាំងនោះ រួមមាន៖

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ
- កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រថ្នាក់បឋមសិក្សា និងមធ្យមសិក្សា
- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព
- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា (អាយុ ៦០ឆ្នាំឡើង)

ទន្ទឹមនេះ, កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារក៏ផ្តល់ការឧបត្ថម្ភគោលសម្រាប់គ្រួសារដែលមានបណ្ណសមធម៌ទាំងអស់ និងគិតគូរដល់សមាជិកគ្រួសារ ដែលរស់នៅជាមួយមេរោគ/ជំងឺអេដស៍ ដោយប្រកាន់ភ្ជាប់នូវគោលការណ៍បរិយាបន្ន និងសមធម៌។

ជាគោលការណ៍, រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពធ្វើសមាហរណកម្មកម្មវិធីជាតិជំនួយសង្គមផ្សេងទៀត ឬកម្មវិធីជាតិជំនួយសង្គមដែលនឹងបង្កើតថ្មី មកក្រោមកញ្ចប់គ្រួសារ តាមភាពជាក់ស្តែង។

## ២.១០. យន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម

យោងតាមអង្កេតកម្លាំងពលកម្មឆ្នាំ២០១៩, កម្ពុជាមានអ្នកធ្វើការងារក្រៅប្រព័ន្ធប្រមាណ ៨៨% ដែលមិនទទួលបានប្រាក់ឈ្នួលពេលឈប់សម្រាកប្រចាំឆ្នាំ ឬ អត្ថប្រយោជន៍ឈប់សម្រាកពេលព្យាបាលជំងឺ និងមិនទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គមណាមួយនៅឡើយ ទោះបីជាមានបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធមានវិសាលភាពគ្របដណ្តប់ដល់ពួកគាត់ក៏ដោយ។ទន្ទឹមនេះសហគ្រាសនិងគ្រឹះស្ថានដែលបានចុះបញ្ជីពាណិជ្ជកម្មឬមានអាជ្ញាបណ្ណឬមានលិខិតអនុញ្ញាតពីក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមទាំងកម្មករនិយោជិតជាច្រើនទៀត មិនទាន់បានចុះបញ្ជី ដើម្បីទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គមនៅឡើយ។ កង្វះការយល់ដឹង និងការផ្សព្វផ្សាយទូលំទូលាយអំពីរបបសន្តិសុខសង្គម,កង្វះយន្តការលើកទឹកចិត្ត និងកង្វះការពង្រឹងអនុលោមភាពនៃបទប្បញ្ញត្តិជាកត្តាចម្បងដែលបណ្តាលឱ្យសហគ្រាសនិងគ្រឹះស្ថាន ក៏ដូចជាកម្មករនិយោជិតមិនបានចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម។បន្ថែមលើនេះ, ការវិវឌ្ឍជឿនលឿននៃបច្ចេកវិទ្យា និងសេដ្ឋកិច្ចបាននាំមកនូវការកើនឡើងនៃបុគ្គលប្រកបវិជ្ជាជីវៈសេរី ឬការងារបែបម៉ៅការ (Casual workers or work) ដែលមិនទទួលបានប្រាក់ឈ្នួល តែទទួលបានកម្រៃជាទម្រង់ប្រាក់ជើងសារផ្អែកលើសមិទ្ធផលការងារ តាមរយៈថ្នាលបញ្ចាទិញតាមប្រព័ន្ធអ៊ីនធឺណិត ជាដើម។ ជាទូទៅ, បុគ្គលទាំងនេះមិនត្រូវបានចាត់ទុកជាកម្មករនិយោជិត និងមិនត្រូវបានចុះបញ្ជីជាសមាជិកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដើម្បីទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម ខណៈដែលការងាររបស់ពួកគាត់ប្រឈមនឹងហានិភ័យខ្ពស់។

ដើម្បីដោះស្រាយបញ្ហាប្រឈមនានា, រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាបន្តបន្ទាប់ ដើម្បីលើកស្ទួយកម្រិតជីវភាពរបស់អ្នកប្រកបមុខរបរ និងធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមរយៈវិធានការគន្លឹះមួយចំនួន ជាពិសេសការដាក់ចេញនូវ "ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ ឆ្នាំ២០២១-២០២៣", "យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨", និងគោលនយោបាយគាំពារសង្គមនានា ផងដែរ។ ទន្ទឹមនេះ, ក្នុងគោលបំណងពង្រីកការគ្របដណ្តប់របបសន្តិសុខសង្គម ប្រកបដោយសមធម៌ និងបរិយាបន្ន សំដៅលើកកម្ពស់សុខុមាលភាពរបស់កម្មករនិយោជិត និងធានាចីរភាពហិរញ្ញវត្ថុក្នុងប្រព័ន្ធសន្តិសុខសង្គម, ក្រុមប្រឹក្សាជាតិគាំពារសង្គមមានគោលដៅដាក់ចេញ "យន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម" ដើម្បីជំរុញ និងលើកទឹកចិត្តសហគ្រាស និងគ្រឹះស្ថាន និយោជក កម្មករនិយោជិត បុគ្គលស្វ័យនិយោជន៍ អ្នកក្នុងបន្ទុកសមាជិក ប.ស.ស. និងជាពិសេសក្រុមបុគ្គលប្រកបវិជ្ជាជីវៈសេរី ឬការងារបែបម៉ៅការ ឱ្យចុះបញ្ជីក្នុងបេឡាជាតិសន្តិសុខសង្គម។

# ៣

# ធាតុផ្សំនៃប្រព័ន្ធគាំពារសង្គមកម្ពុជា

ប្រព័ន្ធគាំពារសង្គមកម្ពុជា ផ្ដោតសំខាន់លើការគិតគូរអំពីហានិភ័យនៃវដ្ដជីវិត តាមដំណាក់កាលជាក់លាក់នីមួយៗ ដែលបង្ហាញថា បុគ្គលម្នាក់ៗប្រឈមនឹងហានិភ័យ និងភាពងាយរងគ្រោះខុសៗគ្នា ហើយប្រព័ន្ធគាំពារសង្គមត្រូវបានរៀបចំដើម្បីដោះស្រាយការគំរាមកំហែងដែលបង្កដោយហានិភ័យទាំងនេះ។





# ៣.១. មាតុភាព និងហានិភ័យកុមារភាព

## ៣.១.១. ស្ថានភាពទូទៅ

ការមានផ្ទៃពោះ និងការសម្រាលកូន បង្កហានិភ័យដល់ម្ដាយគ្រប់ៗរូប។ ដំណាក់កាលដំបូងនៃជីវិតរបស់ទារកក្នុងផ្ទៃផ្ដល់សម្ពាធយ៉ាងខ្លាំងលើឪពុកម្ដាយ ជាពិសេសម្ដាយ ក្នុងទិដ្ឋភាពចំនួន ២ រួមមាន៖ (១) សុខុមាលភាពផ្ទៃពោះ និងការសម្រាល និង (២) លទ្ធភាពរកប្រាក់ចំណូលសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ។ ការលើកកម្ពស់សុខុមាលភាពទាំងម្ដាយ និងទារក មានសារៈសំខាន់ក្នុងការចូលរួមដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារចាប់តាំងពីនៅក្នុងផ្ទៃ និងជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី ក្នុងរយៈពេល ១ ០០០ ថ្ងៃដំបូងនៃជីវិត។ បន្ថែមលើនេះ, ក្នុងអំឡុងមានផ្ទៃពោះ ស្ត្រីមានតម្រូវការមីក្រូសារជាតិខ្ពស់ និងប្រឈមហានិភ័យកង្វះមីក្រូសារជាតិ រួមទាំងកង្វះជាតិដែក ដែលជាមូលហេតុចម្បងដែលបង្កភាពស្លេកស្លាំង។ ភាពស្លេកស្លាំងធ្ងន់ធ្ងរអាចធ្វើឱ្យម្ដាយ និងទារកស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ដោយ ការកើនឡើងហានិភ័យនៃការបាត់បង់ឈាមក្នុងពេលសម្រាល និងការកើនឡើងហានិភ័យនៃកូនមិនគ្រប់ខែ និងកូនមានទំហំតូច ព្រមទាំងអត្រាមរណៈខ្ពស់ក្រោយសម្រាល។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការអន្តរាគមន៍គាំពារសង្គមមួយចំនួន រួមមាន៖

១. កម្មវិធីផ្ដល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិកជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ដោយផ្ដល់ប្រាក់ឧបត្ថម្ភ នៅពេលទៅពិនិត្យផ្ទៃពោះមុនសម្រាល ពេលសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ និងពេលពិនិត្យសុខភាពក្រោយសម្រាល និងយកកូនទៅចាក់ថ្នាំបង្ការរហូតដល់អាយុ ២ឆ្នាំ។ មន្ត្រីរាជការសាធារណៈ, មន្ត្រីកម្មសិក្សា, និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រី ក៏ទទួលបានអត្ថប្រយោជន៍ដូចគ្នាពីកម្មវិធីនេះផងដែរ នៅពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយពេលសម្រាល។

២. ប្រាក់បំណាច់មាតុភាព ដោយសមាជិក ប.ស.ស. ជាស្ត្រីនៃវិស័យឯកជន មានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% នៃប្រាក់ឈ្នួលជាប់ភាគទានមធ្យម សម្រាប់រយៈពេល ៩០ថ្ងៃនៃការឈប់សម្រាកមុន និងក្រោយពេលសម្រាល។ បន្ថែមលើនេះ ផ្អែកតាមច្បាប់ស្ដីពីការងារក្នុងពេលឈប់សម្រាកមាតុភាព, កម្មករនិយោជិតជាស្ត្រីមានសិទ្ធិទទួលបានប្រាក់ឈ្នួលពាក់កណ្ដាលគិតទាំងប្រាក់បន្ទាប់បន្សំផងដែរ ដែលផ្ដល់ដោយនិយោជក។

៣. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដែលជាកម្មវិធីជាតិជំនួយសង្គមដំបូងគេតាំងពីឆ្នាំ២០១៩ ដោយផ្ដល់សាច់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះមកពីគ្រួសារមានបណ្ណសមធម៌ ភ្ជាប់នឹងលក្ខខណ្ឌទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល នៅពេលសម្រាល និងពិនិត្យសុខភាពក្រោយពេលសម្រាល និងពេលយកកូនទៅទទួលថ្នាំបង្ការរហូតដល់កូនអាយុ២ឆ្នាំ។

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំនេះ បានរួមចំណែកលើកកម្ពស់អាហារូបត្ថម្ភទាំងសម្រាប់ស្ត្រីជាម្តាយ និងកុមារតូច ជាពិសេសបានជួយដល់ការលូតលាស់របស់កុមារទាំងកាយសម្បទា និងបញ្ញាស្មារតី រួមទាំងកាត់បន្ថយអត្រាមរណភាពផងដែរ។ លទ្ធផលនៃការវាយតម្លៃបង្ហាញថា កម្មវិធីនេះពិតជាបានលើកទឹកចិត្តឱ្យស្ត្រីមានផ្ទៃពោះស្វែងរកសេវាថែទាំសុខភាពត្រឹមត្រូវតាមនិយាមសុខាភិបាល និងបានផ្តល់ផលវិជ្ជមានជារួមដល់សុខភាពរបស់ម្តាយ និងកុមារ។

បន្ថែមលើការគាំពារម្តាយ និងកុមារអាយុក្រោម ២ឆ្នាំ, រាជរដ្ឋាភិបាលក៏បានផ្តល់ការគាំពារដល់កុមារនៅសាលារៀន ដើម្បីបន្តលើកកម្ពស់ការរីកលូតលាស់របស់កុមារ តាមរយៈកម្មវិធីចំនួន ២ គឺ៖ (១) កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ដែលជាកម្មវិធីជាតិជំនួយសង្គមមួយ ត្រូវបានដាក់ឱ្យដំណើរការចាប់តាំងពីឆ្នាំ២០១៩ ដោយផ្តល់អាហារក្តៅមានជីវជាតិដល់កុមារនៅតាមសាលាបឋមសិក្សាសាធារណៈ ក្នុងតំបន់ដែលមានបញ្ហាកង្វះអាហារូបត្ថម្ភ និងមានភាពងាយរងគ្រោះខ្ពស់ ក្នុងគោលដៅលើកកម្ពស់កម្រិតអាហារូបត្ថម្ភ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការរីកលូតលាស់របស់កុមារស្ថិតក្នុងវ័យកំពុងទទួលបានការអប់រំ។ មិនតែប៉ុណ្ណោះ កម្មវិធីនេះក៏បានចូលរួមលើកកម្ពស់សេដ្ឋកិច្ច និងសមធម៌យេនឌ័រនៅក្នុងសហគមន៍ ដោយសារការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងការជួយជំរុញឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ តាមរយៈការប្រើប្រាស់កសិផលនៅក្នុងសហគមន៍ទាំងស្រុង ដែលទទួលបានពីអ្នកផ្គត់ផ្គង់ និងកសិករដែលភាគច្រើនជាស្ត្រី និង (២) កម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សា ដោយផ្តល់ការឧបត្ថម្ភសាច់ប្រាក់ដល់កុមារដែលមកពីគ្រួសារក្រីក្រ ក្នុងគោលបំណងជំរុញការចុះឈ្មោះចូលរៀនឱ្យបានទាន់ពេល និងឈានដល់ការបញ្ចប់ការសិក្សាតាមកម្រិតនីមួយៗដោយជោគជ័យ។ ទោះយ៉ាងណា, កម្រិតប្រាក់ឧបត្ថម្ភ និងវិសាលភាពគ្របដណ្តប់នៅតែជាបញ្ហាប្រឈមសំខាន់សម្រាប់កម្មវិធីទាំង ២ នេះ នៅឡើយ។

ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់, សូចនាករនៃការអភិវឌ្ឍរបស់កុមារកម្ពុជានៅតែជាក្តីកង្វល់។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ផ្តល់ការគាំពារដល់កុមារពីក្នុងផ្ទៃ រហូតដល់អាយុ ២ឆ្នាំ ខណៈដែលកម្មវិធីផ្តល់អាហារតាមសាលារៀន និងកម្មវិធីអាហារូបករណ៍ផ្តល់ការគាំពារដល់កុមារ ពីអាយុចូលរៀនបឋមសិក្សា ដែលជាទូទៅចាប់ពីអាយុ ៦ឆ្នាំ រហូតដល់ចប់មធ្យមសិក្សា។ ការណ៍នេះបង្ហាញឱ្យឃើញពីភាពខ្វះចន្លោះនៃការគ្របដណ្តប់របស់កម្មវិធីគាំពារសង្គម លើកុមារដែលមានអាយុពី២ឆ្នាំ ដល់ ៥ឆ្នាំ ដែលជាវ័យកំពុងលូតលាស់ និងត្រូវការជាចាំបាច់នូវការគាំពារ។ មិនតែប៉ុណ្ណោះ យោងតាមទិន្នន័យអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ២០២១-២០២២, កុមារជាច្រើនមិនបានទទួលអាហារូបត្ថម្ភគ្រប់គ្រាន់ ដោយក្នុងនោះ ៣២% ជួបបញ្ហាក្រិសក្រិន, ២៤% មិនគ្រប់ទម្ងន់ និង ១០% នៃកុមារដែលមានអាយុក្រោម ៥ឆ្នាំ ជួបប្រទះបញ្ហាស្គមស្គាំង។ មួយវិញទៀត, មូលហេតុចម្បងនៃការបោះបង់ការសិក្សា គឺបញ្ហាកម្លាំងពលកម្ម និងដើម្បីជួយធ្វើការងារផ្ទះ។

### ៣.១.២. វិធានការគោលនយោបាយ

ការគាំពារម្តាយ និងកុមារមានភាពចាំបាច់ ដើម្បីធានាថាកុមារគ្រប់រូបមានឱកាសទទួលបានការអភិវឌ្ឍទាំងផ្លូវកាយ បញ្ញា និងស្មារតី តាមរយៈការបរិភោគអាហារដែលមានអាហារូបត្ថម្ភគ្រប់គ្រាន់ ទន្ទឹមនឹងការទទួលបានការអប់រំប្រកបដោយសមធម៌ ដែលនឹងបង្កើតឱកាសកាន់តែច្រើនក្នុងការទទួលបានការងារធ្វើ និងប្រាក់ចំណូលសមរម្យ ពោលគឺចៀសផុតពីភាពក្រីក្រ។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងបន្តពង្រឹងយន្តការក្នុងការផ្តល់អត្ថប្រយោជន៍ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីនៃគ្រួសារមានបណ្ណសមធម៌, កម្មករនិយោជិតជាស្ត្រី, និងមន្ត្រីក្នុងវិស័យជាសាធារណៈជាស្ត្រី ក្នុងអំឡុងមានផ្ទៃពោះរហូតដល់កូនអាយុ ២ឆ្នាំ ដើម្បីធានាបាននូវការមកទទួលយកសេវាថែទាំទាំងមុន និងក្រោយពេលសម្រាល ព្រមទាំងការសម្រាលកូននៅតាមមូលដ្ឋានសុខាភិបាល ដែលមានវិជ្ជាជីវៈ ក្នុងគោលដៅធានាឱ្យបាននូវសុវត្ថិភាព និងសុខភាពសម្រាប់ម្តាយ និងទារក។ លើសពីនេះ, រាជរដ្ឋាភិបាលនឹងគិតគូរបន្ថែមផងដែរ ដល់ការគ្របដណ្តប់កុមារពីអាយុពី ២ឆ្នាំ ដល់ ៥ឆ្នាំ និងក្រុមគោលដៅផ្សេងទៀត ទៅតាមលទ្ធភាពទ្រទ្រង់បាននៃថវិកា ព្រមទាំងគិតគូរដាក់បញ្ចូលកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ទៅក្នុងរបបសន្តិសុខសង្គម ដែលប្រើប្រាស់ថវិកាភាគទាន។

សម្រាប់កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ រាជរដ្ឋាភិបាលបានប្តេជ្ញាទទួលយកសាលារៀនគោលដៅទាំងអស់បណ្តើរៗ ពីការគ្រប់គ្រងរបស់កម្មវិធីស្បៀងអាហារពិភពលោក ត្រឹមឆ្នាំ២០២៨ និងអនុវត្ត "គោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនឆ្នាំ ២០២៤-២០៣៥" ដែលរាជរដ្ឋាភិបាលទើបនឹងដាក់ចេញ ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័ន និងយន្តការអនុវត្តកម្មវិធី ព្រមទាំងសិក្សាអំពីលទ្ធភាពក្នុងការគ្របដណ្តប់សាលារៀនគោលដៅផ្សេងទៀតជាពិសេសសម្រាប់ថ្នាក់មត្តេយ្យសិក្សា និងមធ្យមសិក្សា ក្នុងរយៈពេលវែង។ ដោយកម្មវិធីអាហារូបករណ៍ត្រូវបានធ្វើសមាហរណកម្មទៅក្រោមកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ, រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពកែសម្រួលកម្រិតប្រាក់ឧបត្ថម្ភ និងពង្រីកការគ្របដណ្តប់ជាជំហានៗ ផងដែរ។

ការរៀបចំ និងការអនុវត្តកម្មវិធីជាតិជំនួយសង្គម ឬរបបសន្តិសុខសង្គមសម្រាប់ឆ្លើយតបនឹងមាតុភាព និងហានិភ័យកុមារភាព ត្រូវគិតគូរអំពីទិដ្ឋភាពពាក់ព័ន្ធឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីលើកកម្ពស់ការឆ្លើយតបនឹងយេនឌ័រ និងបរិយាបន្ន។

## ៣.២. ហានិភ័យសុខភាព

### ៣.២.១. ស្ថានភាពទូទៅ

មូលនិធិសមធម៌សុខាភិបាល ត្រូវបានចាប់ផ្តើមអនុវត្តសាកល្បងនៅខេត្តសៀមរាប និងខេត្តតាកែវ កាលពីឆ្នាំ២០០០ និងត្រូវបានពង្រីកជាបន្តបន្ទាប់រហូតគ្របដណ្តប់មូលដ្ឋានសុខាភិបាលសាធារណៈទូទាំងប្រទេស ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ កាលពីឆ្នាំ២០១៥។ កាលពីឆ្នាំ២០១៨, រាជរដ្ឋាភិបាលបានពង្រីកវិសាលភាពកម្មវិធីនេះ ដល់ក្រុមពលរដ្ឋគោលដៅជាទៀត រួមមានកម្មករក្រៅប្រព័ន្ធ, អ្នកជាក់ស៊ីក្លូ, កីឡាករ-កីឡាការិនី, មេភូមិ, អនុភូមិ, សមាជិកភូមិ, ក្រុមប្រឹក្សាឃុំ សង្កាត់, បុគ្គលិក និងអ្នកជំនាញដោះមីន និងអ្នករស់នៅជាមួយមេរោគអេដស៍។ ជាមួយគ្នានេះ, កាលពីឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានពង្រីកវិសាលភាពនៃមូលនិធិសមធម៌សុខាភិបាល ដល់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសស្ត្រីបម្រើការតាមរង្គសាល ឌីស្កូតែក ខារ៉ាអូខេ បៀរហ្គាឌិន កន្លែងម៉ាស្សា។ បន្ថែមលើនេះ ក្នុងឆ្នាំ២០២៣, រាជរដ្ឋាភិបាលក៏បានសម្រេចពង្រីកវិសាលភាពមូលនិធិសមធម៌សុខាភិបាលដល់គ្រួសារងាយរងហានិភ័យផងដែរ។ ជារួម គិតត្រឹមខែសីហា ឆ្នាំ២០២៤, មូលនិធិសមធម៌សុខាភិបាល បាន និងកំពុងគ្របដណ្តប់ពលរដ្ឋក្រីក្រ ពលរដ្ឋងាយរងហានិភ័យ និងក្រុមពលរដ្ឋគោលដៅជាទៀតសរុបចំនួនប្រមាណជាង ៤,៧ លាននាក់។

ជាមួយគ្នានេះ, រាជរដ្ឋាភិបាលក៏បានដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត នៅឆ្នាំ២០១៦, សម្រាប់មន្ត្រីសាធារណៈនៅឆ្នាំ២០១៨ និងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. កាលពីចុងឆ្នាំ២០២៣ ដោយមានបេឡាជាតិសន្តិសុខសង្គមជាប្រតិបត្តិករ។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៣, របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព បានគ្របដណ្តប់កម្មករនិយោជិត មន្ត្រីសាធារណៈ និងបុគ្គលស្វ័យនិយោជន៍ សរុបចំនួនប្រមាណជាង ២,១ លាននាក់។ ជារួម, ប្រព័ន្ធគាំពារសុខភាពសង្គម បាន និងកំពុងគ្របដណ្តប់ពលរដ្ឋសរុបចំនួនប្រមាណជាង ៧ លាននាក់ ឬស្មើប្រមាណ ៤១% នៃពលរដ្ឋសរុប។

តាមរយៈការវិនិយោគ និងនវានុវត្តន៍ចម្បងៗក្នុងវិស័យសុខាភិបាល ក្នុងរយៈពេលជាង ២ទសវត្សរ៍កន្លងមកនេះ, ការអភិវឌ្ឍប្រព័ន្ធសុខាភិបាលនៅកម្ពុជាបានបោះជំហានប្រកបដោយវឌ្ឍនភាព ជាមួយនឹងការកើនឡើងនៃការប្រើប្រាស់សេវាថែទាំ និងព្យាបាល ដែលធ្វើឱ្យសុខភាពរបស់ពលរដ្ឋកាន់តែប្រសើរជាលំដាប់។ សូចនាករមួយចំនួនបានឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវវឌ្ឍនភាពនេះ រួមមាន៖ (១) កម្រិតសន្ទស្សន៍នៃការគ្របដណ្តប់ដោយសេវាសុខាភិបាលសាវន្តក្នុងឆ្នាំ២០២១ មានអត្រាជាមធ្យម ៥៨% ដែលក្នុងនោះ សន្ទស្សន៍នៃការគ្របដណ្តប់សេវាសុខភាពបន្តពូជ, មាតា, ទារក, និងកុមារមានអត្រា ៧៤%, សេវាជំងឺឆ្លង ៦៥%, សេវាជំងឺមិនឆ្លង ៦៤%, សមត្ថភាព និងការទទួលបានសេវា ៣៧%, (២) ការថយចុះទំហំចំណាយពីហោប៉ៅផ្ទាល់របស់ពលរដ្ឋលើការថែទាំសុខភាពមកត្រឹម ៦០% ក្នុងឆ្នាំ២០២០, (៣) ការកើនឡើងជាលំដាប់នៃអាយុរំពឹងរស់របស់ពលរដ្ឋ, និង (៤) ការធ្លាក់ចុះអត្រាមរណភាពមាតា ទារក និងកុមារ ជាដើម។

ទោះយ៉ាងនេះក្ដី, ចំណាយពីហោប៉ៅផ្ទាល់របស់ពលរដ្ឋលើការថែទាំសុខភាពនៅកម្ពុជានៅមានកម្រិតខ្ពស់នៅឡើយ ពោលគឺមានចំនួនប្រមាណ ៦០% ដែលជាអត្រាមួយខ្ពស់ជាងបណ្ដាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ការណ៍នេះបង្ហាញថា ពលរដ្ឋកម្ពុជាភាគច្រើននៅតែប្រឈមនឹងហានិភ័យហិរញ្ញវត្ថុក្នុងកម្រិតមួយខ្ពស់ ជាពិសេសពលរដ្ឋដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ ដែលងាយនឹងធ្លាក់ខ្លួនចូលក្នុងភាពក្រីក្រវិញ ក្នុងករណីសមាជិកគ្រួសារណាម្នាក់ធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ។

## ៣.២.២. វិធានការគោលនយោបាយ

ជាមួយនឹងវឌ្ឍនភាពទាំងនេះ ព្រមទាំងការវិភាគស៊ីជម្រៅលើបញ្ហាប្រឈមបច្ចុប្បន្ន និងទស្សនវិស័យអនាគត, រាជរដ្ឋាភិបាលពិនិត្យឃើញយ៉ាងច្បាស់នូវភាពចាំបាច់ក្នុងការបន្តជំរុញល្បឿននៃដំណើរឆ្ពោះទៅការគ្របដណ្ដប់សុខភាពជាសកលនៅកម្ពុជា ដែលទាមទារនូវការគិតគូរវែងឆ្ងាយ ល្អិតល្អន់និងគ្រប់ជ្រុងជ្រោយ។ ផ្អែកលើបរិការណ៍នេះ, "ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្ដប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ២០២៤-២០៣៥" ត្រូវបានរៀបចំ និងបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ផែនទីបង្ហាញផ្លូវនេះ កំណត់ដំណើរជាយុទ្ធសាស្ត្រឆ្ពោះទៅការគ្របដណ្ដប់សុខភាពជាសកលនៅកម្ពុជា ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០៣៥ ដោយដាក់ចេញនូវជម្រើសគោលនយោបាយអាទិភាពសម្រាប់ការកែទម្រង់ស៊ីជម្រៅ តាមដំណាក់កាល ក្នុងទិដ្ឋភាពពហុវិស័យ និងពហុវិមាត្រ តាមរយៈការអភិវឌ្ឍប្រព័ន្ធគាំពារសុខភាពសង្គម និងការពង្រឹងសមត្ថភាពក្នុងការផ្ដល់សេវាសុខាភិបាលទាំងសាធារណៈ និងឯកជន សំដៅកាត់បន្ថយឱ្យបានជាអតិបរមានូវទំហំនៃចំណាយពីហោប៉ៅផ្ទាល់លើការថែទាំសុខភាព និងពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់វិស័យសុខាភិបាល។ ផែនទីបង្ហាញផ្លូវនេះក៏បានកំណត់គោលដៅជាក់លាក់ចំនួន ៣ គឺ៖ (១) ការពង្រីកវិសាលភាពនៃការគ្របដណ្ដប់ពលរដ្ឋដោយប្រព័ន្ធគាំពារសុខភាពសង្គមឱ្យបាន ៨០% នៃចំនួនពលរដ្ឋសរុប, (២) ការកំណត់សន្ទស្សន៍នៃការគ្របដណ្ដប់សេវាសុខាភិបាលសារវន្តឱ្យបានយ៉ាងហោច ៨០%, និង (៣) ការកាត់បន្ថយទំហំចំណាយពីហោប៉ៅផ្ទាល់លើការថែទាំសុខភាពឱ្យនៅយ៉ាងច្រើនត្រឹម ៣៥% នៃចំណាយសរុបលើវិស័យសុខាភិបាល។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងផ្ដោតលើការអនុវត្តទិសដៅគោលនយោបាយ ដែលកំណត់ក្នុងផែនទីបង្ហាញផ្លូវនេះ ក្នុងគោលដៅជំរុញឱ្យការគ្របដណ្ដប់សុខភាពជាសកល ក្លាយជាការពិតសម្រាប់ពលរដ្ឋកម្ពុជា។



## ៣.៣. ហានិភ័យការងារ

### ៣.៣.១. ស្ថានភាពទូទៅ

របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ដែលត្រូវបានដាក់ឱ្យអនុវត្តពេញលេញសម្រាប់វិស័យសាធារណៈ និងសម្រាប់បុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ បាន និងកំពុងផ្តល់ការគាំពារផ្នែកហិរញ្ញវត្ថុដល់មន្ត្រីសាធារណៈ និងកម្មករនិយោជិតនៅពេលគ្រោះថ្នាក់កើតឡើងនៅទីតាំងបំពេញការងារផ្ទាល់, ការធ្វើដំណើរទៅ និងត្រឡប់មកពីទីតាំងបំពេញការងារ, និងជំងឺវិជ្ជាជីវៈ។ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារនេះ ផ្តល់នូវ៖ (១) ការព្យាបាល និងការថែទាំវេជ្ជសាស្ត្រ, (២) ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន, (៣) ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍, (៤) វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍, (៥) ធនលាភឧត្តរជីវី, (៦) វិភាជន៍បូជាសព, និង (៧) សេវាស្តារនីតិសម្បទា។

### ៣.៣.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលនឹងបន្តជំរុញការពង្រឹងគុណភាពសេវាព្យាបាល និងការស្តារនីតិសម្បទា។ ប.ស.ស. ត្រូវសហការជាមួយមូលនិធិជនពិការ (ម.ជ.ព.) ធ្វើការសិក្សាអំពីលទ្ធភាពក្នុងការជំរុញការប្រើប្រាស់សេវាស្តារនីតិសម្បទារបស់មជ្ឈមណ្ឌលរដ្ឋឱ្យបានជាអតិបរមា។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏នឹងបន្តពិនិត្យឡើងវិញនូវកញ្ចប់អត្ថប្រយោជន៍នៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ឱ្យស្របទៅនឹងកម្រិតភាគទាន ដែលបានបង់ដោយនិយោជក ក៏ដូចជាសិក្សាអំពីលទ្ធភាពក្នុងការពង្រីកវិសាលភាពនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ទៅបុគ្គលស្វ័យនិយោជន៍ ដូចបណ្តាប្រទេសមួយចំនួនក្នុងតំបន់។

## ៣.៤. ពិការភាព

### ៣.៤.១. ស្ថានភាពទូទៅ

ទិន្នន័យអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា ឆ្នាំ២០២១-២០២២ បង្ហាញថាពលរដ្ឋកម្ពុជាអាយុចាប់ពី៥ឆ្នាំឡើង ប្រមាណ ៤,២% មានពិការភាពធ្ងន់ធ្ងរ។ ជនមានពិការភាព តែងតែជួបឧបសគ្គក្នុងការចូលរួមពេញលេញក្នុងវិស័យការងារ ដែលក្នុងនោះ ស្ត្រីមានពិការភាពចំនួន ៥២% មានការងារធ្វើបើធៀបនឹងស្ត្រីដែលគ្មានពិការភាពមានការងារធ្វើរហូតដល់ ៨៦%។ ជនមានពិការភាពជាច្រើនបាន និងកំពុងប្រកបរបរដោយខ្លួនឯង (ស្វ័យនិយោជន៍) ឬបំពេញការងារក្នុងគ្រួសារដែលមិនមានកម្រៃ។ ភាពទន់ខ្សោយនៃអវយវៈណាមួយនៃរាងកាយ រួមផ្សំនឹងកង្វះឱកាសក្នុងការចូលរួមក្នុងសង្គមជារបាំងដែលបណ្តាលឱ្យជនមានពិការភាពពុំបានទទួលការងារដែលមានបៀវត្សរ៍សមរម្យ។ លើសពីនេះ, វត្តមានរបស់ជនមានពិការភាពនៅក្នុងគ្រួសារ ក៏អាចកម្រិតការចូលរួមរបស់សមាជិកផ្សេងទៀតទៅក្នុងទីផ្សារការងារ ដោយពួកគាត់អាចនឹងត្រូវបោះបង់ការងារដើម្បីផ្តល់ការថែទាំដល់ជនមានពិការភាព ដែលនេះអាចបណ្តាលឱ្យគ្រួសាររបស់ពួកគាត់បាត់បង់ចំណូលមួយផ្នែក។ ពិការភាពក៏ជាកត្តាសំខាន់ដែលបណ្តាលឱ្យគ្រួសាររបស់ពួកគាត់ប្រឈមនឹងហានិភ័យដទៃផ្សេងទៀតក្នុងផ្នែកនីមួយៗនៃវដ្តជីវិត។ ទន្ទឹមនេះ, ជនមានពិការភាពជួបប្រទះនឹងចំណាយខ្ពស់ជាងពលរដ្ឋទូទៅលើចំណាយមួយចំនួន ដូចជាចំណាយលើការថែទាំសុខភាព, ការស្តារនីតិសម្បទា, ការអប់រំ, និងការធ្វើដំណើរ។ រីឯចំណាយខ្ពស់ក្នុងការទទួលបានការអប់រំក៏រួមចំណែកដល់ការធ្វើឱ្យកុមារមានពិការភាព អាយុចាប់ពី ៦ឆ្នាំ ទៅ ១៧ឆ្នាំ ត្រឹមតែ ៤៨% ប៉ុណ្ណោះបានចូលរៀន បើធៀបនឹងកុមារដែលមិនមានពិការភាពមានចំនួនរហូតដល់ ៨៦%។ ជារួម, ជនមានពិការភាពមានបន្ទុកទ្វេដង ដោយសារចំណាយខ្ពស់ ប៉ុន្តែប្រាក់ចំណូលដែលទទួលបានមានកម្រិតទាប។

រាជរដ្ឋាភិបាលបានផ្តល់ការឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាពមកពីគ្រួសារក្រីក្រ និងងាយរងគ្រោះ ចំនួនសរុបប្រមាណ ១៧ ០០០ នាក់ តាមរយៈរបបគោលនយោបាយជូនជនមានពិការភាពក្រីក្រនៅតាមសហគមន៍។ ទោះជាយ៉ាងណា, ប្រាក់ឧបត្ថម្ភ និងវិសាលភាពនៃកម្មវិធីនេះនៅមានកម្រិតនៅឡើយ ដែលចាំបាច់ត្រូវធ្វើការកែសម្រួល។ ក្នុងន័យនេះ ក្នុងឆ្នាំ២០២៤ រាជរដ្ឋាភិបាលសម្រេចកែសម្រួលកម្មវិធីនេះទៅជា "កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព" ដោយធ្វើសមាហរណកម្មទៅក្រោមកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលបានពង្រីកវិសាលភាពឱ្យគ្របដណ្តប់ទូទាំងប្រទេស ព្រមទាំងបានដំឡើងកម្រិតអត្ថប្រយោជន៍ផងដែរ។ ចំណែកមន្ត្រីសាធារណៈ, កងកម្លាំងប្រដាប់អាវុធ, និងកម្មករនិយោជិត ដែលមានពិការភាព ក៏បាន និងកំពុងទទួលបានការគាំពារទៅតាមស្ថានភាពជាក់ស្តែងនៅក្រោមយន្តការនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកប្រាក់សោធន។ ទន្ទឹមនេះ, រាជរដ្ឋាភិបាល តាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ឱ្យដំណើរការយន្តការកំណត់អត្តសញ្ញាណពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ដែលជាយន្តការថ្នាក់ជាតិក្នុងការកំណត់អត្តសញ្ញាណជនមានពិការភាព ដើម្បីទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម និងសេវាសង្គមកិច្ច ព្រមទាំងប្រមូល និងចងក្រងទិន្នន័យពិការភាពនៅកម្ពុជា ដែលមានបទដ្ឋានរួម។

### ៣.៤.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលនឹងបន្តពង្រឹងយន្តការកំណត់អត្តសញ្ញាណពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋានក្នុងគោលដៅកំណត់អត្តសញ្ញាណជនមានពិការភាពឱ្យបានគ្រប់ជ្រុងជ្រោយនៅទូទាំងប្រទេស។ ប្រព័ន្ធនេះនឹងផ្តល់ទិន្នន័យគោលស្តីពីពិការភាព សម្រាប់ជាមូលដ្ឋានក្នុងការគិតគូរគោលនយោបាយគាំពារសង្គម និងសង្គមកិច្ចផ្សេងទៀតទៅតាមតម្រូវការជាក់ស្តែង និងទៅតាមវិស័យរៀងៗខ្លួន។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលនឹង (១) ពង្រឹងយន្តការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាពក្រីក្រ ដែលបានធ្វើសមាហរណកម្មទៅក្រោមកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដើម្បីធានាថាក្រុមគោលដៅនេះទទួលបានការឧបត្ថម្ភពីរាជរដ្ឋាភិបាលពិតប្រាកដ, (២) បន្តពង្រឹងយន្តការគាំពារពាក់ព័ន្ធនឹងពិការភាពក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកប្រាក់សោធនសម្រាប់មន្ត្រីសាធារណៈ កងកម្លាំងប្រដាប់អាវុធ និងកម្មករនិយោជិត ដែលត្រូវផ្តោតសំខាន់លើការស្តារនីតិសម្បទា, និង (៣) ពិនិត្យលទ្ធភាពក្នុងការគិតគូរផ្តល់ការគាំពារដល់ជនមានពិការភាពដែលជាសមាជិកនៃគ្រួសារងាយរងហានិភ័យ ទៅតាមលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ។



## ៣.៥. និកម្មភាព

### ៣.៥.១. ស្ថានភាពទូទៅ

របបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ ត្រូវបានចែងក្នុងច្បាប់ស្ដីពីរបបសន្តិសុខសង្គម ដែលបានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីឆ្នាំ២០១៩ ប៉ុន្តែមិនទាន់ត្រូវបានដាក់ឱ្យអនុវត្តនៅឡើយ។ រាជរដ្ឋាភិបាលមិនទាន់ដាក់ឱ្យដំណើរការរបបនេះ ដោយសារអត្រានិកម្មភាពនៅកម្ពុជាមានកម្រិតទាបនៅឡើយ ពោលគឺមានត្រឹមតែចំនួនប្រមាណ ១% ប៉ុណ្ណោះ បើយោងតាមទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០២១។ ទោះជាយ៉ាងនោះក្តី, រាជរដ្ឋាភិបាលក៏បានមើលឃើញអំពីភាពខ្វះខាតនៃកម្រិតជំនាញវិជ្ជាជីវៈរបស់ពលរដ្ឋ ជាពិសេសយុវជននៃគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដែលផ្តល់កម្មវិបាកអវិជ្ជមានក្នុងការទទួលបានការងារ និងប្រាក់ចំណូលសមរម្យ។ កង្វះធនធាន និងកង្វះការគាំទ្រពាក់ព័ន្ធក៏ជាកត្តាចម្បងដែលបង្ខំឱ្យយុវជនមួយចំនួនបោះបង់ការសិក្សាទៅចាប់យកការងារដែលមានចំណូលទាប ដើម្បីចូលរួមផ្គត់ផ្គង់ជីវភាពគ្រួសារ។ ដោយពិនិត្យឃើញស្ថានភាពនេះ, រាជរដ្ឋាភិបាលបានដាក់ចេញកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដោយផ្តល់ជូននូវការបណ្តុះបណ្តាលជំនាញដោយឥតគិតថ្លៃ និងផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែក្នុងពេលទទួលការបណ្តុះបណ្តាល ព្រមទាំងផ្សារភ្ជាប់យុវជនដែលទទួលបានការបណ្តុះបណ្តាល ជាមួយនិយោជក ដើម្បីទទួលឱកាសការងារក្នុងការបង្កើនប្រាក់ចំណូល និងជីវភាពរស់នៅ ផងដែរ។

ទន្ទឹមនេះ, ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានពង្រីកវិសាលភាពនៃកម្មវិធីសាច់ប្រាក់ពលកម្ម ដើម្បីកាត់បន្ថយកម្មវិបាកអវិជ្ជមានលើសេដ្ឋកិច្ចគ្រួសារ ដោយកម្មវិធីនេះបានផ្តល់ឱកាសការងាររយៈពេលខ្លី និងបណ្តោះអាសន្នដល់គ្រួសារក្រីក្រ ដែលបាត់បង់ការងារភ្លាមៗ និងគ្រួសារដែលវិលត្រឡប់ពីចំណាកស្រុក។ បន្ថែមលើនេះ, កម្មវិធីនេះក៏បានចូលរួមចំណែកស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈខ្នាតតូចនៅទីជនបទផងដែរ ជាពិសេសការកសាងប្រព័ន្ធធារាសាស្ត្រដែលត្រូវបានកំណត់ជាគោលដៅអាទិភាព។

### ៣.៥.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលនឹងបន្តកសាងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន ដើម្បីត្រៀមខ្លួនសម្រាប់ការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ នៅពេលសមស្របណាមួយខាងមុខ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈដល់យុវជននៃគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ តាមរយៈការពង្រឹងយន្តការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដោយរៀបចំយន្តការ និងវគ្គបណ្តុះបណ្តាលបន្ថែម ដែលមានភាពសមស្រប និងភាពទាក់ទាញ សម្រាប់យុវជនគោលដៅ ពិសេសជនមានពិការភាព និងស្ត្រី។

រាជរដ្ឋាភិបាលក៏នឹងពិនិត្យលទ្ធភាពដាក់ឱ្យដំណើរការ"កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ" ដោយផ្អែកលើលទ្ធផលនៃគម្រោងសាកល្បងដែលបានដាក់ឱ្យដំណើរការក្រោមកិច្ចសហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏នឹងជំរុញការធ្វើស្ថាប័ននូបនីយកម្ម"កម្មវិធីសាច់ប្រាក់ពលកម្ម" ឱ្យទៅជាយន្តការក្រោមកិច្ចសម្របសម្រួលរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

ក្នុងរយៈពេលមធ្យម, រាជរដ្ឋាភិបាលក៏នឹងសិក្សាផងដែរអំពីលទ្ធភាពក្នុងការដាក់ឱ្យដំណើរការកម្មវិធីផ្តល់ឥណទានសម្រាប់ការសិក្សាថ្នាក់ឧត្តមសិក្សា ដល់និស្សិតដែលមានបំណងចូលរៀន ប៉ុន្តែមិនមានធនធានគ្រប់គ្រាន់សម្រាប់ការរៀនសូត្របានចប់ចុងចប់ដើម។ កម្មវិធីនេះមានគោលបំណងលើកទឹកចិត្តយុវជនដែលមានបំណងចង់បន្តការសិក្សាតាមសមត្ថភាពជំនាញរៀងៗខ្លួន។



## ៣.៦. ភាពគ្មានជម្រក

### ៣.៦.១. ស្ថានភាពទូទៅ

ការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងគម្លាតនៃការអភិវឌ្ឍរវាងទីក្រុង និងជនបទ បានជំរុញឱ្យពលរដ្ឋកម្ពុជាធ្វើការផ្លាស់ទីលំនៅទៅកាន់តំបន់ដែលមានការអភិវឌ្ឍខ្ពស់ជាង ដើម្បីស្វែងរកឱកាសការងារ និងការសិក្សា។ ការណ៍នេះ បានធ្វើឱ្យពលរដ្ឋទាំងនោះ ជាពិសេសពលរដ្ឋដែលមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ប្រឈមនឹងបញ្ហានៃការរកជម្រកសមរម្យដើម្បីស្នាក់អាស្រ័យ ដែលជាឧបសគ្គមួយនាំឱ្យមានការបោះបង់ការសិក្សាទៀតផង។ ទន្ទឹមនេះ, ពលរដ្ឋដែលមានចំណូលទាបក៏កំពុងប្រឈមនឹងបញ្ហានៃការទទួលបានលំនៅឋានសមរម្យផ្ទាល់ខ្លួនផងដែរ ដោយសារថ្លៃផ្ទះសម្បែងមានការកើនឡើងជាគំហុកជាពិសេសក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។កន្លងមក,រាជរដ្ឋាភិបាលបានដាក់ចេញនូវគម្រោង "លំនៅឋានតម្លៃសមរម្យ - Affordable Housing" ប៉ុន្តែគំនិតផ្តួចផ្តើមនេះ មិនទាន់មានវិសាលភាពទូលំទូលាយ និងមិនទាន់ត្រូវបានចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធគាំពារសង្គមនៅឡើយ។

### ៣.៦.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលបាន និងកំពុងផ្តល់ការយកចិត្តទុកដាក់ដល់ក្រុមពលរដ្ឋគោលដៅមួយចំនួនតាមរយៈអន្តរាគមន៍ ដែលរួមមានការគិតគូរពីការឧបត្ថម្ភឈ្នួលផ្ទះ, ការបញ្ចុះថ្លៃទឹកស្អាត និងថ្លៃអគ្គិសនីឱ្យនៅក្នុងអត្រាទាប ជាពិសេសសម្រាប់កម្មករនិយោជិតរោងចក្រដែលជួលបន្ទប់ស្នាក់នៅជាដើម។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពក្នុងការផ្តល់ការគាំទ្រផ្នែកលំនៅឋាន តាមរយៈយន្តការគាំពារសង្គម ដោយធ្វើការសិក្សាសមិទ្ធិលទ្ធភាព ក្នុងការរៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ទ្រទ្រង់ចំណាយជួលផ្ទះបន្ទប់ស្នាក់នៅជូនដល់សិស្សនិងនិស្សិតដែលមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យដោយអាចចាប់ផ្តើមសាកល្បងនៅតំបន់ទីប្រជុំជនមួយចំនួន មុននឹងពង្រីកវិសាលភាពទៅទូទាំងប្រទេស។ ទន្ទឹមនេះ, រាជរដ្ឋាភិបាល ក៏នឹងធ្វើការសិក្សាសមិទ្ធិលទ្ធភាពក្នុងការដាក់ឱ្យដំណើរការកម្មវិធី "លំនៅឋានតម្លៃសមរម្យ" ក្នុងគោលបំណង ផ្តល់លទ្ធភាពជូនពលរដ្ឋដែលមានចំណូលទាប និងជនងាយរងគ្រោះរួមទាំងអ្នកទទួលផលក្រោមកម្មវិធីជាតិជំនួយសង្គម ដើម្បីទទួលបានផ្ទះសម្បែងរស់នៅសមរម្យ សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលក៏នឹងសិក្សាសមិទ្ធិលទ្ធភាពក្នុងការផ្តល់ការគាំទ្រសម្រាប់ជួយសម្រួលដល់ក្រុមជនងាយរងគ្រោះដែលកំពុងស្នាក់នៅតាមទីវត្តអារាម និងទីកន្លែងសាសនាដទៃទៀត ផងដែរ។

## ៣.៧. ជរាភាព និងឧត្តរជីវី

### ៣.៧.១. ស្ថានភាពទូទៅ

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ បានបង្ហាញថា ចំនួនពលរដ្ឋដែលមានអាយុ៦០ឆ្នាំឡើង នឹងមានការកើនទ្វេដងពី ៧,៦% ក្នុងឆ្នាំ២០២០ ទៅ ១៦,៤% ក្នុងឆ្នាំ២០៥០។ ការកើនឡើងនៃពលរដ្ឋវ័យចាស់បង្ហាញពីតម្រូវការកាន់តែខ្លាំងក្នុងការកសាងប្រព័ន្ធគាំពារសង្គមដែលរឹងមាំ និងមានចីរភាពដើម្បីជួយការពារពលរដ្ឋឱ្យចៀសផុតពីការធ្លាក់ចូលក្នុងភាពក្រីក្រនៅពេលឈានចូលវ័យចាស់ជរា។ ការស្រាវជ្រាវចុងក្រោយ ក្នុងឆ្នាំ២០២១ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរកឃើញថាមនុស្សវ័យចាស់ប្រមាណ ៧៣% រស់នៅដោយពឹងផ្អែកលើការជួយឧបត្ថម្ភពីក្រុមគ្រួសារ។ កត្តានេះបង្ហាញថា ពលរដ្ឋចាស់ជរាមួយចំនួនធំ ស្ថិតនៅក្នុងស្ថានភាពអសន្តិសុខប្រាក់ចំណូលនៅឡើយ។

ជាសារបាន ប្រព័ន្ធសោធននៅកម្ពុជាបានចាប់ផ្តើមក្នុងទម្រង់ដាច់ៗពីគ្នា ទៅតាមប្រភេទនៃពលរដ្ឋគោលដៅ។ របបប្រាក់សោធនសម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ត្រូវបានគ្រប់គ្រង និងចាត់ចែងដោយស្ថាប័នដោយឡែក គឺបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) និងបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ.) ដែលកាលពីឆ្នាំ២០២២ ត្រូវបានធ្វើសមាហរណកម្មឱ្យស្ថិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ស្ថាប័នថ្មីមួយគឺ "មូលនិធិជាតិជំនួយសង្គម"។ បច្ចុប្បន្ន, របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់មន្ត្រីសាធារណៈទាំងនេះ កំពុងត្រូវបានរ៉ាប់រងទាំងស្រុងដោយថវិកាជាតិ ដែលមាននិន្នាការកើនឡើងជាបន្តបន្ទាប់ និងអាចប៉ះពាល់ដល់ចីរភាពថវិកាជាតិ និងម៉ាក្រូសេដ្ឋកិច្ចជាតិ ក្នុងរយៈពេលវែង។ ចំណែករបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិត ដែលទើបត្រូវបានដាក់ឱ្យដំណើរការនៅចុងឆ្នាំ២០២២ ស្ថិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ ប.ស.ស. ដែលទ្រទ្រង់ដោយថវិកាភាគទានតាមរយៈការចូលរួមបង់ដោយនិយោជក និងកម្មករនិយោជិត។

ដោយឡែក, ជនចាស់ជរាដែលស្ថិតក្នុងគ្រួសារមានបណ្ណសមធម៌ និងគ្រួសារងាយរងហានិភ័យបានទទួលប្រាក់ឧបត្ថម្ភក្រោមអន្តរាគមន៍ជំនួយសង្គមពិសេសមួយចំនួន ដូចជាកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក៏ដូចជាកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងមានសម្ពាធអតិផរណា និងពីគ្រោះទឹកជំនន់ធ្ងន់ធ្ងរ។ លើសពីនេះ, រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យដំណើរការកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ កាលពីខែមេសា ឆ្នាំ២០២៤ ដែលក្នុងនោះរួមទាំងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរាអាយុ ៦០ឆ្នាំឡើង ក្នុងគ្រួសារមានបណ្ណសមធម៌។

### ៣.៧.២. វិធានការគោលនយោបាយ

យោងតាមជំរឿនទូទៅប្រជាជន ឆ្នាំ២០១៩, អាយុសង្ឃឹមរស់របស់ពលរដ្ឋកម្ពុជាត្រូវបានរំពឹងថានឹងកើនឡើងដល់ប្រមាណ ៨២ឆ្នាំ ក្នុងឆ្នាំ២០៣០ និង ៨៦,៦ឆ្នាំ ក្នុងឆ្នាំ២០៥០ ដែលការណ៍នេះតម្រូវឱ្យមានការគិតគូរយ៉ាងហ្មត់ចត់ពីការអភិវឌ្ឍប្រព័ន្ធសោធននៅកម្ពុជា ដើម្បីធានានិរន្តរភាព និងចីរភាពហិរញ្ញវត្ថុ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងធ្វើការកែទម្រង់របបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលនៃវិស័យ

សាធារណៈ ដើម្បីធានាចីរភាពនៃប្រព័ន្ធសោធនជារួម និងភាពទ្រទ្រង់បាននៃថវិកាជាតិ តាមរយៈការបង្វែរពីការទ្រទ្រង់ទាំងស្រុងដោយបន្ទុកថវិកាជាតិ មកជាប្រព័ន្ធបង់ភាគទានវិញ ដែលមានសង្គតិភាពជាមួយរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់កម្មករនិយោជិត និងក្រុមពលរដ្ឋដទៃទៀត។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលស្វ័យនិយោជន៍ ទៅតាមបរិបទជាក់ស្តែង។ មិនតែប៉ុណ្ណោះ, ដោយកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរាមកពីគ្រួសារមានបណ្ណសមធម៌ ត្រូវបានដាក់ឱ្យអនុវត្តក្រោមកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ, រាជរដ្ឋាភិបាលក៏នឹងពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យដំណើរការប្រព័ន្ធសោធនពហុកម្រិត (Multi-tiers Pension System) ដើម្បីពង្រីកការគ្របដណ្តប់ផ្នែកប្រាក់សោធនដល់ពលរដ្ឋផ្សេងទៀតដែលមិនទាន់ទទួលបានការគ្របដណ្តប់ ផងដែរ។

# ៤

# កិច្ចការឆ្លងវិស័យ

ក្រៅពីជំរុញការអភិវឌ្ឍអន្តរាគមន៍គាំពារសង្គមនានា ដែលបានកំណត់នៅក្នុងផ្នែកទី៣ ស្ដីពីអន្តរាគមន៍គាំពារសង្គម, ការគិតគូរអំពីកិច្ចការពាក់ព័ន្ធផ្សេងៗ ជាកត្តាចាំបាច់ផងដែរ ដើម្បីគាំទ្រ និងជំរុញដំណើរការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។ ការគិតគូរអំពីកិច្ចការឆ្លងវិស័យនានា ក៏នឹងធានាថាកត្តាពាក់ព័ន្ធផ្សេងៗនឹងមិនបង្កភាពរាំងស្ទះដល់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ទាំងដោយផ្ទាល់ ឬដោយប្រយោល។





## ៤.១. ការដោះស្រាយវិវាទ និងការទទួលមតិត្រឡប់

### ៤.១.១. ស្ថានភាពទូទៅ

ក្នុងក្របខណ្ឌគតិយុត្តកម្ពុជា, ការដោះស្រាយវិវាទអាចត្រូវអនុវត្តតាមរយៈប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ (Alternative Dispute Resolution)។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាវិធីសាស្ត្រកម្រិតបឋម ដែលត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយវិវាទ មុនពេលភាគីវិវាទសម្រេចចិត្ត ដោះស្រាយនៅតុលាការ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ប្រមូលផ្តុំដោយទម្រង់ដែលមាន លក្ខណៈសាមញ្ញ។ ទម្រង់ទូទៅបំផុតនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ រួមមានការចរចា, ការផ្សះផ្សា, ការសម្រុះសម្រួល និងមជ្ឈត្តកម្ម។

សម្រាប់ប្រព័ន្ធគាំពារសង្គមនៅកម្ពុជា, យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវបាន លើកទឹកចិត្តឱ្យអនុវត្ត ដើម្បីកាត់បន្ថយការចំណាយពេល និងធនធាន។ យន្តការដោះស្រាយវិវាទ ក្នុងប្រព័ន្ធសន្តិសុខសង្គម ត្រូវបានបង្កើតឡើងជាលក្ខណៈប្រព័ន្ធច្បាស់លាស់ ដោយបែងចែកជា ២ កម្រិត គឺ៖ កម្រិតទី១- ការដោះស្រាយវិវាទជាមុននៅកម្រិតប្រតិបត្តិករ និង កម្រិតទី២- ការប្តឹងតវ៉ានៅ កម្រិតនិយ័តករសន្តិសុខសង្គម។ ដោយឡែក ចំពោះប្រព័ន្ធជំនួយសង្គម, ការដោះស្រាយវិវាទត្រូវបាន អនុវត្តជាច្រើនកម្រិត ដូចជាកម្រិតឃុំ/សង្កាត់, ក្រុង/ស្រុក/ខណ្ឌ, រាជធានី/ខេត្ត, ប្រតិបត្តិករ/ក្រសួង, និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

### ៤.១.២. វិធានការគោលនយោបាយ

សម្រាប់របបសន្តិសុខសង្គម, ប្រតិបត្តិករ និងនិយ័តករសន្តិសុខសង្គម ត្រូវរៀបចំ និងដាក់ឱ្យ ដំណើរការយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទាំងការដោះស្រាយវិវាទនៅកម្រិតទី១ និងកម្រិត ទី២ ឱ្យបានពេញលេញ ដើម្បីផ្តល់ឱកាស និងភាពងាយស្រួលដល់អ្នកទទួលផលក្នុងការតវ៉ា ករណីមាន ភាពមិនប្រក្រតីកើតឡើង ឬករណីមិនសះជា។

សម្រាប់កម្មវិធីជាតិជំនួយសង្គម, យន្តការ និងការគិតគូរខាងលើនេះ អាចត្រូវអនុវត្តផងដែរ។ ប្រព័ន្ធគ្រប់គ្រងការទទួលបណ្តឹង, មតិត្រឡប់, និងសំណូមពរ ចាំបាច់ត្រូវគិតគូររៀបចំឡើងឱ្យមាន លក្ខណៈសាមញ្ញ ងាយស្រួល និងសមាត់ ដោយបង្កើតនូវជម្រើសច្រើន ទាំងការដាក់ពាក្យដោយផ្ទាល់ ឬតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប ដើម្បីឆ្ពោះទៅការធ្វើសុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងការទទួលបណ្តឹង មតិត្រឡប់ និងសំណូមពររបស់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងការធ្វើអន្តរប្រតិបត្តិការនៅគ្រប់កម្រិត ទាំងអស់ ក្នុងប្រព័ន្ធគាំពារសង្គម។

## ៤.២. ការកំណត់អត្តសញ្ញាណអត្តគាហក

### ៤.២.១. ស្ថានភាពទូទៅ

ប្រព័ន្ធកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ត្រូវបានប្រើប្រាស់ជាប្រភពទិន្នន័យគោលសម្រាប់កម្មវិធីជាតិជំនួយសង្គមនានា។ បច្ចុប្បន្ន, ប្រព័ន្ធនេះត្រូវបានផ្លាស់ប្ដូរពីយន្តការតាមជុំ មកជាយន្តការតាមការស្នើសុំ (On Demand) ដែលជាយន្តការមានលក្ខណៈទន់ភ្លន់ និងអាចឆ្លើយតបបានទាន់ពេលចំពោះការប្រែប្រួលនៃជីវភាពរស់នៅរបស់ពលរដ្ឋ។ គិតត្រឹមដំណាច់ឆ្នាំ២០២៤, គ្រួសារប្រមាណជាង ៧០ម៉ឺនគ្រួសារត្រូវបានកំណត់អត្តសញ្ញាណជាគ្រួសារក្រីក្រ (ទាំងក្រ១ និងក្រ២)។

កន្លងមក, យន្តការបណ្ណអាទិភាព (Post-ID) ដែលជាយន្តការបំពេញបន្ថែម ដើម្បីអនុញ្ញាតឱ្យគ្រួសារក្រីក្រអាចទទួលបានសេវាថែទាំសុខភាព ក្នុងករណីពួកគាត់ខកខានមិនបានទទួលបណ្ណសមធម៌ ត្រូវបានដាក់ឱ្យដំណើរការនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ។ ទោះយ៉ាងណា, យន្តការនេះត្រូវបានបញ្ចប់ នៅពេលយន្តការតាមការស្នើសុំរបស់ប្រព័ន្ធកំណត់អត្តសញ្ញាណគ្រួសារក្រីក្រត្រូវបានដាក់ឱ្យអនុវត្តពេញលេញ។

បន្ថែមលើការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ, ក្នុងឆ្នាំ២០២២ រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តការកំណត់អត្តសញ្ញាណក្រុមគោលដៅថ្មីមួយគឺ "គ្រួសារងាយរងហានិភ័យ" ដែលជាទូទៅត្រូវបានចាត់ទុកជាគ្រួសារពលរដ្ឋដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ។ ការកំណត់អត្តសញ្ញាណក្រុមគោលដៅថ្មីនេះ មានគោលបំណងពិនិត្យលទ្ធភាពក្នុងការផ្ដល់ការគាំទ្រដល់ពលរដ្ឋទាំងនោះ ដែលកន្លងមកពួកគេទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមនៅមានកម្រិតនៅឡើយ ខណៈពួកគាត់ប្រឈមខ្លាំងនឹងការធ្លាក់ចូលភាពក្រីក្រវិញភ្លាម ក្នុងករណីមានជំងឺធ្ងន់ធ្ងរ ជួបវិបត្តិ ឬគ្រោះអាសន្ននានា។

### ៤.២.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលនឹងបន្តពង្រឹងយន្តការកំណត់អត្តសញ្ញាណអត្តគាហកនៃប្រព័ន្ធគាំពារសង្គម ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ មានលក្ខណៈទន់ភ្លន់ និងឆ្លើយតបនឹងការប្រែប្រួលនៃកម្រិតជីវភាព និងស្ថានភាពនៃសមាជិកគ្រួសារបានទាន់ពេល ដើម្បីធានាថាពលរដ្ឋគោលដៅត្រូវបានកំណត់អត្តសញ្ញាណ និងទទួលបានបណ្ណទៅតាមលក្ខខណ្ឌជាធរមាន។ រាជរដ្ឋាភិបាលមានទស្សនវិស័យអភិវឌ្ឍប្រព័ន្ធកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ឱ្យក្លាយទៅជាឆ្អឹងខ្នងនៃមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម (Social Protection Registry) ដែលជាមូលដ្ឋានទិន្នន័យគោល អនុញ្ញាតឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធធ្វើប្រតិបត្តិការផ្លាស់ប្ដូរទិន្នន័យរវាងគ្នានឹងគ្នា។

## ៤.៣. ប្រព័ន្ធគាំពារសង្គមឌីជីថល

### ៤.៣.១. ស្ថានភាពទូទៅ

ជាមួយនឹងវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា, ការធ្វើឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថលនៃប្រព័ន្ធគាំពារសង្គម តាមរយៈការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ជារបៀបវារៈ និងមូលដ្ឋានដ៏សំខាន់ក្នុងការគាំទ្រ និងអនុវត្តគោលនយោបាយជាតិគាំពារសង្គម ប្រកបដោយគណនេយ្យភាព, តម្លាភាព, បរិយាបន្ន, និងអភិបាលកិច្ចល្អ។ កិច្ចការនេះអាចសម្រេចបាន តាមរយៈការកាត់បន្ថយជាអតិបរមានូវការចុះបញ្ជី និងការបើកផ្តល់អត្ថប្រយោជន៍ស្ទួន, ការវិនិយោគ និងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានដែលមានមុខងារដូចគ្នា, និងការគ្រប់គ្រងទិន្នន័យបែបបរិមជ្ឈការ ដែលនឹងនាំឱ្យមានភាពបែកខ្ញែក (Fragmented) កាន់តែធំឡើងៗ ស្របពេលវិសាលភាពនៃប្រព័ន្ធគាំពារសង្គមត្រូវបានពង្រីកឈានទៅបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការផ្តល់អត្ថប្រយោជន៍គាំពារសង្គមនានា និងការបើកផ្តល់បានឆាប់រហ័ស និងងាយស្រួល តាមរយៈស្វ័យប្រវត្តិកម្មប្រព័ន្ធឌីជីថល។

ទិដ្ឋភាពរួមនៃការអនុវត្តប្រព័ន្ធគាំពារសង្គមបច្ចុប្បន្ន បានជួបប្រទះ និងកំពុងមានបញ្ហាប្រឈមច្រើនពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដោយការគ្រប់គ្រងទិន្នន័យ និងការចុះបញ្ជីនៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនានា ត្រូវបានរចនាឡើងក្នុងអភិក្រមបែបវិមជ្ឈការ ដែលនាំឱ្យមានភាពបែកខ្ញែកនៃប្រព័ន្ធគ្រប់គ្រងទិន្នន័យកាន់តែធំឡើងៗ។ ទន្ទឹមនេះ, រំហូរនៃការចុះបញ្ជីនៅមានភាពរាយប៉ាយ និងធ្វើឡើងដោយនីតិវិធី និងប្រព័ន្ធគ្រប់គ្រងទិន្នន័យដាច់ដោយឡែកពីគ្នា ដែលនាំឱ្យអត្ថគាហក និងពលរដ្ឋគោលដៅម្នាក់ៗមានកាត ឬបណ្ណសម្គាល់អត្តសញ្ញាណច្រើន ដោយលេខសម្គាល់អត្តសញ្ញាណដែលបានចេញដោយប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ប្រតិបត្តិករទាំងអស់មិនទាន់មានការតភ្ជាប់ និងផ្លាស់ប្តូរទិន្នន័យរវាងគ្នានៅឡើយ។ ក្នុងក្របខណ្ឌនៃការអនុវត្តឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថលនៃប្រព័ន្ធគាំពារសង្គម, ក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមត្រូវបានបង្កើតជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំដោះស្រាយ និងអភិវឌ្ឍការងារនេះស្របតាម ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និង "ផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ឆ្នាំ២០២៤-២០២៨" និងបទដ្ឋានគតិយុត្តជាធរមាន។

### ៤.៣.២. វិធានការគោលនយោបាយ

ការកែទម្រង់យន្តការ និងនីតិវិធីនៃការចុះបញ្ជីបែបវិមជ្ឈការក្នុងបរិបទនៃការអនុវត្តបច្ចុប្បន្ន ទៅជាការចុះបញ្ជី និងការផ្តល់អត្ថប្រយោជន៍គាំពារសង្គមដោយប្រើប្រាស់ផតថលរួមលើ ថ្នាលគាំពារសង្គមឌីជីថល (Digital Social Protection Platform) និងការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងការគ្រប់គ្រងទិន្នន័យ រវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យប្រតិបត្តិករជាមួយ មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម (Social Protection Registry) តាមរយៈការធ្វើអន្តរប្រតិបត្តិការ, បច្ចុប្បន្នកម្ម, និងសមកាលកម្ម

ទិន្នន័យរវាងគ្នានឹងគ្នា នឹងនាំឱ្យកាត់បន្ថយភាពបែកខ្ញែកនៃប្រព័ន្ធជាអតិបរមា ក៏ដូចជាសម្រាលបន្ទុក និងសម្ពាធរបស់មន្ត្រីមូលដ្ឋានដែលជាអ្នកអនុវត្តផ្ទាល់។ ជាមួយគ្នានេះ, ការដាក់ចេញ និងការអនុវត្តផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ឆ្នាំ២០២៤-២០២៨ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ បានចាប់ផ្តើមក្លាយជាចលនាការ ដ៏សំខាន់ ក្នុងការលើកកម្ពស់ការកសាងសមត្ថភាពផ្នែកឌីជីថលសម្រាប់តួអង្គពាក់ព័ន្ធ, ការពង្រឹងការរៀបចំគោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធ, ការធ្វើឱ្យកាន់តែប្រសើរនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ប្រតិបត្តិករ និងការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាដៃគូអភិវឌ្ឍន៍នានា ឈានទៅសម្រេចបានគោលដៅនៃការដោះស្រាយបញ្ហា ទាំងក្នុងទិដ្ឋភាពនៃការអនុវត្តគោលនយោបាយជាតិគាំពារសង្គម និងទាំងទិដ្ឋភាពគាំពារសង្គមឌីជីថល។



## ៤.៤. ការបញ្ជ្រាបការយល់ដឹង ទំនាក់ទំនង និងការផ្សព្វផ្សាយ

### ៤.៤.១. ស្ថានភាពទូទៅ

ការយល់ដឹងរបស់សាធារណជនអំពីប្រព័ន្ធគាំពារសង្គមកម្ពុជា នៅមានកម្រិតនៅឡើយ។ កត្តានេះអាចរាំងស្ទះដល់ការចូលរួម ឬការទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមទាំងមូល។ ភស្តុតាងពីការសិក្សាកន្លងមកបានបង្ហាញថា គ្រួសារក្រីក្រដែលមានបណ្ណសមធម៌មួយចំនួន តែងតែប្រឈមនឹងហានិភ័យផ្នែកហិរញ្ញវត្ថុនៅពេលសមាជិកគ្រួសារធ្លាក់ខ្លួនឈឺ ទោះបីជាពួកគាត់ទទួលបានការគាំពារផ្នែកហិរញ្ញវត្ថុពេញលេញពីមូលនិធិសមធម៌សុខាភិបាលក៏ដោយ។ មិនតែប៉ុណ្ណោះ, កម្មករនិយោជិតមួយចំនួនធំដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ នៅមិនទាន់បានក្លាយជាសមាជិករបស់ ប.ស.ស. នៅឡើយ ដោយសារភាពព្រងើយកន្តើយ ឬការគេចវេះក្នុងការចុះបញ្ជីរបស់សហគ្រាសមួយចំនួន។ កត្តាទាំងនេះភាគច្រើនបណ្តាលមកពីកង្វះការយល់ដឹងអំពីប្រព័ន្ធគាំពារសង្គម និយាយជារួម និងកង្វះការយល់ដឹងអំពីអត្ថប្រយោជន៍នៃប្រព័ន្ធគាំពារសង្គម និយាយដោយឡែក។

កន្លងមក, ស្ថាប័នពាក់ព័ន្ធ ជាពិសេសស្ថាប័នប្រតិបត្តិករបានអនុវត្តយន្តការផ្សព្វផ្សាយ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនជាហូរហែ ប៉ុន្តែការអនុវត្តសកម្មភាពទាំងនោះភាគច្រើនមានលក្ខណៈរាយប៉ាយទៅតាមសមត្ថកិច្ចរៀងៗខ្លួន ដែលនេះជាហេតុធ្វើឱ្យក្រុមប្រឹក្សាជាតិគាំពារសង្គមបានដាក់ចេញនូវយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយគាំពារសង្គមកម្ពុជា ក្នុងឆ្នាំ២០២២ ដើម្បីធ្វើសុខដុមនីយកម្មការផ្សព្វផ្សាយ ពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម។ អន្តរាគមន៍ជាយុទ្ធសាស្ត្រមួយក្នុងចំណោមអន្តរាគមន៍នានាក្នុងយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយនេះ គឺការបង្កើតយន្តការផ្សព្វផ្សាយជាតិគាំពារសង្គម (NSPBM) ដើម្បីពង្រឹងទំនាក់ទំនង និងលើកកម្ពស់ការយល់ដឹង ការផ្សព្វផ្សាយ និងការផ្លាស់ប្តូរព័ត៌មានជាមួយគ្រប់ភាគីពាក់ព័ន្ធ អ្នកទទួលផល និងសាធារណជន។

បន្ថែមលើនេះ, ដើម្បីពង្រឹងកិច្ចសហការបន្ថែមទៀតក្នុងចំណោមភាគីពាក់ព័ន្ធ, ក្រុមប្រឹក្សាជាតិគាំពារសង្គមបានបង្កើត "សប្តាហ៍គាំពារសង្គមកម្ពុជា" ដែលជាវេទិកាថ្នាក់ជាតិប្រចាំឆ្នាំ ក្នុងគោលបំណងធំៗចំនួន២ គឺ៖ (១) ផ្តល់ឱកាសដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, និយោជក, កម្មករនិយោជិត, ដៃគូអភិវឌ្ឍន៍, និងអង្គការសង្គមស៊ីវិលនានា បានជួបពិភាក្សាអំពីការដាក់ចេញនូវគោលនយោបាយគាំពារសង្គម ព្រមទាំងជជែកពិភាក្សាលើដំណើរការនៃការអនុវត្តរបបសន្តិសុខសង្គម ឬកម្មវិធីជាតិជំនួយសង្គមនីមួយៗ, និង (២) លើកទឹកចិត្តសិស្ស និស្សិត ក៏ដូចជាបុគ្គលស្វ័យនិយោជន៍ និងសាធារណជន ឱ្យចូលរួមកិច្ចសន្ទនាសង្គមស្តីពីការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងស្វែងយល់កាន់តែច្បាស់អំពីអត្ថប្រយោជន៍របស់ប្រព័ន្ធគាំពារសង្គម។

### ៤.៤.២. វិធានការគោលនយោបាយ

ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវបន្តពង្រឹង និងពង្រីកវិសាលភាពនៃយន្តការផ្សព្វផ្សាយជាតិគាំពារសង្គម ឱ្យកាន់តែទូលំទូលាយដែលអនុញ្ញាតឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ប្រើប្រាស់ជាយន្តការរួមមួយក្នុងការផ្សព្វផ្សាយ និងការភ្ជាប់ទំនាក់ទំនងជាមួយសាធារណជន។ យន្តការផ្សព្វផ្សាយ និងផ្តល់ព័ត៌មានអំពីគាំពារសង្គមនឹងផ្តោតជាពិសេសលើក្រុមគោលដៅជាស្ត្រី និងជនមានពិការភាព។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពពង្រីកវិសាលភាពនៃយន្តការផ្សព្វផ្សាយអំពីប្រព័ន្ធគាំពារសង្គម ឱ្យកាន់តែទូលំទូលាយ ដោយការភ្ជាប់ទំនាក់ទំនងជាមួយអ្នកទទួលផល តាមរយៈបុគ្គលមានមានប្រជាប្រិយភាព។ រីឯសប្តាហ៍គាំពារសង្គមកម្ពុជា ក៏នឹងត្រូវពង្រីកទៅជាវេទិកាពិភាក្សាកម្រិតតំបន់ និងសកលផងដែរ។

ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងធម្មការ និងសាសនា និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវសហការជាមួយក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីពិនិត្យលទ្ធភាពក្នុងការដាក់បញ្ចូលចំណេះដឹងពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គមទៅក្នុងកម្មវិធីសិក្សាជាតិ ទាំងក្នុងកម្រិតចំណេះទូទៅ និងឧត្តមសិក្សា។

## ៤.៥. គោលនយោបាយគាំទ្រប្រព័ន្ធគាំពារសង្គម

### ៤.៥.១. ស្ថានភាពទូទៅ

ការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយនូវគោលនយោបាយពន្ធ និងគោលនយោបាយអនុគ្រោះផ្សេងទៀត ដើម្បីគាំទ្រប្រព័ន្ធគាំពារសង្គម ជាកត្តាសំខាន់ក្នុងការជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមពីសំណាក់ពលរដ្ឋឱ្យបានកាន់តែច្រើន។ការគិតគូរទាំងនោះមានដូចជា៖ (១) របបពន្ធដារលើតាវកាលិកគាំពារសង្គម, (២) របបពន្ធដារលើការបង់ភាគទានចូលក្នុងរបបសន្តិសុខសង្គម ទាំងរបបជាកាតព្វកិច្ច និងរបបស្ម័គ្រចិត្ត, (៣) របបពន្ធដារលើប្រាក់ចំណូលពីការវិនិយោគមូលនិធិសន្តិសុខសង្គម, (៤) ការឧបត្ថម្ភធនពីរដ្ឋ, និង (៥) របបពន្ធដារ និងការអនុគ្រោះផ្សេងទៀត។

### ៤.៥.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលនឹងពិចារណាដាក់ចេញនូវគោលនយោបាយពន្ធ និងគោលនយោបាយអនុគ្រោះផ្សេងទៀត រួមទាំងការឧបត្ថម្ភធនពីរដ្ឋ សម្រាប់គាំទ្រប្រព័ន្ធគាំពារសង្គម ស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៤.៦. យន្តការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធគាំពារសង្គម

### ៤.៦.១. ស្ថានភាពទូទៅ

ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា តាមរយៈការផ្តល់ជំនួយបច្ចេកទេសក្នុងការអភិវឌ្ឍគោលនយោបាយ, ការរៀបចំផែនការយុទ្ធសាស្ត្រ, ការកសាងសមត្ថភាព, និងការអនុវត្តរបបសន្តិសុខសង្គម, ឬកម្មវិធីជាតិជំនួយសង្គមនានា។ ក្នុងន័យនេះ និងដើម្បីពង្រឹងការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ឱ្យកាន់តែមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព ប្រសិទ្ធភាព ភាពជាប្រព័ន្ធ និងបរិយាបន្ន, ក្រុមប្រឹក្សាជាតិគាំពារសង្គមបានបង្កើតយន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធគាំពារសង្គមនាពេលកន្លងមក។

តាមរយៈយន្តការនេះ, ក្រុមប្រឹក្សាជាតិគាំពារសង្គមដើរតួនាទីជាអ្នកសម្របសម្រួលតំណាងឱ្យភាគីរាជរដ្ឋាភិបាល។ យន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធគាំពារសង្គម ផ្តោតលើកិច្ចសហការក្នុង៖ (១) ប្រព័ន្ធជំនួយសង្គម, (២) ប្រព័ន្ធសន្តិសុខសង្គមពាក់ព័ន្ធនឹងវិស័យការងារ, និង (៣) ប្រព័ន្ធគាំពារសុខភាពសង្គម។ ទន្ទឹមនេះ, យន្តការនេះក៏មានក្រុមការងារទទួលបន្ទុកសម្របសម្រួលជាតុចូលគោលនយោបាយ ជាមួយដៃគូអភិវឌ្ឍន៍ ដែលមានតួនាទីត្រួតពិនិត្យកិច្ចសហការជាយុទ្ធសាស្ត្រ។

កិច្ចប្រជុំក្រុមការងារទទួលបន្ទុកតាមផ្នែកនីមួយៗនៃប្រព័ន្ធគាំពារសង្គម ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ដើម្បីចែករំលែកព័ត៌មានអំពីវឌ្ឍនភាព និងគំនិតផ្តួចផ្តើមគាំពារសង្គមនានា ដើម្បីជំរុញឱ្យមានភាពស៊ីសង្វាក់គ្នា កាត់បន្ថយការងារប្រំដែល, កំណត់ឱកាសសំខាន់ៗ, ក៏ដូចជាបំពេញនូវចន្លោះខ្វះខាតដែលអាចកើតមាន និងផ្តល់ជំនួយក្នុងការតាមដាន និងពិនិត្យវឌ្ឍនភាព។

### ៤.៦.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាល នឹងបន្តពង្រឹងការអនុវត្តយន្តការនេះ ដើម្បីពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលសំដៅបន្តផ្តល់ក្របខណ្ឌស្ថាប័នសម្រាប់ការប្រមូលផ្តុំកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ការពង្រឹងគណនេយ្យភាពទៅវិញទៅមក ព្រមទាំងការពង្រឹងយន្តការសន្ទនាគោលនយោបាយ ផងដែរ។ ជាមួយនឹងការសម្របសម្រួលដែលមានសហថាមភាព និងការចូលរួមពីភាគីពាក់ព័ន្ធ, យន្តការនេះនឹងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការផ្តល់ជំនួយបច្ចេកទេស សម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមទាំងមូល ព្រមទាំងបន្តធានានូវភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍភាពជាដៃគូដែលមានលក្ខណៈស្មើភាពគ្នា និងគោរពគ្នាទៅវិញទៅមកក្នុងការសន្ទនា និងកិច្ចសហប្រតិបត្តិការ។

# ៤

# អភិបាលកិច្ច ប្រព័ន្ធគាំពារសង្គមកម្ពុជា

រចនាសម្ព័ន្ធអភិបាលកិច្ចនៃប្រព័ន្ធគាំពារសង្គមកម្ពុជា ត្រូវបានបែងចែកជា ៣ កម្រិត រួមមាន៖ (១) កម្រិតគោលនយោបាយ, (២) កម្រិតនិយ័តករ, និង (៣) កម្រិតប្រតិបត្តិករ ដើម្បីជានាបាននូវប្រតិគុណ្យការរវាងការបំពេញមុខងាររបស់អ្នកដាក់ចេញគោលនយោបាយ អ្នកត្រួតពិនិត្យ និងអ្នកអនុវត្តផ្ទាល់។

## ៥.១. កម្រិតគោលនយោបាយ

### ៥.១.១. ស្ថានភាពទូទៅ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត ក្រុមប្រឹក្សាជាតិគាំពារសង្គម (ក.ជ.គ.ស.) ជាសេនាធិការដើម្បីសម្របសម្រួល និងតម្រង់ទិសជាយុទ្ធសាស្ត្ររួមសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមទាំងមូល។ ក្រោយពីត្រូវបានបង្កើត និងដាក់ឱ្យដំណើរការកាលពីឆ្នាំ២០១៧, ក.ជ.គ.ស. បានបំពេញតួនាទីយ៉ាងសំខាន់ក្នុងការតម្រង់ទិសគោលនយោបាយ ក៏ដូចជាយុទ្ធសាស្ត្រក្នុងការដាក់ចេញ និងអនុវត្តរបបសន្តិសុខសង្គម និងកម្មវិធីជាតិជំនួយសង្គមនានា ស្របតាមចក្ខុវិស័យដែលបានកំណត់ក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ ដោយសម្រេចបាននូវវឌ្ឍនភាពជាបន្តបន្ទាប់ជាច្រើន ដូចជាការពង្រីកវិសាលភាពនៃការគ្របដណ្តប់, ការបង្កើត និងការដាក់ឱ្យដំណើរការកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមថ្មីៗ ព្រមទាំងការកែទម្រង់ស្ថាប័ននានាផងដែរ។ ក.ជ.គ.ស. ដំណើរការការងារដោយមានគណៈកម្មាធិការប្រតិបត្តិ, អនុគណៈកម្មាធិការ, ក្រុមការងារបច្ចេកទេស, និងអគ្គលេខាធិការដ្ឋាន ជាសេនាធិការ។

### ៥.១.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលមើលឃើញពីសារៈសំខាន់នៃការបំពេញតួនាទីរបស់ ក.ជ.គ.ស. ហើយនឹងបន្តពង្រឹងការបំពេញមុខងាររបស់ក្រុមប្រឹក្សាជាតិនេះឱ្យកាន់តែរឹងមាំថែមទៀត ដើម្បីបន្តជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមជារួម ក៏ដូចជាបន្តកែទម្រង់រចនាសម្ព័ន្ធស្ថាប័នពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាព, តម្លាភាព និងគណនេយ្យភាព ដោយប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អជាគោល។

បន្ថែមលើតួនាទី និងភារកិច្ចពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ ក៏ដូចជាការសម្របសម្រួលអនុវត្ត, ក្រុមប្រឹក្សាជាតិនេះក៏មានភារកិច្ចតាមដាន និងវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយនេះ ផងដែរ។

## ៥.២. កម្រិតនិយ័តករ

### ៥.២.១. ស្ថានភាពទូទៅ

រាជរដ្ឋាភិបាលបានបង្កើត និងដាក់ឱ្យដំណើរការនិយ័តករសន្តិសុខសង្គម (ន.ស.ស.) នៅក្រោមអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលមានតួនាទីតាមដាន និងត្រួតពិនិត្យរាល់ប្រតិបត្តិការនៃរបបសន្តិសុខសង្គម ដើម្បីធានាថាប្រតិបត្តិការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គម ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ព្រមទាំងមានភាពរឹងមាំផ្នែកហិរញ្ញវត្ថុ។ ច្បាប់ស្តីពីរបបសន្តិសុខសង្គម និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានកំណត់មុខងារ និងភារកិច្ចជារួមរបស់ ន.ស.ស.។ អនុក្រឹត្យស្តីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម និងអនុក្រឹត្យស្តីពីគោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម បានកំណត់លក្ខខណ្ឌចម្បងៗ សម្រាប់ការធ្វើនិយ័តកម្ម និងការត្រួតពិនិត្យប្រព័ន្ធសន្តិសុខសង្គម។ ក្នុងដំណាក់កាលដំបូងនៃការចាប់ផ្តើមប្រតិបត្តិការ,ន.ស.ស.ប្រើប្រាស់រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីបំពេញមុខងារ និងភារកិច្ច។

### ៥.២.២. វិធានការគោលនយោបាយ

ន.ស.ស. ត្រូវបន្តរៀបចំ និងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិប្រុងប្រយ័ត្នចាំបាច់នានា ដើម្បីធានាថាភាគទាន និងតាវកាលិករបស់សមាជិកនៃរបបសន្តិសុខសង្គមក្នុងផ្នែកនីមួយៗ ត្រូវបានការពារ និងធានាយ៉ាងពេញលេញ។ ជាមួយគ្នានេះ, និយ័តករសន្តិសុខសង្គមត្រូវបន្តអភិវឌ្ឍលិខិតបទដ្ឋានគតិយុត្ត ដើម្បីបង្កើតយន្តការការពារអ្នកទទួលផល និងដាក់ឱ្យដំណើរការយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងប្រព័ន្ធសន្តិសុខសង្គម ឱ្យបានពេញលេញក្នុងគោលដៅការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីវិវាទប្រកបដោយប្រសិទ្ធភាព តម្លាភាព សុចរិតភាព និងយុត្តិធម៌។

ក្នុងរយៈពេលមធ្យមខាងមុខ, រាជរដ្ឋាភិបាលនឹងរៀបចំកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់ ន.ស.ស. ឱ្យដាច់ចេញពីរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីធានាឱ្យបាននូវឯករាជ្យភាព ក្នុងការបំពេញការងាររបស់ខ្លួន។ ន.ស.ស. ត្រូវមានឯករាជ្យភាពពេញលេញទាំងការបំពេញមុខងារ និងថវិកា។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏នឹងសិក្សាអំពីលទ្ធភាពក្នុងការបង្កើតមុខងារនិយ័តកម្មដាច់ដោយឡែក សម្រាប់ប្រព័ន្ធជំនួយសង្គមផងដែរ។

## ៥.៣. ប្រតិបត្តិករសន្តិសុខសង្គមៈ បេឡាជាតិសន្តិសុខសង្គម

### ៥.៣.១. ស្ថានភាពទូទៅ

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវបានបង្កើតឡើងកាលពីចុងឆ្នាំ២០០៧ ហើយបានកែសម្រួលរចនាសម្ព័ន្ធថ្មីនៅឆ្នាំ២០១៩ តាមរយៈច្បាប់ស្តីពីរបបសន្តិសុខសង្គម ដោយបានប្តូរឈ្មោះមកជាបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ក្នុងគោលបំណងចម្បងមួយគឺការឆ្លើយតបនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើត និងការដាក់ឱ្យដំណើរការស្ថាប័នប្រតិបត្តិករទោលសម្រាប់ប្រព័ន្ធសន្តិសុខសង្គម អនុលោមតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ សំដៅធានាបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមនានា។

ការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ ប.ស.ស. បានបោះជំហានប្រកបដោយវឌ្ឍនភាព ចាប់ពីការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិតកាលពីឆ្នាំ២០០៨, ការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត កាលពីឆ្នាំ២០១៦ និងសម្រាប់មន្ត្រីសាធារណៈ កាលពីឆ្នាំ២០១៨, ការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ កាលពីឆ្នាំ២០២១, ការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិតកាលពីឆ្នាំ២០២២ និងការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកនៅក្នុងបន្ទុកសមាជិក ប.ស.ស. កាលពីចុងឆ្នាំ២០២៣។

### ៥.៣.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលមានគោលដៅបន្តពង្រឹងដំណើរការចាត់ចែង និងគ្រប់គ្រងរបបសន្តិសុខសង្គមឱ្យមានតម្លាភាព និងគណនេយ្យភាពពេញលេញតាមរយៈការប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ ដើម្បីកសាងជំនឿទុកចិត្តរបស់សាធារណជន ជាពិសេសកម្មករនិយោជិត និងនិយោជក ដែលជាបុគ្គលមានកាតព្វកិច្ចបង់ភាគទាន។ ការបន្តជំរុញការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សជាកត្តាចម្បងដើម្បីសម្រេចបាននូវគោលដៅនេះ ជាពិសេសការធ្វើបរិវត្តកម្មឌីជីថលនៃប្រព័ន្ធគ្រប់គ្រងសំដៅបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវា និងភាពងាយស្រួលក្នុងការទទួលសេវារបស់សមាជិកនៃរបបសន្តិសុខសង្គមនីមួយៗ។

## ៥.៤. ប្រតិបត្តិករជំនួយសង្គមៈ មូលនិធិជាតិជំនួយសង្គម

### ៥.៤.១. ស្ថានភាពទូទៅ

មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.) ត្រូវបានបង្កើតឡើងស្របតាមការចង្អុលបង្ហាញរបស់ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ក្នុងគោលដៅធ្វើសមាហរណកម្មការគ្រប់គ្រង និងការចាត់ចែងកម្មវិធីជាតិជំនួយសង្គមឱ្យស្ថិតនៅក្រោមប្រតិបត្តិករតែមួយ។ ក្រោយពីដាក់ឱ្យដំណើរការជាផ្លូវការកាលពីដើមឆ្នាំ២០២២, ម.ជ.ជ. បានទទួលការផ្ទេរមុខងារទាំងស្រុងពីបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ.) និងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) ព្រមទាំងមុខងារគ្រប់គ្រងកម្មវិធីជំនួយសង្គមរបស់មូលនិធិជនពិការ (ម.ជ.ព.) និងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

### ៥.៤.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលមានគោលដៅបន្តជំរុញការធ្វើសមាហរណកម្មការគ្រប់គ្រង និងការចាត់ចែងកម្មវិធីជាតិជំនួយសង្គមឱ្យស្ថិតក្រោមសមត្ថកិច្ចរបស់ ម.ជ.ជ. ដោយបានចាប់ផ្តើមពីកម្មវិធីអាហារូបករណ៍សិស្សក្រីក្រថ្នាក់បឋមសិក្សា និងថ្នាក់មធ្យមសិក្សា។ ដំណើរការនៃការគ្រប់គ្រង ម.ជ.ជ. ចាំបាច់ត្រូវពង្រឹងដោយប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ ដើម្បីធានាថារាល់ការចាត់ចែងហិរញ្ញប្បទានរបស់រដ្ឋត្រូវបានប្រព្រឹត្តទៅប្រកបដោយតម្លាភាព និងគណនេយ្យភាពពេញលេញ តាមរយៈការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អនុលោមតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា (IPSAP) និងការរងសវនកម្មស្របតាមបទដ្ឋានគតិយុត្តជាធរមាន។

## ៥.៥. ប្រតិបត្តិករមូលនិធិសមធម៌សុខាភិបាល

### ៥.៥.១. ស្ថានភាពទូទៅ

មូលនិធិសមធម៌សុខាភិបាល បាន និងកំពុងដំណើរការប្រកបដោយវឌ្ឍនភាព ដោយចាប់ផ្តើមពីការដាក់ឱ្យអនុវត្តដោយសាកល្បង កាលពីឆ្នាំ២០០០ និងបានពង្រីកវិសាលភាពទូទាំងប្រទេស កាលពីឆ្នាំ២០១៥។ ទោះយ៉ាងណា, រហូតមកដល់ពេលនេះ មូលនិធិសមធម៌សុខាភិបាលនៅបន្តដំណើរការជាលក្ខណៈការអនុវត្តគម្រោង ក្នុងក្របខណ្ឌគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល (H-EQIP) នៅឡើយ។ យន្តការគ្រប់គ្រងបច្ចុប្បន្ននេះ នៅមានភាពរាយប៉ាយ និងមិនទាន់មានភាពច្បាស់លាស់លើមុខងារ និងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធ។

### ៥.៥.២. វិធានការគោលនយោបាយ

ទន្ទឹមនឹងគោលដៅក្នុងការពង្រឹងអភិបាលកិច្ចនៃប្រព័ន្ធគាំពារសង្គមទាំងមូល, រាជរដ្ឋាភិបាលនឹងធ្វើស្ថាប័នូបនីយកម្មមូលនិធិសមធម៌សុខាភិបាល ឱ្យទៅជាយន្តការអភិបាលកិច្ចអចិន្ត្រៃយ៍ ដែលមានសង្គតិភាពទៅនឹងយន្តការគ្រប់គ្រងរបបសន្តិសុខសង្គម និងកម្មវិធីជាតិជំនួយសង្គមផ្សេងទៀត ដោយប្រកាន់ខ្ជាប់នូវគោលការណ៍បែងចែកឱ្យដាច់ពីគ្នានូវស្ថាប័នផ្តល់សេវា និងស្ថាប័នទូទាត់ថ្លៃសេវា (Payer-Provider Split) សំដៅធានាបាននូវប្រតិតុល្យការនៃការគ្រប់គ្រងស្ថាប័ន។

## ៥.៦. ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ

### ៥.៦.១. ស្ថានភាពទូទៅ

ជាសារបាន, ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល (ទ.ប.ច.ស.) ត្រូវបានបង្កើតឡើងកាលពីឆ្នាំ២០១៧ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសុខាភិបាល ដើម្បីបំពេញតួនាទីជាស្ថាប័នបញ្ជាក់ភាពត្រឹមត្រូវលើរាល់ការស្នើសុំចំណាយ សម្រាប់ទូទាត់ថ្លៃសេវាថែទាំសុខភាព របស់មូលនិធិសមធម៌សុខាភិបាល។ ដោយឡែក, ការបញ្ជាក់ការស្នើសុំចំណាយសម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងាររបស់ ប.ស.ស. ត្រូវបានអនុវត្តដោយ ប.ស.ស. ផ្ទាល់។

ដោយរាជរដ្ឋាភិបាលមានឆន្ទៈដ៏រឹងមាំ ក្នុងការបោះជំហានទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា, ការគិតគូរឡើងវិញអំពីយន្តការប្រតិតុល្យការបានក្លាយជាគោលដៅអាទិភាពដ៏សំខាន់មួយ ដែលជាមូលហេតុធ្វើឱ្យរាជរដ្ឋាភិបាលបានសម្រេចធ្វើការកែទម្រង់ទ.ប.ច.ស.ទៅជាទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ (ទ.ជ.ប.) ក្នុងឆ្នាំ២០២៣ ដោយប្រែក្លាយស្ថាប័ននេះ ទៅជាអង្គភាពនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងគោលដៅពង្រឹងឯករាជ្យភាពក្នុងការបំពេញការងារ ព្រមទាំងពង្រីកវិសាលភាពដោយទទួលខុសត្រូវលើការបញ្ជាក់ការស្នើសុំចំណាយរបស់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព រួមទាំងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងាររបស់ ប.ស.ស. ផងដែរ។

### ៥.៦.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលនឹងពង្រឹងយន្តការបញ្ជាក់ចំណាយឱ្យកាន់តែមានប្រសិទ្ធភាព និងសុក្រឹតភាព តាមរយៈការប្រើប្រាស់ប្រព័ន្ធឌីជីថល ដោយបន្តពង្រឹង និងពង្រីកប្រព័ន្ធកត់ត្រានិងគ្រប់គ្រងទិន្នន័យអ្នកជំងឺ (PMRS) ឱ្យក្លាយជាប្រព័ន្ធគ្រប់គ្រងការបញ្ជាក់ចំណាយស្វ័យប្រវត្តិ ដែលត្រូវដើរទន្ទឹមគ្នាជាមួយនឹងការដាក់ឱ្យអនុវត្តប្រព័ន្ធ EMR នៅតាមមូលដ្ឋានសុខាភិបាល ទាំងសាធារណៈ និងឯកជន។

បន្ថែមលើនេះ នៅរយៈពេលមធ្យម និងវែង, រាជរដ្ឋាភិបាលមានចក្ខុវិស័យពង្រឹងតួនាទីរបស់ ទ.ជ.ប. នៅក្នុងដំណើរការអភិវឌ្ឍប្រព័ន្ធថែទាំសុខភាពសង្គមនៅកម្ពុជា លើសពីមុខងារបញ្ជាក់ចំណាយ ជាពិសេសការបង្កើត និងការដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃបច្ចេកវិទ្យាសុខាភិបាល (HTA) និងតួនាទីក្នុងយន្តការទិញជាយុទ្ធសាស្ត្រ (Strategic purchasing)ជាដើម។



## ៥.៧. ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៥.៧.១. ស្ថានភាពទូទៅ

ដើម្បីធានាដល់ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបនឹងតម្រូវការ និងការដោះស្រាយបញ្ហាប្រឈមរបស់ពលរដ្ឋបានទាន់ពេល និងចំគោលដៅ, រាជរដ្ឋាភិបាលបានផ្ទេរសិទ្ធិអំណាច មុខងារ ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងការទទួលខុសត្រូវពេញលេញដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង ចាត់ចែង បង្ការ ទប់ស្កាត់ និងចាត់វិធានការដោះស្រាយបញ្ហានានា ដោយទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ទាន់ពេល និងប្រកបដោយប្រសិទ្ធភាព ជាពិសេស ក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ។ លើសពីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានដើរតួយ៉ាងសំខាន់ក្នុងដំណើរការគ្រប់គ្រង និងចាត់ចែងអន្តរាគមន៍គាំពារសង្គមពិសេសកម្មវិធីជំនួយសង្គម ដូចជាការចូលរួមអនុវត្តការកំណត់អត្តសញ្ញាណក្រុមពលរដ្ឋគោលដៅនៃប្រព័ន្ធគាំពារសង្គម រួមមានគ្រួសារក្រីក្រ គ្រួសារងាយរងហានិភ័យ ជនងាយរងគ្រោះ និងបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ, ការបើកផ្តល់សាច់ប្រាក់, ការផ្សព្វផ្សាយ, និងការបញ្ជ្រាបចំណេះដឹង ជាដើម។ល។

ទន្ទឹមនេះ, ក្រសួងមហាផ្ទៃជាតួអង្គដ៏សំខាន់ ក្នុងការជំរុញឱ្យរដ្ឋបាលរាជធានី ខេត្ត ធ្វើការវិភាជន៍ថវិកាប្រមាណ ១០% នៃថវិកាគុណប្រយោជន៍ ដើម្បីអនុវត្តសកម្មភាពសេវាសង្គម ដែលជាសកម្មភាពបំពេញបន្ថែមលើប្រព័ន្ធគាំពារសង្គមដោយផ្តោតទៅលើការជួយដល់ពលរដ្ឋក្រីក្រ ជនចាស់ជរា ស្ត្រី កុមារ និងជនងាយរងគ្រោះផ្សេងៗទៀត ព្រមទាំងជំរុញរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ធ្វើការតែងតាំងមន្ត្រីសេវាសង្គម ដើម្បីជួយគាំទ្រស្ត្រី និងកុមាររងាយរងគ្រោះពីអំពើហិង្សា ការរំលោភបំពាន និងបញ្ហាផ្សេងៗទៀត។

ទោះយ៉ាងណា, ភាពសកម្មនៃការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតខុសគ្នាពីតំបន់មួយទៅតំបន់មួយទៀត ដោយអាស្រ័យលើកត្តាធនធានមនុស្សនៅតាមមូលដ្ឋានផ្ទាល់ ព្រមទាំងភាពមានកម្រិតនៃធនធានហិរញ្ញវត្ថុ ផងដែរ។

### ៥.៧.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលនឹងបន្តពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០២១-២០៣០ ដែលផ្តោតសំខាន់លើការផ្ទេរធនធានទៅថ្នាក់ក្រោមជាតិសម្រាប់ការកសាងទាំងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស។ ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបន្តកិច្ចសហការជាមួយក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីជំរុញការងារនេះ ដោយផ្តោតសំខាន់លើកត្តាធំៗចំនួន ៣ គឺ៖ (១) ការពង្រឹងសមត្ថភាព, (២) ការបង្កើនទំនាក់ទំនងរវាងរដ្ឋបាលឃុំ/សង្កាត់, រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ និងរដ្ឋបាលរាជធានី/ខេត្ត, និង (៣) ការធ្វើឌីជីថលូបនីយកម្ម។

បន្ថែមលើនេះ, ភាគីពាក់ព័ន្ធត្រូវផ្តល់កិច្ចសហការដល់ក្រុមប្រឹក្សាជាតិគាំពារសង្គមក្នុងការជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គមឱ្យបានល្អប្រសើរប្រកបដោយប្រសិទ្ធភាព និងមានគុណភាពខ្ពស់ ស្របតាមគោលនយោបាយ គោលការណ៍ និងស្តង់ដាជាតិដែលបានកំណត់។

ក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ការអភិវឌ្ឍសមត្ថភាព និងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃឱ្យបានទៀងទាត់ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពសមត្ថភាពគ្រប់គ្រាន់ និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការអនុវត្តមុខងារទាំងនោះប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

លើសពីនេះ ដើម្បីគិតគូរផ្តល់មុខងារ និងធនធានបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តសកម្មភាពនានាដែលបម្រើដល់គោលនយោបាយជាតិគាំពារសង្គម, ក្រសួងមហាផ្ទៃ ដែលជាអ្នកគាំទ្រ និងជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្ទាល់ និងដោយមានកិច្ចសហការពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវផ្តល់កិច្ចសហការជូនក្រុមប្រឹក្សាជាតិគាំពារសង្គម តាមការចាំបាច់។

# ៦

# យន្តការអនុវត្ត និងយន្តការតាមដាន និងវាយតម្លៃ

ដើម្បីឆ្លើយតបនឹងសារៈសំខាន់នៃការចាប់ផ្តើមដំណាក់កាលថ្មីនៃទិសដៅគោលនយោបាយគាំពារសង្គម, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ នឹងដើរតួជាមគ្គុទ្ទេសក៍បង្ហាញផ្លូវរយៈពេលវែង ក្នុងការបន្តតម្រង់ទិសការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជាឱ្យកាន់តែរឹងមាំ និងល្អប្រសើរ សម្រាប់រយៈពេល ១១ឆ្នាំបន្តទៀត។ ក្នុងន័យនេះ, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ កំណត់យន្តការអនុវត្ត ក៏ដូចជាយន្តការតាមដាន និងវាយតម្លៃ ដែលមានភាពប្រទាក់ក្រឡា និងជាក់លាក់ ដូចខាងក្រោម៖

## ៦.១. យន្តការអនុវត្ត

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ ជាឯកសារយុទ្ធសាស្ត្រថ្នាក់ជាតិ ដែលកំណត់ទិសដៅគោលនយោបាយក្នុងការបន្តជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ឱ្យកាន់តែរឹងមាំ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព សម្រាប់ផ្តល់ការគាំពារដល់ពលរដ្ឋគ្រប់រូបនៅគ្រប់ដំណាក់កាលនៃវដ្តជីវិត និងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គ្រោះអាសន្ន ឬវិបត្តិនានា។ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ នេះ, ផែនការសកម្មភាពជាក់លាក់ក្នុងក្របខណ្ឌពេលច្បាស់លាស់ នឹងត្រូវបានរៀបចំឡើងដោយផ្អែកលើភស្តុតាង និងការពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយ។ ផែនការសកម្មភាពនេះ នឹងកំណត់សកម្មភាពអាទិភាពលម្អិតសម្រាប់រយៈពេលខ្លី, មធ្យម និងវែង ដែលមានសូចនាករវាស់វែងជាក់លាក់ ព្រមទាំងបញ្ជាក់ពីការទទួលខុសត្រូវអនុវត្តរបស់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដោយត្រូវបែងចែកជា ២ ដំណាក់កាល។ ផែនការសកម្មភាពដំណាក់កាលទី១ សម្រាប់ឆ្នាំ២០២៤-២០៣០ និងដំណាក់កាលទី២ សម្រាប់ ឆ្នាំ២០៣០-២០៣៥។

## ៦.២. យន្តការតាមដាន និងវាយតម្លៃ

ការអនុវត្ត និងសមិទ្ធផលនានាក្នុងប្រព័ន្ធគាំពារសង្គម ដែលសម្រេចបានកន្លងមកត្រូវបានតាមដាន និងវាយតម្លៃក្នុងអភិក្រមដាច់ដោយឡែកពីគ្នា ដោយមានកិច្ចសហការរវាងក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដែលការណ៍នេះអនុញ្ញាតឱ្យមើលឃើញពីវឌ្ឍនភាពនៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមនាពេលកន្លងមក និងលទ្ធផលនៃការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ។ ដើម្បីតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមទាំងមូល, យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមរួមមួយ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តចាប់តាំងពីឆ្នាំ២០២០ ក្នុងគោលបំណងលើកកម្ពស់ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិគាំពារសង្គម ក៏ដូចជាការប្រមូលទិន្នន័យ និងភស្តុតាងដែលជាធាតុចូលមិនអាចខ្វះបានក្នុងការបង្កើតជម្រើសគោលនយោបាយនានា។

ក្នុងន័យនេះ, យន្តការតាមដាន និងវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០២៤-២០៣៥ បន្តប្រកាន់យកអភិក្រមដូចគ្នានឹងការអនុវត្តនាពេលកន្លងមក ដែលបែងចែកជា ២ ដូចខាងក្រោម៖

### ៦.២.១. យន្តការតាមដាន និងវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងផែនការសកម្មភាព

ការតាមដាន និងការវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ រួមទាំងផែនការសកម្មភាព នឹងត្រូវបានរៀបចំឡើង នៅពេលដាក់ឱ្យអនុវត្ត។ ការតាមដាន និងការវាយតម្លៃនេះ មានគោលបំណងសំខាន់ចំនួន ២ គឺ៖ (១) ពិនិត្យវឌ្ឍនភាពរបស់ផែនការសកម្មភាព និងស្វែងយល់អំពីភាពជាប់ពាក់ព័ន្ធ, និង (២) សិក្សាទាញយកមេរៀន និងឧត្តមានុវត្តន៍នៃការអនុវត្តផែនការសកម្មភាព ព្រមទាំងស្វែងរកកម្មវិបាក និងលទ្ធផលចុងក្រោយនៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមនេះ។ ស្ថាប័នកម្រិតគោលនយោបាយ កម្រិតនិយ័តករ និងកម្រិតប្រតិបត្តិករក្នុងប្រព័ន្ធគាំពារសង្គម មានភារកិច្ចតាមដានការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងផែនការសកម្មភាព ដោយមានការគាំទ្រពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម រួមទាំងការវាយតម្លៃពាក់កណ្ដាលអាណត្តិ នឹងត្រូវដឹកនាំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម និងមានការគាំទ្រពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងន័យពង្រឹង និងកែលម្អការអនុវត្តផែនការសកម្មភាព និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។

### ៦.២.២. យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម

ការបន្តអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមរួម ដែលមានស្រាប់ មានសារៈសំខាន់ ដើម្បីបន្តពិនិត្យវឌ្ឍនភាព និងវាយតម្លៃកម្មវិបាកនៃប្រព័ន្ធគាំពារសង្គមក្នុងការលើកកម្ពស់សុខភាព និងសុខុមាលភាពពលរដ្ឋ, ការកាត់បន្ថយភាពក្រីក្រ វិសមភាពយេនឌ័រ និងវិសមភាពសង្គម ព្រមទាំងការពង្រឹងសាមគ្គីភាព និងស្ថិរភាពសង្គម ក្នុងអំឡុងការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥។ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមរួមនេះឱ្យកាន់តែប្រសើរ, ការរៀបចំ និងការអនុវត្តយន្តការតាមដាន និងវាយតម្លៃកម្រិតកម្មវិធី នៅតាមក្រសួង-ស្ថាប័ន ដែលជាប្រតិបត្តិករ មានភាពចាំបាច់ ក្នុងការធានាបានភាពត្រឹមត្រូវ និងសង្គតិភាពនៃទិន្នន័យ, តម្លាភាព និងឆ្លុះបញ្ចាំងនូវលទ្ធផលនៃកិច្ចខិតខំសហការក្នុងការអភិវឌ្ឍ

ប្រព័ន្ធគាំពារសង្គមពីគ្រប់ក្រសួង-ស្ថាប័ន ដោយធ្វើការដាក់បញ្ចូលទិន្នន័យពាក់ព័ន្ធនឹងយេនឌ័រ ផងដែរ។ ជាមួយគ្នានេះ ក្នុងគោលបំណងបង្កើនប្រសិទ្ធិភាព និងរក្សាបាននូវចលនាការ, ការធ្វើស្វ័យប្រវត្តិកម្មនៃការបញ្ចូលទិន្នន័យ តាមរយៈការធ្វើសន្ទានកម្មកម្មវិធីកុំព្យូទ័រ រវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ប្រតិបត្តិករ ជាមួយនឹងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមមានភាពចាំបាច់ណាស់។

របបសន្តិសុខសង្គម, កម្មវិធីជាតិជំនួយសង្គម, សូចនាករ រួមទាំងក្រសួង-ស្ថាប័ន ដែលបានកំណត់ក្នុងយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមបច្ចុប្បន្ន ត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំ និងទាន់ពេល ដោយធ្វើការដាក់បញ្ចូលនូវសូចនាករពាក់ព័ន្ធនឹងយេនឌ័រ ស្របតាមបរិបទនៃការវិវឌ្ឍក្នុងប្រព័ន្ធគាំពារសង្គម និងសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា។ បន្ថែមលើនេះ, ការវាយតម្លៃជាប្រព័ន្ធអំពីកម្មវិបាក (Systemic Impact Evaluation)របស់កម្មវិធីជាតិជំនួយសង្គមនិងរបបសន្តិសុខសង្គមគួរត្រូវបានធ្វើឡើងដើម្បីវាស់វែងនិងអាចធានាបានថា គោលដៅ និងគោលបំណងរបស់កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ ត្រូវបានបំពេញ និងសម្រេចបាន ក៏ដូចជាដើម្បីផ្តល់រូបភាពកាន់តែច្បាស់អំពីការរួមចំណែករបស់ប្រព័ន្ធគាំពារសង្គម ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា។

# ៧

# សេចក្ដីសន្និដ្ឋាន

រាជរដ្ឋាភិបាលគ្រប់នីតិកាល ជាពិសេសក្នុងនីតិកាលទី៧នៃរដ្ឋសភា នៅតែផ្ដោតការយកចិត្តទុកដាក់លើ "**មនុស្ស**" ជាគោលដៅអាទិភាពសម្រាប់ការអភិវឌ្ឍប្រទេសជាតិ ដោយនឹងបន្តលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស និងសុខុមាលភាពរបស់ពលរដ្ឋ តាមរយៈការបន្តជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឱ្យកាន់តែមានប្រសិទ្ធភាព និងចីរភាព ដើម្បីផ្ដល់ការគាំពារដល់ពលរដ្ឋពេញមួយវដ្ដជីវិត។ ក្នុងន័យនេះ និងផ្អែកលើការវិវឌ្ឍជាក់ស្ដែងនៃស្ថានភាពសង្គម-សេដ្ឋកិច្ចកម្ពុជា, រាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការរៀបចំ "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥" ដែលជាការធ្វើបច្ចុប្បន្នកម្ម និងជំនួស ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដើម្បីធានានិរន្តរភាពនៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ក្នុងការបន្តតម្រង់ទិសការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា សំដៅរួមចំណែកលើកកម្ពស់សុខុមាលភាពសង្គម និងកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាបន្ន។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ នេះ ធ្វើការផ្លាស់ប្ដូរអភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមពីប្រព័ន្ធដែលធ្វើការគាំពារតាមបែបសសរស្ដម្ភមកជាប្រព័ន្ធដែលធ្វើការគាំពារតាមហានិភ័យនៃវដ្ដជីវិត ដើម្បីបន្តជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា។

ក្របខណ្ឌគោលនយោបាយថ្មីនេះ ជាឯកសារគោលសម្រាប់តម្រង់ទិសការរៀបចំអន្តរាគមន៍គាំពារតាមដំណាក់កាល រួមមានមាតុភាព និងហានិភ័យកុមារភាព, ហានិភ័យការងារ, និកម្មភាពការងារ, ហានិភ័យសុខភាព, ពិការភាព, ភាពគ្មានជម្រក និងជរាភាពនិងឧត្តរជីវី។ បន្ថែមលើនេះ, ក្របខណ្ឌគោលនយោបាយ នេះក៏កំណត់វិធានការគោលនយោបាយសម្រាប់កិច្ចការឆ្លងវិស័យពាក់ព័ន្ធ ដើម្បីជួយជំរុញដំណើរការអភិវឌ្ឍ និងមិនបង្កភាពរាំងស្ទះដល់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ទាំងដោយផ្ទាល់ ឬដោយប្រយោល។ ដូចគ្នានេះដែរ, រាជរដ្ឋាភិបាលក៏បានកំណត់វិធានការគោលនយោបាយ សម្រាប់បន្តពង្រឹងអភិបាលកិច្ចនៃប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ តាមមុខងារទាំង ៣កម្រិត រួមមានកម្រិតគោលនយោបាយ, កម្រិតនិយ័តករ និងកម្រិតប្រតិបត្តិករ ដើម្បីធានាបាននូវប្រតិតុល្យការរវាងការបំពេញមុខងារនីមួយៗ។

ជារួម, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ បង្ហាញពីទស្សនវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក្នុងការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដែលអាចផ្ដល់ការគាំពារដល់ពលរដ្ឋឆ្លើយតបនឹងហានិភ័យនៃវដ្ដជីវិត ស្របតាមដំណើរការវិវឌ្ឍនៃស្ថានភាពសង្គម-សេដ្ឋកិច្ចកម្ពុជា ឆ្ពោះទៅការសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

# ឧបសម្ព័ន្ធ ១

## សទ្ទានុក្រម

| | | |
|---|---|---|
| ១ | ការគ្របដណ្តប់សុខភាពជាសកល | សំដៅដល់ការធានាឱ្យពលរដ្ឋទាំងអស់មានលទ្ធភាពទទួលបានសេវាសុខាភិបាលប្រកបដោយ គុណភាពពេញលេញ ដែលពួកគេត្រូវការនៅគ្រប់ទីកន្លែង និងពេលមានតម្រូវការ ដោយមិនរងផលលំបាកផ្នែកហិរញ្ញវត្ថុ ដែលសេវាទាំងនោះរួមមានចាប់ពីការលើកកម្ពស់សុខភាព ការបង្ការជំងឺ រហូតដល់ការព្យាបាល ការស្តារនីតិសម្បទា និងការថែទាំសម្រន់។ |
| ២ | ការទិញជាយុទ្ធសាស្ត្រ | សំដៅដល់យុទ្ធសាស្ត្រហិរញ្ញប្បទានសុខាភិបាលដែលផ្សារភ្ជាប់ថវិកា និងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ទៅនឹងសមិទ្ធកម្មការងារ (ទាំងគុណភាព និងបរិមាណ) ដែលត្រូវបានកំណត់ដោយព័ត៌មានលម្អិតអំពីការអនុវត្តការផ្តល់សេវា និងតម្រូវការសុខភាពរបស់ពលរដ្ឋគោលដៅ។ |
| ៣ | គ្រួសារងាយរងហានិភ័យ | សំដៅដល់គ្រួសាររស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ និងមានភាពងាយរងគ្រោះក្នុងគ្រួសារ ចំនួន ១ យ៉ាងតិច ដែលក្នុងនោះរួមមានជនមានពិការភាព, កុមារអាយុក្រោម ២ឆ្នាំ, ជនចាស់ជរាអាយុចាប់ពី ៦០ឆ្នាំឡើង, ស្ត្រីជាមេគ្រួសារ និងរស់នៅដោយគ្មានស្វាមី, គ្រួសារដែលមានសមាជិកសុទ្ធសឹងជាកុមារ និងជនវ័យ ចាស់ (មិនមានសមាជិកគ្រួសារអាយុពី ១៩-៥៩ ឆ្នាំ)។ |
| ៤ | ចំណាយប្រាក់ហោប៉ៅ | សំដៅដល់រាល់ការចំណាយផ្ទាល់របស់គ្រួសារ ដែលរាប់បញ្ចូលទាំងចំណាយលើថ្លៃសេវា, ចំណាយក្រៅផ្លូវការ, ការទិញឱសថ និងចំណាយផ្សេងៗ ដើម្បីទទួលបានការថែទាំសុខភាព។ ចំណាយប្រាក់ហោប៉ៅ រាប់បញ្ចូលទាំងចំណាយលើការធ្វើដំណើរ និងការដឹកជញ្ជូនពាក់ព័ន្ធនឹងការថែទាំសុខភាព តែមិនរាប់បញ្ចូលការបង់មុន ដូចជាការបង់ពន្ធ ឬធានារ៉ាប់រងសុខភាព។ |

| | | |
|---|---|---|
| ៥ | ឌីជីថលូបនីយកម្ម | សំដៅដល់ដំណើរការកែសម្រួលការធ្វើអភិបាលកិច្ច ឬធុរកិច្ច ឬដំណើរការសកម្មភាពអ្វីមួយឱ្យមានប្រសិទ្ធភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ |
| ៦ | តាវកាលិក | សំដៅដល់អត្ថប្រយោជន៍នៃប្រព័ន្ធគាំពារសង្គមដែលត្រូវផ្តល់ជូនក្រុមពលរដ្ឋគោលដៅ តាមរយៈកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម។ |
| ៧ | ថ្នាលគាំពារសង្គមឌីជីថល | សំដៅដល់ថ្នាលឌីជីថលរួមបែបសមាហរណ៍របស់រាជរដ្ឋាភិបាល ដំណើរការដោយតភ្ជាប់ជាមួយមូលដ្ឋានទិន្នន័យចុះបញ្ជីរបស់ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ បង្កើតជាប្រព័ន្ធអន្តរប្រតិបត្តិការអេកូឡូស៊ីរួមសម្រាប់ប្រព័ន្ធគាំពារសង្គមកម្ពុជា។ |
| ៨ | ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ | សំដៅដល់ប្រាក់ឧបត្ថម្ភដែលត្រូវបើកផ្តល់ជូនសមាជិក ប.ស.ស. ដែលបានជួបប្រទះហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្នុងកម្រិតចាប់ពី២០%ឡើង។ |
| ៩ | ធនលាភឧត្តរជីវី | សំដៅដល់ប្រាក់ឧបត្ថម្ភដែលត្រូវបើកផ្តល់ដល់សិទ្ធិវន្តជាឧត្តរជីវីរបស់សមាជិក ប.ស.ស. ដែលទទួលរងហានិភ័យការងាររហូតបាត់បង់ជីវិត។ |
| ១០ | បរិយាបន្ន | សំដៅដល់ការលើកកម្ពស់ស្ថានភាពរបស់បុគ្គល និងក្រុមនានាក្នុងការចូលរួម និងការទទួលផលពីសកម្មភាពនានា របស់សង្គម ដោយមិនរើសអើងពីពិការភាព យេនឌ័រ ពណ៌សម្បុរ សាសនា ជាតិសាសន៍ ស្ថានភាព និងជីវភាពគ្រួសារ។ |
| ១១ | បរិវត្តកម្មឌីជីថល | សំដៅដល់ការធ្វើសមាហរណកម្មបច្ចេកវិទ្យាឌីជីថលទៅក្នុងគ្រប់ទិដ្ឋភាពនៃធុរកិច្ច សេដ្ឋកិច្ច និងសង្គម សំដៅផ្លាស់ប្តូរការងារបែបប្រពៃណី ឬមិនសូវមាននវានុវត្តន៍ ទៅជាប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីមិនគ្រាន់តែបង្កើនប្រសិទ្ធិភាពការងារប៉ុណ្ណោះទេ ថែមទាំងផ្តល់ឱកាសឱ្យមាននវានុវត្តន៍ថ្មីៗ ក្នុងការសម្រួលដល់ការធ្វើធុរកិច្ច និងការរស់នៅរបស់មនុស្សជាតិជំនាន់ថ្មី។ |
| ១២ | បុគ្គលស្វ័យនិយោជន៍ | សំដៅដល់ជនដែលប្រកបការងារឬមុខរបររកចំណូលផ្ទាល់ខ្លួន ដោយមិនពាក់ព័ន្ធនឹងប្រាក់ឈ្នួល ឬប្រាក់បៀវត្សដែលផ្តល់ដោយនិយោជកឬរដ្ឋតាមកិច្ចសន្យាការងារ ហើយក៏មិនមានប្រើប្រាស់កម្មករនិយោជិតនៅក្នុងសកម្មភាពការងារ ឬមុខរបររបស់ខ្លួន។ |

| | |
|---|---|
| ១៣ មជ្ឈត្តកម្ម | សំដៅដល់ការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ហើយអាចស្ថិតនៅក្នុង ឬនៅក្រៅក្របខណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍។ |
| ១៤ មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម | សំដៅដល់មូលដ្ឋានទិន្នន័យចុះបញ្ជីរួមបែបសមាហរណ៍ របស់រាជរដ្ឋាភិបាល ដែលផ្ទុកទិន្នន័យអត្តសញ្ញាណគាំពារសង្គម និងទិន្នន័យស្ថានភាពសង្គម-សេដ្ឋកិច្ច ដោយបង្កើតលេខសម្គាល់គាំពារសង្គមតែមួយគត់ចំនួន ១០ (ដប់) ខ្ទង់។ |
| ១៥ មូលនិធិសមធម៌សុខាភិបាល | សំដៅដល់យន្តការហិរញ្ញប្បទានផ្នែកគាំពារសុខភាពសង្គម ដើម្បីផ្តល់លទ្ធភាពដល់ក្រុមពលរដ្ឋគោលដៅមួយចំនួនទទួលបាន ឬប្រើប្រាស់សេវាថែទាំសុខភាព ដោយឥតបង់ថ្លៃនៅមូលដ្ឋានសុខាភិបាលសាធារណៈ តែរាជរដ្ឋាភិបាលជាអ្នកទទួលបន្ទុកបង់ថ្លៃជំនួស។ |
| ១៦ យេនឌ័រ | សំដៅដល់ការយល់ដឹង និងផ្តល់ការគិតគូរលើបទដ្ឋានសង្គម-វប្បធម៌ និងការរើសអើងនានា ដើម្បីទទួលស្គាល់ពីភាពខុសគ្នានៃសិទ្ធ មុខងារ និងទំនួលខុសត្រូវរបស់ស្ត្រី និងបុរសក្នុងសហគមន៍ និងទំនាក់ទំនងរវាងពួកគេ។ |
| ១៧ យុទ្ធសាស្ត្រចាកចេញ | សំដៅដល់ការគិតគូរពីយុទ្ធសាស្ត្រដើម្បីឱ្យពលរដ្ឋចាកចេញពីភាពក្រីក្រ តាមរយៈការផ្តល់នូវការបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងឱកាសការងារសមរម្យក្នុងការបង្កើនប្រាក់ចំណូល និងលើកកម្ពស់កម្រិតជីវភាពរស់នៅ។ |
| ១៨ វិភាជន៍បូជាសព | សំដៅដល់ប្រាក់ឧបត្ថម្ភសម្រាប់ការចាត់ចែងបូជាសពសមាជិក ប.ស.ស. ដែលទទួលមរណភាព។ |
| ១៩ សមកាលកម្មទិន្នន័យ | សំដៅដល់ទំនាក់ទំនងក្នុងការផ្លាស់ប្តូរ និងធ្វើបច្ចុប្បន្នភាពទិន្នន័យទៅវិញទៅមករវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពីរ ឬច្រើន។ |
| ២០ សមធម៌ | សំដៅដល់លក្ខខណ្ឌតម្រូវជាមូលដ្ឋាននៃយុត្តិធម៌សង្គម ដែលជាប់ពាក់ព័ន្ធនឹងភាពត្រឹមត្រូវ ឬចំណែកត្រឹមត្រូវ ហើយខុសពីសមភាព ឬចំណែកស្មើគ្នា។ |

| | |
|---|---|
| ២១ សេវាសុខាភិបាលសារវន្ត | សំដៅដល់សេវាសុខាភិបាលសំខាន់ៗ ដូចជាសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ, សេវាសុខភាពម្តាយនិងទារក, សេវាសុខភាពកុមារ, ការផ្តល់ថ្នាំបង្ការ, អាហារូបត្ថម្ភ, សេវាពិនិត្យនិងព្យាបាលជំងឺឆ្លង (ជំងឺរបេង មេរោគអេដស៍ ជំងឺគ្រុនចាញ់ ជាដើម), សេវាជំងឺត្រូពិចដែលមិនទាន់មានការយកចិត្តទុកដាក់, សេវាពិនិត្យ និងព្យាបាលជំងឺមិនឆ្លង (ជំងឺទឹកនោមផ្អែម ជំងឺលើសសម្ពាធឈាម ជំងឺមហារីក ជាដើម), សេវាសង្គ្រោះបន្ទាន់ និងសេវាសុខភាពផ្លូវចិត្ត។ |
| ២២ សេវាស្តារនីតិសម្បទា | សំដៅដល់ការផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ការផ្តល់សេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ និងការផ្តល់សេវាសង្គម ក្នុងគោលបំណងជួយដល់ជនមានពិការភាពឱ្យអាចរក្សា ស្តារ ឬធ្វើឱ្យប្រសើរឡើងវិញនូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ ដែលបានបាត់បង់ឬខូចខាតដោយសារជំងឺ ការរងរបួស ឬពិការភាព។ |
| ២៣ សុខដុមនីយកម្ម | សំដៅដល់ការកែសម្រួលភាពផ្សេងគ្នា និង/ឬភាពមិនស៊ីចង្វាក់គ្នា ដែលពាក់ព័ន្ធនិងការវាស់វែង វិធីសាស្ត្រ នីតិវិធី កាលវិភាគ លក្ខណៈបច្ចេកទេស ឬប្រព័ន្ធដើម្បីធ្វើឱ្យមានឯកភាពមានភាពសមស្រប សម្រាប់ទាំងអស់គ្នា។ |
| ២៤ អន្តរប្រតិបត្តិការ | សំដៅដល់សមត្ថភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអាចធ្វើសន្ទានកម្ម(ទៅវិញទៅមក) ជាមួយគ្នា ក្នុងការផ្លាស់ប្តូរ ប្រកបដោយប្រសិទ្ធភាព ដែលនឹងធ្វើឱ្យប្រសើរឡើងនូវគុណភាព ប្រសិទ្ធភាព និងភាពងាយស្រួលក្នុងការចូលទៅប្រើប្រាស់សេវាគាំពារសង្គមនានា ដោយអនុញ្ញាតឱ្យមានការទំនាក់ទំនង និងការផ្លាស់ប្តូរទិន្នន័យជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានា ដោយងាយស្រួល និងដោយស្វ័យប្រវត្តិក្រោមលក្ខខណ្ឌច្បាស់លាស់។ |
| ២៥ អភិក្រមហានិភ័យនៃវដ្តជីវិត | សំដៅដល់ការគិតគូរពីបញ្ហាប្រឈមដែលអាចកើតមានក្នុងដំណាក់កាលនីមួយៗនៃវដ្តជីវិតដែលមានដូចជាវ័យកុមារ វ័យបំពេញការងារ និងវ័យចាស់ ដែលហានិភ័យទាំងនោះមានដូចជា មាតុភាព និងហានិភ័យកុមារភាព, ហានិភ័យការងារ, និកម្មភាពការងារ, ហានិភ័យវ័យចាស់ និងឧត្តរជីវី, ហានិភ័យសុខភាព, ភាពគ្មានជម្រក, និងពិការភាព។ |

# ឧបសម្ព័ន្ធ ២

## សេចក្ដីសម្រេចស្ដីពីការបង្កើតក្រុមការងារបច្ចេកទេសរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០៣០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ [illegible]

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

**សេចក្ដីសម្រេច**
**ស្ដីពី**
**ការបង្កើតក្រុមការងារបច្ចេកទេសរៀបចំ**
**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០៣០**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សា-ជាតិគាំពារសង្គម
- បានឃើញសេចក្ដីសម្រេចលេខ ០០៣ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

**ប្រការ ១ .-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០៣០ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **វង្ស វិសុទ្ធ** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការប្រតិបត្តិនៃក្រុម-ប្រឹក្សាជាតិគាំពារសង្គម | ប្រធាន |
| ២. | លោកជំទាវ **ម៉ែន សុបតា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តមវេជ្ជបណ្ឌិត **ឡូ វាសនាគិរី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៤. | ឯកឧត្តម **ស៊ុំ សោភ័ណ** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៥. | ឯកឧត្តមបណ្ឌិត **ចន ណារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម | អនុប្រធានប្រចាំការ |
| ៦. | ឯកឧត្តម **ឈួរ សុបញ្ញា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃមូលនិធិជាតិជំនួយសង្គមនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៧. | ឯកឧត្តម **ង៉ាន ម៉ុនធឿន** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៨. | ឯកឧត្តមបណ្ឌិត **សាន វឌ្ឍនា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩. | ឯកឧត្តម **និន សុខឃួន** | អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១០. | លោកជំទាវ **ខៀវ សុផានី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១១. | ឧត្តមសេនីយ៍ឯក **សំ ចាន់ធួន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានយោធសេវា ទទួលបន្ទុកការងារគោលនយោបាយនៃក្រសួងការពារជាតិ | សមាជិក |
| ១២. | ឯកឧត្តម **ឡៅ សិទ្ធិរ៉ូ** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ១៣. | ឯកឧត្តម **សុទ្ធ គីមកុលមុនី** | ទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងជាប្រធាននាយកដ្ឋានផែនការ និងស្រាវជ្រាវ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| ១៤. | លោកស្រី **សេងផល ដាវីន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍន៍សេដ្ឋកិច្ច នៃក្រសួងកិច្ចការនារី | សមាជិក |
| ១៥. | លោក **គគ្គី សម្បូរណ៍** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុម-ប្រឹក្សាជាតិគាំពារសង្គម | សមាជិក |
| ១៦. | លោក **លី យ៉ាសាក់** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៧. | លោក **វង្ស រតនា** | អនុប្រធាននាយកដ្ឋានរៀបចំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងកិច្ចប្រជុំផ្សេងទៀតនៃអគ្គនាយក-ដ្ឋានសម្របសម្រួលកិច្ចការទូទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៨. | លោក **សេង ជាសិទ្ធ** | ប្រធាននាយកដ្ឋាននីតិកម្មគោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

| | | | |
|---|---|---|---|
| ១៩. | លោកបណ្ឌិត **ស្រី ទុន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា<br>នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២០. | លោកស្រី **គ្រុយ ណារិន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ<br>នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២១. | លោក Holger Thies | ទីប្រឹក្សាជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-<br>ជាតិគាំពារសង្គម | សមាជិក។ |

**ប្រការ ២ .-**

ក្រុមការងារទេសបច្ចេកទេសរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០៣០ មានភារកិច្ច ដូចតទៅ÷

- ពិនិត្យលើរបាយការណ៍នៃការវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដើម្បីប្រមូលធាតុចូលក្នុងការរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០៣០
- រៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០៣០ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងអនុម័ត
- ពិគ្រោះយោបល់ជាមួយអ្នកជំនាញការ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា ដើម្បីរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០៣០ ឱ្យស្របតាមស្តង់ដារអន្តរជាតិ និង
- រាយការណ៍ជាប្រចាំជូនគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម និងក្រុមប្រឹក្សាជាតិគាំពារសង្គម អំពីវឌ្ឍនភាពនៃការរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០៣០។

**ប្រការ ៣ .-**

សមាសភាពក្រុមការងារបច្ចេកទេសដូចមានកំណត់ក្នុងប្រការ១ នៃសេចក្តីសម្រេចនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិរបស់ប្រធាន។

ក្រុមការងារបច្ចេកទេសនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចូលរួមប្រជុំតាមការចាំបាច់ និងអាចស្នើសុំកិច្ចសម្របសម្រួល និងកិច្ចសហការពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន ដទៃទៀត។

**ប្រការ ៤ .-**

អនុប្រធានប្រចាំការត្រូវចាត់មន្ត្រីបច្ចេកទេសពាក់ព័ន្ធ ដើម្បីបំពេញការងារជាលេខាធិការ នៃក្រុមការងារបច្ចេកទេសតាមការចាំបាច់។

**ប្រការ ៥ .-**

អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាជាតិគាំពារសង្គម, ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម, នាយកខុទ្ទកាល័យ, អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម, ប្រធានគ្រប់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៣

## ក្រុមការងារវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
លេខ.....២៤................../អ.ក.គ..................

**លិខិតបង្គាប់ការ**

**ស្តីពី**

**ការបង្កើតក្រុមការងារវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦ - ២០២៥**
**ប្រចាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើត គណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ០៣អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញសេចក្តីសម្រេចលេខ ០០៣ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមតម្រូវការចាំបាច់របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

**ប្រការ១ ._**

ត្រូវបានបង្កើតក្រុមការងារវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦ - ២០២៥ ប្រចាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងគោលបំណងធ្វើការវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦ - ២០២៥ និងរៀបចំសេចក្តីព្រាងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ជំនាន់ទី២ (Version 2.0) ដាក់ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**ប្រការ២ ._**

ក្រុមការងារវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ប្រចាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម មានសមាសភាពដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| ១. | លោក | **គន្ធី សម្បូរណ៍** | អគ្គលេខាធិការរង | ប្រធាន |
| ២. | លោក | Holger THIES | ទីប្រឹក្សា | សមាជិក |
| ៣. | លោក | **ឡេង សុខឡុង** | ទីប្រឹក្សា | សមាជិក |
| ៤. | លោក | **ឡាយ សុផានិត** | មន្ត្រីវិភាគ | សមាជិក |
| ៥. | កញ្ញា | **ហួយ បុណ្ណាស៊ី** | មន្ត្រីវិភាគ | សមាជិក។ |

**ប្រការ៣ ._**

ក្រុមការងារវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦ - ២០២៥ ប្រចាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម មានភារកិច្ចដូចតទៅ÷

- រៀបចំឯកសារទស្សនទាន និងផែនការសកម្មភាព ស្តីពីការវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦ - ២០២៥
- រៀបចំឯកសារទស្សនទាន ផែនការសកម្មភាព និងសេចក្តីព្រាងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ជំនាន់ទី២ (Version 2.0) ដើម្បីដាក់ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានពិនិត្យ និងសម្រេច
- សម្របសម្រួលជាមួយ អ្នកជំនាញការជាតិ និងអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធលើការវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម
- សម្របសម្រួល និងពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងមន្ត្រីជំនាញ លើការងារពាក់ព័ន្ធនឹងការវាយតម្លៃ តាមការចាំបាច់
- រៀបចំរបាយការណ៍លទ្ធផលការងារ និងលើកអនុសាសន៍ពាក់ព័ន្ធនឹងការវាយតម្លៃក្របខណ្ឌគោល-នយោបាយជាតិគាំពារសង្គម ជូនថ្នាក់ដឹកនាំ

- ផ្សព្វផ្សាយលទ្ធផល និងអនុសាសន៍នៃការវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដើម្បីពង្រីកការយល់ដឹងជាសាធារណៈ
- អនុវត្តការងារពាក់ព័ន្ធផ្សេងៗទៀតតាមការចាំបាច់ និងការណែនាំរបស់ថ្នាក់ដឹកនាំ។

**ប្រការ៤ ._**

ក្រុមការងារវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ប្រចាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវមាន របបប្រជុំយ៉ាងតិច ១ខែម្តង។ សមាជិក ឬសមាជិការក្រុមការងារទាំងអស់ ត្រូវចូលរួមកិច្ចប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។

ករណីប្រធានក្រុមការងារអវត្តមាន ប្រធានអាចចាត់តាំង សមាជិក ឬសមាជិកាណាម្នាក់ ដើម្បីសម្របសម្រួលកិច្ចប្រជុំ។

**ប្រការ៥ ._**

អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានក្រោមចំណុះអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ព្រមទាំងសាមីខ្លួន ដូចក្នុងប្រការ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមលិខិតបង្គាប់ការនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២២

**ក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គលេខាធិការ**

**ចន ណារិទ្ធ**

**កន្លែងទទួល៖**

-អគ្គលេខាធិការរង

-គ្រប់នាយកដ្ឋាន

-ដូចប្រការ៥ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៤

## ក្រុមការងារគាំទ្រប្រចាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម សម្រាប់ការរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥

| | | |
|---|---|---|
| ១ | លោក **ឃាន ត្តូក** | អគ្គលេខាធិការរង |
| ២ | លោក **ស្រេង សោភ័ណរស្មី** | ប្រធាននាយកដ្ឋានគោលនយោបាយ |
| ៣ | លោក **ឡេង សុខឡុង** | ប្រធាននាយកដ្ឋានត្រួតពិនិត្យ |
| ៤ | លោក **ធឿង ធានី** | ប្រធានស្តីទីនាយកដ្ឋានគាំទ្រប្រតិបត្តិការ |
| ៥ | លោក **អេ ប៊ុនធិន** | អនុប្រធាននាយកដ្ឋានគោលនយោបាយ |
| ៦ | លោក **ឡាត សូយ** | មន្ត្រី |
| ៧ | លោក **ឱត្យ អានច័ន្ទគ្រឹះស្នា** | មន្ត្រី |
| ៨ | កញ្ញា **ហ៊ាង កញ្ញារី** | មន្ត្រី |
| ៩ | លោក **ហេង បណ្ឌូល** | មន្ត្រី |
| ១០ | លោកស្រី **ហួយ បូណាស៊ី** | មន្ត្រី |
| ១១ | លោក **ឡាយ សុផានិត** | មន្ត្រីវិភាគជាន់ខ្ពស់ |
| ១២ | លោក **ឱត្យ ចំរើនរាជ្យ** | មន្ត្រីវិភាគជាន់ខ្ពស់ |
| ១៣ | លោក **តាំង គីមអៀង** | មន្ត្រីវិភាគជាន់ខ្ពស់ |
| ១៤ | លោកស្រី **មាត្រា ចរល័ក្ខណា** | មន្ត្រីវិភាគ |
| ១៥ | កញ្ញា **ស៊ី សុវណ្ណារី** | មន្ត្រីវិភាគ |
| ១៦ | លោក **ហ៊ុន ពិច** | មន្ត្រីវិភាគ |
| ១៧ | កញ្ញា **ឡាវ គឹមរស្មី** | មន្ត្រីវិភាគ |
| ១៨ | កញ្ញា **ហង្ស ឧស្សា** | មន្ត្រីវិភាគ |
| ១៩ | កញ្ញា **ឈា មួយឡេង** | មន្ត្រីវិភាគ |
| ២០ | កញ្ញា **ឈុំ មុនីរម្យ** | មន្ត្រីវិភាគ |
| ២១ | លោកស្រី **ភៅ សុភាព** | មន្ត្រីវិភាគ |
| ២២ | លោក **ម៉ែន ចន្ទមុន្នីបញ្ញា** | មន្ត្រីវិភាគ |
| ២៣ | លោក **ស្រេង ធីម្លីសិលា** | មន្ត្រីវិភាគ |

ក្រុមប្រឹក្សាជាតិគាំពារសង្គម

គាំពារ
សង្គម
កម្ពុជា

SOCIAL PROTECTION IN CAMBODIA

NATIONAL SOCIAL PROTECTION COUNCIL